ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី១

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៤

# របស់ គ.ជ.អ.ប.

អនុម័តដោយ៖ គ.ជ.អ.ប.

ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤

# មាតិកា

**មាតិកា** ...... i
**អក្សរកាត់** ...... ii
១. សេចក្តីផ្តើម ...... ១
២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ...... ២
ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ...... ២
ខ. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ...... ២៥
គ. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ...... ៣៣
ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៣៩
ង. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន ...... ៤៤
៣. ស្ថានភាពហិរញ្ញវត្ថុ ...... ៥១
៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ ...... ៥៣
៥. សកម្មភាពជាអាទិភាពសម្រាប់ឆមាសទី២ ឆ្នាំ២០២៤ ...... ៥៤
៦. សេចក្តីសន្និដ្ឋាន ...... ៥៨
**ឧបសម្ព័ន្ធ**
១. តារាងវឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពប្រចាំឆមាសទី១ ឆ្នាំ២០២៤ ...... ៦០
២. តារាងវឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់ស្ថាប័នអនុវត្ត ...... ១១៨
៣. តារាងស្ថានភាពនៃការគ្រប់គ្រងហានិភ័យ ...... ១២១

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ (២០២១-២០២៥) ដំណាក់កាលទី១នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF/ADB | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF/WB | ផែនការអនុវត្តគណនេយ្យភាពសង្គម |
| TSSD-AF/ADB | គម្រោងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច ដំណាក់កាលទី២ |
| NASLA/ADB | គម្រោងគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| LGCC-WRP/UNCDF | រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ "ពង្រីកការអនុវត្តមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| CNP/WB | គម្រោងអាហារូបត្ថម្ភនៅកម្ពុជា |
| ISD/GIZ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា |
| STA/UNDP | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ |
| CR-Wash/GCF | សេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងរណបអាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត |
| CSOs | អង្គការសង្គមស៊ីវិល |

## ១. សេចក្តីផ្តើម

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាផែនការឆ្នាំទី៤នៃការអនុវត្ត កជទី២ (២០២១-២០៣០) ដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។ ផែនការនេះ រួមមានលទ្ធផលរំពឹងទុកចំនួន **៣៤** សកម្មភាពជាអាទិភាព**ចំនួន ៨៧ និងសកម្មភាពលម្អិតចំនួន ៣១៧** និងគម្រោងថវិកាចំណាយសរុបមាន**ចំនួន ៧.០៨៨.២៥៥ លានរៀល (១.៧២៩ លានដុល្លារ)** ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមាន**ចំនួន ៦.៩៩២.៧២១ លានរៀល (១.៧០៥ លានដុល្លារ) ស្មើនឹង ៩៨,៦៥%** និងថវិកាកម្ចី និងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមាន**ចំនួន ៩៥.៥៣៤ លានរៀល (២៣ លានដុល្លារ) ស្មើនឹង ១,៣៥% នៃថវិកាសរុប**។ ថវិកាចំណាយសរុបនេះ រួមបញ្ចូលទាំងថវិកាចំណាយសម្រាប់គាំទ្រដល់ការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាចំណាយសម្រាប់គាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. រួមមាន ៥សមាសភាគដូចខាងក្រោម៖

សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ

សមាសភាគទី៥ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**តារាងទី១ ៖ សកម្មភាព និងផែនការចំណាយសរុបតាមសមាសភាគ (គិតជាលានរៀល)**

| ល.រ. | សមាសភាគ | លទ្ធផលរំពឹងទុក | សកម្មភាពជាអាទិភាព | ថវិកា | | | |
|---|---|---|---|---|---|---|---|
| | | | | រាជរដ្ឋាភិបាល | កម្ចី | ជំនួយឥតសំណង | សរុប |
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | ៥ | ២១ | ៨.៧១១ | ០ | ៤.២៣០ | ១២.៩៤១ |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៨ | ១៩ | ៨.៧៦៤ | ០ | ២៦.៥៩៣ | ៣៥.៣៥៦ |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | ៨ | ២០ | ២.៤៤៦ | ១៨.២៣៦ | ០ | ២០.៦៨២ |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | ៩ | ១៦ | ៦.៩៧០.២៤៣ | ១៧.០០០ | ០ | ៦.៩៨៧.២៤៣ |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | ៤ | ១១ | ២.៥៥៧ | ២៦.៩៨២ | ២.៤៩៤ | ៣២.០៣៣ |
| សរុបរួម | | ៣៤ | ៨៧ | ៦.៩៩២.៧២១ | ៦២.២១៨ | ៣៣.៣១៦ | ៧.០៨៨.២៥៥ |
| គិតជាភាគរយ | | | | ៩៨,៦៥% | ០,៨៨% | ០,៤៧% | ១០០% |

របាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី១ នៃឆ្នាំ២០២៤នេះ រៀបរាប់អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆមាសទី១ នៃឆ្នាំ២០២៤របស់ គ.ជ.អ.ប. គិតពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៤ រួមមាន៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ស្ថានភាពនៃការប្រើប្រាស់ថវិកា បញ្ហាប្រឈមនានា និង សកម្មភាពជាអាទិភាពសម្រាប់អនុវត្តឆ្នាំ២០២៤។

## ២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព

ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៨៧ និងសូចនាករចំនួន **១៣៩** នៃ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. មានសកម្មភាពជាអាទិភាព**ចំនួន ៧៣ ស្មើនឹង ៨៣% (បានបញ្ចប់ចំនួន ២៧ និងកំពុងអនុវត្តចំនួន ៤៦)** និងសូចនាករ**ចំនួន ១១៤ ស្មើនឹង ៨២%** ត្រូវបានអនុវត្ត ដូចមានសង្ខេបក្នុងតារាងខាងក្រោម។

**តារាងទី២ ៖ ស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាព**

| សមាសភាគ | បរិយាយ | សកម្មភាពអាទិភាព | បានអនុវត្ត (ចំនួន) | បានអនុវត្ត (%) |
|---|---|---|---|---|
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | ២១ | ២១ | ១០០% |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៩ | ១៥ | ៧៩% |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | ២០ | ១៣ | ៦៥% |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | ១៦ | ១៣ | ៨១% |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | ១១ | ១១ | ១០០% |
| សរុប | | **៨៧** | **៧៣** | **៨៣%** |

លទ្ធផលសំខាន់ៗនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆមាសទី១ នៃឆ្នាំ២០២៤ មានរៀបរាប់តាមសមាសភាគនីមួយៗ ដូចខាងក្រោម៖

### ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី១នេះ រួមមានសកម្មភាពជាអាទិភាពចំនួន **២១** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន **២១** ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាព ដូចខាងក្រោម៖

**១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់**

- បានរៀបចំ និងកែសម្រួលសមាសភាព គ.ជ.អ.ប. ឱ្យស្របទៅនឹងសមាសភាពថ្មីនៃរាជរដ្ឋាភិបាលនៃអាណត្តិទី៧នៃរដ្ឋសភា តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣

- គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំលើកទី២២របស់ខ្លួន នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤ ដែលមានសមាសភាពចូលរួមចំនួន១៥០នាក់ ដោយបានពិនិត្យ ពិភាក្សា និងអនុម័តលើរបៀបវារៈសំខាន់ៗ រួមមាន៖ (១) ការអនុម័តកំណត់ហេតុកិច្ចប្រជុំលើកទី២១ របស់ គ.ជ.អ.ប. (២) ការអនុម័តលើរបាយការណ៍នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ របស់ គ.ជ.អ.ប. (៣) ការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (៤) ពិនិត្យ និងផ្តល់ការឯកភាពលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. និង (៥) របៀបវារៈផ្សេងៗពាក់ព័ន្ធនឹងការជំរុញ និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលរាជធានី ខេត្តក្នុងការចុះបញ្ជីគម្រោងវិនិយោគក្រោម៥លានដុល្លារ ការបន្តពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក និងការពន្លឿនការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចង្អៀតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូលក្រោម៥លានដុល្លារនៅថ្នាក់រាជធានី ខេត្ត ព្រមទាំងដាក់ចេញនូវវិធានការក្នុងការជំរុញការរៀបចំការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរអង្គភាពក្នុងការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូលក្រោម៥លានដុល្លារ
- ដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន១៩នាក់ នៅប្រទេសស្វីស ដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) ដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដែលមានគោលបំណងសិក្សាឈ្វេងយល់អំពីមេរៀន និងពិសោធន៍ល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចនៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ព្រមទាំងពង្រឹង និងពង្រីកទំនាក់ទំនងរវាងកម្ពុជា និងស្វីសក្នុងកិច្ចសហប្រតិបត្តិការនាពេលអនាគត
- បានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដើម្បីតម្រឹមជាមួយច្បាប់រៀបចំអង្គការសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដូចជាសេចក្តីព្រាងច្បាប់ស្តីពីសុរិយោដី សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្រសួងអប់រំ យុវជន និងកីឡា។ល។

**២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព**

- រាជរដ្ឋាភិបាលបានអនុម័តនូវអនុក្រឹត្យលេខ១៦ អ.ន.ក្រ. បក. ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប. ដោយបានកែសម្រួល

អនុគណៈកម្មាធិការនៃ គ.ជ.អ.ប. ដែលមានចំនួន៥ មកត្រឹមចំនួន៣ គឺអនុគណៈកម្មាធិការមុខងារ និងធនធាន អនុគណៈកម្មាធិការកិច្ចការសារពើពន្ធនិងហិរញ្ញវត្ថុ និងអនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- គ.ជ.អ.ប. បានដាក់ចេញសេចក្ដីសម្រេចស្ដីពីការទទួលស្គាល់សមាសភាពអនុគណៈកម្មាធិការទាំង៣របស់ គ.ជ.អ.ប. តាមសេចក្ដីសម្រេចលេខ ០២៧.សសរ/គ.ជ.អ.ប. ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤
- អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ដែលមានការចូលរួមពីសមាជិកអនុគណៈកម្មាធិការមុខងារ និងធនធាន តំណាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំនេះ ដឹកនាំដោយឯកឧត្តម **សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដែលមានគោលបំណងដើម្បី៖ (១) ប្រកាសសមាសភាពថ្មីនៃអនុគណៈកម្មាធិការមុខងារ និងធនធាន (២) ពិនិត្យ និងពិភាក្សាលើស្ថានភាពនៃការអនុវត្តមុខងារក្នុងវិស័យការងារ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្ដល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយថ្នាក់រាជធានី ខេត្ត និង (៣) ពិនិត្យ និងពិភាក្សាលើបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.**

- ថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គភាពមួយចំនួននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានរៀបចំតែងតាំង និងបំពេញបន្ថែមឡើងវិញ **០៨រូប** ដែលរួមមាន ប្រធានលេខាធិការដ្ឋាន **០១រូប** អនុប្រធានលេខាធិការដ្ឋាន **០៥រូប** និងប្រធានអង្គភាព **០២រូប**
- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំការវិភាគមុខងារ រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងការរៀបចំការពិពណ៌នាមុខតំណែង ការកំណត់អំពីតម្រូវការធនធានមនុស្ស ព្រមទាំងតម្រូវការអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីបុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប.
- បានចាត់តាំងមន្ត្រីជាន់ខ្ពស់ចំនួន ០១រូប នៃលេខាធិការដ្ឋាន គ.ជ.អ.ប. ចូលរួមទស្សនកិច្ចសិក្សានៅប្រទេសថៃ ស្ដីពីការគ្រប់គ្រង និងការផ្ដល់សេវាសុខាភិបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិកាលពីថ្ងៃទី១៤-១៧ ខែឧសភា ឆ្នាំ២០២៤។ ទស្សនកិច្ចសិក្សានេះរៀបចំដោយក្រសួងមុខងារសាធារណៈ ក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈគំរូវិស័យសុខាភិបាល ដោយមានការចូលរួមពីមណ្ឌលសុខភាពដែលជាប់ចំណាត់ថ្នាក់ទាំង១០ និងគណៈកម្មាធិការបច្ចេកទេស

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានបញ្ជូនមន្ត្រីជាថ្នាក់ដឹកនាំចំនួន០៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ជំនាន់៦ នៅសាលាភូមិន្ទរដ្ឋបាល ដែលមានរយៈពេល០៣ខែ ចាប់ផ្តើមពីខែមីនា ដល់ខែមិថុនា ឆ្នាំ២០២៤
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានចាត់តាំងមន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាស្តីពីការពង្រឹងភាពជាដៃគូក្នុងតំបន់សម្រាប់ការប្រែប្រួលអាកាសធាតុនៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៤ នៅទីក្រុងបាងកក ប្រទេសថៃ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ក្នុងតំបន់នានា និងមានការរៀបចំឡើងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ សិក្ខាសាលានេះ គឺជាវេទិកាមួយសម្រាប់ការផ្លាស់ប្តូរថ្នាក់តំបន់ ការចែករំលែកបទពិសោធការអនុវត្តល្អបំផុត និងផ្តល់នូវមធ្យោបាយឆ្ពោះទៅមុខ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការរៀនសូត្រជាក់ស្តែងពីបទពិសោធការងារនៅតាមបណ្តាប្រទេសនានានៅអាស៊ីខាងត្បូង និងតំបន់អាស៊ីអាគ្នេយ៍
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំប្រចាំខែជាទៀងទាត់ ដើម្បីតាមដានត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ បញ្ហាប្រឈម និងដំណោះស្រាយនានា។

**៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.)**

- គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ.ឆ្នាំ២០២៤ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២១ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត
- គ.ដ.វ.វ. នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត។

**៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួលរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់៣បូក១ និងរៀបចំសកម្មភាពអាទិភាពសម្រាប់រយៈពេល៦ខែដើមឆ្នាំ២០២៤ ដើម្បីត្រៀមកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ (យ.ស.ក.) ដែលដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប.
- លេខាធិការដ្ឋាននៃកំណែទម្រង់ទាំង៥ ដែលរួមមានកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បានចុះធ្វើការសិក្សាឈ្វេងយល់អំពីការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងថវិកា និងក្របខ័ណ្ឌគណនេយ្យភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាព និងកំណត់បញ្ហាប្រឈម និងសំណើ

ដំណោះស្រាយក្នុងទិដ្ឋភាពនៃកំណែទម្រង់ទាំង៥នៅខេត្តប៉ៃលិន កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ និងខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

- បានសហការជាមួយកំណែទម្រង់៤ផ្សេងទៀតក្នុងការរៀបចំផែនការសកម្មភាពរួមនៃកំណែទម្រង់ទាំង៥សម្រាប់ឆមាសទី២ ឆ្នាំ២០២៤ និងសម្រាប់ឆ្នាំ២០២៥ ព្រមទាំងបានពិនិត្យកែសម្រួលអនុក្រឹត្យស្ដីពីយន្តការសុខដុមនីយកម្មនៃកំណែទម្រង់គន្លឹះទាំង៥
- បានចូលរួមកិច្ចប្រជុំ និងវិបស្សនាប្រចាំឆ្នាំស្ដីពីយន្តការអន្តរកំណែទម្រង់ស្នូលទាំង៥របស់រាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមនៃការកែទម្រង់ទាំង៥របស់រាជរដ្ឋាភិបាល ដោយបានឯកភាពទៅលើការកែសម្រួលយន្តការពី "ការកែទម្រង់៣បូក១" និងបន្ថែមយន្តការកែទម្រង់ច្បាប់ ទៅជាយន្តការអន្តរកំណែទម្រង់គន្លឹះទាំង៥ ដើម្បីសុំការសម្រេចពីប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ និងការពិនិត្យសម្រេចពីប្រមុខរដ្ឋាភិបាល។

**៦. ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

- បាននិងកំពុងរៀបចំកិច្ចដំណើរការវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្នុងនោះកិច្ចការដែលសម្រេចបានរួមមាន (១) រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារទស្សនទានស្ដីពីការរៀចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ (២) គ.ជ.អ.ប. បានដាក់ចេញសេចក្ដីណែនាំស្ដីពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងសេចក្ដីសម្រេចស្ដីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលា សម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) បានផ្សព្វផ្សាយឯកសារទស្សនទាន និងសេចក្ដីណែនាំស្ដីពីការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានផ្ដល់ការគាំទ្រទាំងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) រដ្ឋបាលឃុំ សង្កាត់ទាំង១.៦៥២ បានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ខ្លួន ដើម្បីកំណត់អំពីបញ្ហាប្រឈមជាគន្លឹះនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់ខ្លួនឯង និងបញ្ហាប្រឈមដែលត្រូវស្នើឱ្យរដ្ឋបាលថ្នាក់លើបន្តបន្ទាប់ធ្វើអន្តរាគមន៍ដោះស្រាយ
- បានរៀបចំនូវសេចក្ដីព្រាងបឋមឯកសារទស្សនទានស្ដីពីកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនង គណនេយ្យភាព និងការទទួលខុសត្រូវរវាងក្រុមប្រឹក្សា និងគណៈអភិបាល ការពិភាក្សា និងការផ្លាស់ប្ដូរយោបល់លើការអនុវត្តគោលនយោបាយ និងសេចក្ដីសម្រេចចិត្តនានា ការដឹកនាំសម្របសម្រួល ព្រមទាំងការកំណត់នូវបញ្ហាប្រឈម និងអនុសាសន៍សម្រាប់លើកសំណើកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា**

- លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងពិនិត្យ និងកែសម្រួលទៅលើលក្ខខណ្ឌការងាររបស់ក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (TWG) ដើម្បីឱ្យមានលក្ខណៈសមស្របទៅតាមស្ថានភាពនៃការវិវត្តនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានរៀបចំផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំក្រុមការងារបច្ចេកទេសវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ភាគីខាងរាជរដ្ឋាភិបាល) ដែលរួមមាន (១) **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. ជាប្រធានក្រុមការងារ** និង (២) **ឯកឧត្តម ចាន់ សុធា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាប្រធានលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេស**
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានជួបប្រជុំពិភាក្សាជាមួយតំណាងស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា អំពីការបន្សុីរវាងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការអភិវឌ្ឍន៍ភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ រវាងរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា។

**៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិដល់អភិបាល អភិបាលរងជាស្ត្រី នាយករដ្ឋបាល និងនាយករងរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុកទាំង១៣ នៃខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប ៤៩រូប (ស្ត្រី២១រូប)
- គ.ក.ស.ក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានរៀបចំកិច្ចប្រជុំជារៀងរាល់ខែបានទៀងទាត់ ដើម្បីពិនិត្យមើលសកម្មភាពនានាទាក់ទងអំពីហិង្សា ជនងាយរងគ្រោះជាស្ត្រីនិងកុមារ ការផ្តល់យោបល់លើការថែទាំមាតាមានផ្ទៃពោះ ការអប់រំកុមារ និងការរក្សាអនាម័យដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហា និងបានជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច។

**៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង**

- បាននិងកំពុងបន្តសហការជាមួយនឹងអង្គការ GIZ ក្នុងការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយមានការគាំទ្រពីទីប្រឹក្សាឯករាជ្យដែលជ្រើសរើសឡើងដោយអង្គការ GIZ និងគ្រោងបញ្ចប់នៅដំណាច់ឆ្នាំ២០២៤នេះ
- បាននិងកំពុងកែលម្អ និងពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងដោយប្រមូលធាតុចូលពីរដ្ឋបាលរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តរតនគិរី ដើម្បីកែសម្រួលសៀវភៅយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដោយគ្រោងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៤
- បានបន្តផ្សព្វផ្សាយ និងដាក់បញ្ចូលឯកសារព័ត៌មានក្នុងគេហទំព័រ បណ្តាញសង្គម Facebook YouTube និង Chanel Telegram ជាប្រចាំ

- Facebook page របស់លេខាធិការដ្ឋាន គ.ជ.អ.ប. មានចំនួនអ្នកចូលចិត្តចំនួន (Like) ៣៧.៥១៣នាក់ ចំនួនអ្នកតាមដាន (Follower) ៣៩.២៤៤នាក់ ចំនួនចូលទស្សនា (Reach) ៣.៩៩៩នាក់
- Chanel telegram របស់លេខាធិការដ្ឋាន គ.ជ.អ.ប. មានអ្នកតាមដានចំនួន ១.២៤៦នាក់
- Telegram Chanel របស់គណនេយ្យភាពសង្គមមានអ្នកតាមដានចំនួន ២.០០២នាក់
- YouTube របស់លេខាធិការដ្ឋាន គ.ជ.អ.ប. មានអ្នកតាមដានចំនួន ២.៣៣០នាក់។

**១០. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានបញ្ចូលឯកសារនានាពាក់ព័ន្ធទៅនឹងកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិករបស់ គ.ជ.អ.ប. បាន**ចំនួន ១២.៣៥០** ឯកសារ និងត្រៀមបញ្ចូលនូវឯកសារ**ប្រមាណ ១៣.៥៧៧** ឯកសារបន្ថែមទៀតទៅក្នុងបណ្ណាល័យអេឡិចត្រូនិកនេះ
- បានរៀបចំវីដេអូឯកសារអំពីការងារគណនេយ្យភាពសង្គម និងបានផ្សព្វផ្សាយជូនថ្នាក់ដឹកនាំក្នុងដំណើរទស្សនកិច្ចស្តីពីការងារគណនេយ្យភាពសង្គមរបស់គណៈប្រតិភូជាតិ និងអន្តរជាតិដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ នៅខេត្តកំពត និងបានសម្របសម្រួលជាមួយស្ថាប័នអ្នកសារព័ត៌មានចំនួន ០៧ស្ថាប័ន និងទូរទស្សន៍ BTV ដើម្បីបន្តផ្សព្វផ្សាយព័ត៌មានអំពីការងារគណនេយ្យភាពសង្គម
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការផ្សព្វផ្សាយព័ត៌មានសរុបចំនួន២៥ព័ត៌មានសំខាន់ៗដូចជាព័ត៌មានកិច្ចប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដំណើរទស្សនកិច្ចស្តីពីការងារគណនេយ្យភាពសង្គមរបស់គណៈប្រតិភូជាតិ អន្តរជាតិ សារលិខិតជូនពរ ឯកសារសេចក្តីសម្រេចនានា បេសកកម្មជាមួយដៃគូអភិវឌ្ឍន៍ និងវគ្គបណ្តុះបណ្តាលផ្សេងៗដាក់ក្នុងប្រព័ន្ធបណ្តាញសង្គម Facebook និង Telegram ក្នុងនោះមានសេចក្តីប្រកាសចំនួន០២ បានដាក់ចូលក្នុងគេហទំព័រ និងវីដេអូចំនួន០៣ បានដាក់ចូលក្នុងបណ្តាញ YouTube របស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- បាន និងកំពុងពិនិត្យកែសម្រួលលើផែនការសកម្មភាព និងថវិកា និងពិនិត្យបញ្ចប់លើលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសក្រុមហ៊ុនជំនាញអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តសាកល្បង និងបានរៀបចំគោលការណ៍អនុវត្តទៅតាមនីតិវិធីលទ្ធកម្ម ដើម្បីដំណើរការជ្រើសរើសទីប្រឹក្សា
- បានរៀបចំបទដ្ឋានបច្ចេកទេស និងធ្វើលទ្ធកម្មទិញម៉ាស៊ីនមេ (Server) ចំនួន០២គ្រឿងសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**១១. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង**

- បាននិងកំពុងប្រមូលធាតុចូលនានាដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឧបករណ៍ និងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនរួមមាន៖ រដ្ឋបាល

រាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តរតនគិរី ដែលទទួលបានការគាំទ្របច្ចេកទេស និងថវិកាពីអង្គការ GIZ។

**១២. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃ កជទី២**

- គិតត្រឹមខែមិថុនា ឆ្នាំ២០២៤នេះ ការអនុវត្តផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី១ គឺមានរយៈពេល ៣ឆ្នាំ ៦ខែ ដែលសម្រេចបានលទ្ធផលដូចខាងក្រោម៖
  - លទ្ធផលរំពឹងទុក**ចំនួន ៣៥ ស្មើនឹង ៩៥%** នៃលទ្ធផលរំពឹងទុកសរុប**ចំនួន ៣៧** នៃផអ៥ទី១ បាននិងកំពុងអនុវត្ត និងលទ្ធផលរំពឹងទុក**ចំនួន ០២ មិនទាន់បានអនុវត្ត** រួមមាន (១) វិធីសាស្ត្របណ្ដុះបណ្ដាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត និង (២) ក្របខ័ណ្ឌអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
  - សកម្មភាពជាអាទិភាព**ចំនួន ៨៤ ស្មើនឹង ៧៤%** នៃសកម្មភាពជាអាទិភាពសរុបចំនួន **១១៣** នៃផអ៥ទី១ បាននិងកំពុងអនុវត្ត និងសកម្មភាពជាអាទិភាព**ចំនួន ១៧ មិនទាន់អនុវត្ត**។

**១៣. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.**

- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៤ របស់ គ.ជ.អ.ប. និងរបាយការណ៍នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ របស់ គ.ជ.អ.ប. បានអនុម័តនាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ និងបានបោះពុម្ព ផ.ស.ថ. ឆ្នាំ២០២៤ ចំនួន ១០០ក្បាល និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ ឆ្នាំ២០២៣ ចំនួន ១០០ក្បាល ដើម្បីបែងចែក និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានសម្របសម្រួល ពិនិត្យ និងអនុម័តសេចក្ដីសម្រេចរួមឆ្នាំ២០២៤ រវាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និង គ.ជ.អ.ប. សរុបក្រសួង ស្ថាប័នចំនួន ២០ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥។ បន្ទាប់ពីការចុះសេចក្ដីសម្រេចរួមរួចមក លេខាធិការដ្ឋាន គ.ជ.អ.ប. បន្តតាមដាន និងសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តទៅលើសកម្មភាពដែលមាននៅក្នុងផែនការដែលបានគ្រោងទុកនៃឆ្នាំ២០២៤ ដើម្បីសម្រេចគោលដៅ ចក្ខុវិស័យឱ្យស្របផែនការអនុវត្តរយៈពេល០៥ឆ្នាំ (២០២១-២០២៥) នៃកម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) នៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- គ.ជ.អ.ប. បានបញ្ជូនសេចក្ដីព្រាងផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥ ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងក្របខ័ណ្ឌពេលវេលា ត្រូវបានរៀបចំ និងបានបញ្ជូនទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីត្រៀមដាក់បញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ដើម្បីជានាដល់ការចូលរួមអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។

**១៤. ការរៀបចំ និងការដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃ គជអប នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា (២០២៥-២០២៧) របស់ខ្លួន និងបានប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានរតនាគារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ព្រមទាំងបានពិភាក្សា និងចរចាជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមផែនការអនុវត្តរយៈពេល០៥ឆ្នាំ ដំណាក់កាលទី១ (២០២១-២០២៥) និងបានបញ្ជូនទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពិនិត្យមើលលើសកម្មភាព និងដាក់បញ្ចូលសកម្មភាពរបស់ខ្លួនទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់សាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់យោបល់ មុននឹងរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ របស់ គ.ជ.អ.ប.។

**១៥. ការរៀបចំគម្រោងនានាគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សុំជាមួយនឹង គជអប**

- បានរៀបចំទិន្នន័យប្រែប្រួលអាកាសធាតុសម្រាប់ស្រុកគោលដៅចំនួន៧៨ ដែលបានទទួលហិរញ្ញប្បទានប្រែប្រួលអាកាសធាតុពីគម្រោង SRL, LGCC, ASPIRE ដែលក្នុងនោះមានស្រុកចំនួន៥០ បានទទួលមូលនិធិបន្សាំនឹងអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត (PBCRG) ដើម្បីកំណត់តំបន់ភូមិសាស្ត្រអាទិភាពក្នុងការរៀបចំកម្មវិធីការងាររយៈពេល០៥ឆ្នាំ ស្តីពីការប្រែប្រួលអាកាសធាតុដំណាក់កាលទី២ ពីឆ្នាំ២០២៤-២០២៨ (Entity Work Program-EWP) របស់លេខាធិការដ្ឋាន គ.ជ.អ.ប. សម្រាប់មូលនិធិអាកាសធាតុបៃតង
- បានរៀបចំគំរូស្តីពីការកសាងគោលគំនិតនៃគម្រោងវិនិយោគរបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីបញ្ជ្រាបទៅក្នុងកម្មវិធីការងាររយៈពេល៥ឆ្នាំស្តីពីការប្រែប្រួលអាកាសធាតុដំណាក់កាលទី២ ពីឆ្នាំ២០២៤-២០២៨ (Entity Work Program-EWP)របស់លេខាធិការដ្ឋាន គ.ជ.អ.ប. សម្រាប់មូលនិធិអាកាសធាតុបៃតង
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលបេសកកម្មពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយក្រុមការងារ IFAD ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដែលបានព្រមព្រៀងគ្នានៃបេសកកម្មត្រួតពិនិត្យចុងក្រោយ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តគម្រោង ព្រមទាំងស្វែងរកការពង្រឹងការរៀបចំនិរន្តរភាពគម្រោង
- **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** បានជួបពិភាក្សាការងារជាមួយនឹងលោក **ចូសេហ្វ សូយ៉េ** អ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ (UN) ប្រចាំប្រទេសកម្ពុជា និងសហការីលើកិច្ចសហប្រតិបត្តិការលើវិស័យ

អាទិភាពមួយចំនួនរួមមាន អភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សុវត្ថិភាព ផ្លូវថ្នល់ ការប្រឆាំងហិង្សាផ្នែកយេនឌ័រ ការប្រែប្រួលអាកាសធាតុ សន្តិសុខស្បៀង និងកិច្ចការពារសង្គម

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានជួបពិភាក្សាការងារជាមួយលោកស្រី Tegan Park **លេខាទី១** ទទួលបន្ទុកសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍនៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជាអំពីការបន្សុីគ្នារវាងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់កម្ពុជា និងគោលនយោបាយការបរទេសរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលផ្តល់អាទិភាពលើការពង្រឹងអភិបាលកិច្ច គណនេយ្យភាព ការផ្តល់សេវាប្រកបដោយបរិយាបន្ន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានជួបពិភាក្សាការងារជាមួយលោក **ហ្សាង ជាំងហ្វឹង** (Zhang **Jiangfeng**) ប្រធានផ្នែកអភិវឌ្ឍន៍ជនបទ កសិកម្ម ស្បៀង និងធនធានធម្មជាតិនៃធនាគារអភិវឌ្ឍន៍អាសុីលើបញ្ហាចំនួន ០២ រួមមាន (១) ការអនុវត្តគម្រោងនានាក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាសុី និង (២) កិច្ចសហប្រតិបត្តិការនាពេលអនាគតរវាង គ.ជ.អ.ប. និងធនាគារអភិវឌ្ឍន៍អាសុីក្នុងការលើកកម្ពស់ការអភិវឌ្ឍជនបទ និងភាពធន់នឹងអាកាសធាតុ
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានទទួលជួបពិភាក្សាជាមួយតំណាងអង្គការ UNDP លើការងារតាមដានការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨) ដើម្បីបន្សុីគ្នាលើយន្តការតាមដាន និងវាយតម្លៃរបស់ក្រសួង ស្ថាប័ននីមួយៗក្នុងគោលបំណងធានាបានប្រសិទ្ធភាព និងការអនុវត្តទាន់ពេលវេលា
- គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន១១ បានជួយគាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់មួយចំនួនមានដូចជា៖ គម្រោង WB/ISAF-Supply Side, GIZ/ISD, UNCDF/LGCC-WRP, ADB/SNIF, ADB/NASLA, GCF/READINESS, UNDP/STA, WB/CNP, WB/Solid Waste, ADB/Smart City, និង UNICEF
- បានរៀបចំ និងសហការរៀបចំសំណើគម្រោងថ្មីមួយចំនួនសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរួមមានចំនួន ៦ ដូចជា៖ (១) រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុជំហានទី៣ (LGCC-III) (២) Readiness KHM-RS-011 ស្តីពីការអភិវឌ្ឍហិរញ្ញប្បទានអាកាសធាតុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា (៣) សេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងរណបអាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត (CR-Wash) (៤) ការធ្វើឱ្យប្រសើរឡើងនូវកសិកម្មអេកូឡូសុីដែលងាយរងគ្រោះដោយសារអាកាសធាតុនៅតំបន់ខ្ពង់រាប (Agroecological transitions) (៥) ពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី២ (EmPower II) និង (៦) ការពង្រឹងប្រព័ន្ធយន្តការបង្ការ និងឆ្លើយតបអំពើហិង្សាទាក់ទងទៅនឹងយេនឌ័រនៅប្រទេសកម្ពុជា។

## គម្រោងជាច់ដោយឡែកដែលបានគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| ល.រ | គម្រោង/គោលបំណង | រយៈពេលអនុវត្ត | គាំទ្រដោយ | ថវិកា | ភ្នាក់ងារអនុវត្ត | វឌ្ឍនភាពគម្រោង |
|---|---|---|---|---|---|---|
| ១ | **គម្រោង៖**<br>ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF)<br>**គោលបំណង៖**<br>គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយទៅជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លាភាព ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | ២០២៣-២០២៥ | មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក (គាំទ្រថវិកាដោយរដ្ឋាភិបាលអូស្រ្តាលី) | ៤លានដុល្លារ (សម្រាប់ផ្នែកផ្គត់ផ្គង់ និងតម្រូវការ) | លេខាធិការដ្ឋាន គ.ជ.អ.ប. | - បាននិងកំពុងបន្តអនុវត្តការងារគណនេយ្យភាពសង្គមបានចំនួន ១.៥៤៥ឃុំ សង្កាត់ ស្មើនឹង ៩៣% នៃចំនួនឃុំ សង្កាត់សរុប ១.៦៥២ ព្រមទាំងបានទទួលការគាំទ្រដោយរាជរដ្ឋាភិបាលអូស្ត្រាលី (DFAT) ក្នុងការបន្តគាំទ្រការងារគណនេយ្យភាពសង្គមសម្រាប់រយៈពេល២ឆ្នាំ (២០២៤ -២០២៥) ក្រោមការសម្របសម្រួលដោយធនាគារពិភពលោកតាមរយៈមូលនិធិបរធនបាលកិច្ច (Trust Fund)។<br>- បាននិងកំពុងបន្តអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចំនួន៣៧ ក្រុង ស្រុក ខណ្ឌ ស្មើនឹង ១៨% នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌសរុបចំនួន២០៩។<br>- សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាតិ និងអន្តរជាតិ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅខេត្តកំពត ដឹកនាំដោយ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ដែលមានការអញ្ជើញចូលរួមពី ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. តំណាងជាន់ខ្ពស់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ការជារីទូត និងតំណាងដៃគូអភិវឌ្ឍន៍មួយចំនួន។<br>- បានរៀបចំសេចក្តីសម្រេចកែសម្រួលសមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្រ្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស.)។<br>- បានរៀបចំសេចក្តីសម្រេចបង្កើតក្រុមការងារបច្ចេកទេសគណនេយ្យភាពសង្គម និងបានរៀបចំកិច្ចប្រជុំចំនួន០២លើកដើម្បីពិនិត្យ និងពិភាក្សាកែសម្រួលឯកសារបច្ចេកទេសពាក់ព័ន្ធ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | នឹងការងារគណនេយ្យភាពសង្គម។<br>- បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដល់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដែលមានសមាសភាពចូលរួមសរុបប្រមាណ២៧០រូប (ស្ត្រី៧៣រូប)។<br>- បានរៀបចំកែសម្រួល និងដាក់ឱ្យប្រើប្រាស់សៀវភៅប្រតិបត្តិការស្តីពីការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់។<br>- បានសហការសម្របសម្រួលក្នុងការរៀបចំបេសកកម្មគាំទ្រការអនុវត្តគម្រោងលើកទី៧ របស់ធនាគារពិភពលោក ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម។<br>- បានរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ដល់រដ្ឋបាលថ្នាក់ក្រោមជាតិតំបន់គោលដៅថ្មី។<br>- បានបោះពុម្ពប្រតិទិន និងទិនានុលេខន៍ឆ្នាំ២០២៤ សម្រាប់ចែកជូននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គម។<br>- បានសហការសម្របសម្រួល និងគាំទ្របច្ចេកទេសស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២ | **គម្រោង៖**<br>ការលើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (CSOs)<br>**គោលបំណង៖**<br>គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បី | ២០២៤-២០២៥ | មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក (គាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី USAID) | ៧.០៩ លានដុល្លារ | • អង្គការទស្សនៈពិភពលោក<br>• អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)<br>• អង្គការអុកស្វាមប្រចាំកម្ពុជា | - បាននិងកំពុងអនុវត្តនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន ១៣០ នៃរាជធានី ខេត្តចំនួន២០ ផ្តោតលើការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ចំនួន ១.១១២ សាលាបឋមសិក្សាចំនួន ៤.៨៦៨ និងមណ្ឌលសុខភាពចំនួន ៨៨០។<br>- បាននិងកំពុងអនុវត្តការងារគណនេយ្យភាពសង្គមលើសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៣០។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ធ្វើឱ្យប្រសើរឡើងតម្លាភាព ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | | | | | |
| ៣ | **គម្រោង៖**<br>កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD/GIZ)<br>**គោលបំណង៖**<br>គម្រោងមានគោលបំណងលើកកម្ពស់ការផ្តល់សេវាសាធារណៈដោយមានការចូលរួមពីប្រជាពលរដ្ឋ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ | ខែមីនា ឆ្នាំ ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៥ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (ជី អាយ ហ្សេត GIZ) កម្ពុជា | ៩.៨១៨.១៨២អឺរ៉ូ ស្មើនឹង ១០.៥២២.៣៦៥ ដុល្លារ | អនុវត្តដោយ ISD ក្រោមកិច្ចសហប្រតិបត្តិការ លេខាធិការដ្ឋាន គ.ជ.អ.ប. អគ្គនាយដ្ឋានរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន | - សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងរៀបចំកិច្ចប្រជុំដំបូងនៃក្រុមការងារសិក្សាជម្រើសសម្រាប់រៀបចំរដ្ឋបាលខេត្តជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ រដ្ឋបាលរាជធានីភ្នំពេញជារដ្ឋបាលមេត្រូប៉ូលីតែន<br>- គាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការរៀបចំកិច្ចប្រជុំប្រមូលជាតុចូល ដើម្បីកែសម្រួលយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ និងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រុមជាតិ<br>- បានជួយរៀបចំសេចក្តីព្រាងការពិពណ៌នាមុខតំណែងសម្រាប់ពិភាក្សាបន្តជាមួយក្រុមការងារអន្តរក្រសួង<br>- បាននិងកំពុងរៀបចំឯកសារទស្សនទានស្តីពីការសិក្សាវាយតម្លៃការអនុវត្តអនុក្រឹត្យលេខ ១៩៣ និងការសិក្សាជម្រើសសម្រាប់ការធ្វើប្រតិភូកម្មមុខងារសុខាភិបាលពីរដ្ឋបាលរាជធានីខេត្ត ទៅរដ្ឋបាលក្រុងស្រុកខណ្ឌ និងឃុំសង្កាត់<br>- គាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការសិក្សាទិន្នន័យដើមគ្រាវិស័យអប់រំ<br>- គាំទ្ររដ្ឋបាលក្រុងស្រុកគោលដៅក្នុងការកំណត់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ ដែលត្រូវផ្តល់តាមប្រព័ន្ធឌីជីថល និងគាំទ្រឧបករណ៍សម្ភារៈដល់រដ្ឋបាលស្រុកគោលដៅ (ចំនួន២) ក្នុងការផ្តល់សេវាចល័ត<br>- គាំទ្រក្រសួងមហាផ្ទៃ (នាយកដ្ឋានមុខងារ និងធនធាន) ក្នុងការរៀបចំដំឡើងម៉ាស៊ីនមេ (Server) និងផ្ទេរទិន្នន័យពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ការផ្តល់សេវាតាមប្រព័ន្ធឌីជីថល<br>- គាំទ្ររដ្ឋបាលក្រុងស្រុកគោលដៅទាំង៦ក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម និងសំណល់រឹង<br>- គាំទ្រក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃក្នុងការរៀបចំឯកសារ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | បច្ចេកទេសស្តីពីការរៀបចំផែនការគ្រប់គ្រងសំរាមសំណល់រឹងនៅថ្នាក់ក្រុងស្រុក<br>- គាំទ្ររដ្ឋបាលក្រុងស្រុកគោលដៅ (ចំនួន៤) ក្នុងការរៀបចំផែនការគ្រប់គ្រងទឹក<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្នុងភាពជាអ្នកដឹកនាំដល់អភិបាលនៃគណៈអភិបាល នាយក និងនាយករងរដ្ឋបាលក្រុង ស្រុកនៃខេត្តគោលដៅទាំងបី (បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ) ដោយមានអ្នកចូលរួមសរុបចំនួន ១០១រូប (ស្ត្រីចំនួន ៥០រូប)<br>- បានគាំទ្រដល់រដ្ឋបាលក្រុងស្រុកក្នុងការរៀបចំប្រជុំអនុគណៈកម្មការគ្រប់គ្រងសំរាម សំណល់រឹង និងអនុគណៈកម្មការគ្រប់គ្រងទឹក<br>- បានជួយគាំទ្រដល់រដ្ឋបាលក្រុង ស្រុក (ពិសេសការិយាល័យប្រជាពលរដ្ឋ) ក្នុងខេត្តគោលដៅទាំងបី ធ្វើការផ្សព្វផ្សាយអំពី App មតិយើង (ដែលជា App សម្រាប់ប្រជាពលរដ្ឋផ្តល់យោបល់ត្រលប់ពាក់ព័ន្ធការផ្តល់សេវា)<br>- បានគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំឯកសារបណ្តុះបណ្តាលសម្រាប់ក្រុមប្រឹក្សារដ្ឋបាលក្រុង ស្រុកតាមប្រព័ន្ធអនឡាញ<br>- បានគាំទ្ររដ្ឋបាលក្រុង ស្រុកក្នុងការគណនាចំណូលចំណាយសម្រាប់ការផ្តល់សេវារដ្ឋបាល (តាមរយៈការិយាល័យច្រកចេញចូលតែមួយ) |
| ៤ | **គម្រោង៖**<br>រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ "ពង្រីកការអនុវត្តមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាស | ២០២០-២០២២<br>ពន្យារការអនុវត្តដល់ឆ្នាំ២០២៤ | • UNCDF<br>• ក្រសួងបរិស្ថាន នៃសាធារណរដ្ឋកូរ៉េ | ៧៤៨.៤០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | - លេខាធិការដ្ឋាន គ.ជ.អ.ប. បានចាត់បញ្ជូនថ្នាក់ដឹកនាំ មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងវិស័យឯកជន ចំនួន១០រូប ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពលើការគ្រប់គ្រងការផ្គត់ផ្គង់ទឹក ធ្វើឡើងដោយ K-Water Academy |

| | | | | | | |
|---|---|---|---|---|---|---|
| | ជាតុនៅកម្ពុជា៖ នវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតធន់ទៅនឹងការប្រែប្រួលអាកាសធាតុតាមបែបវិមជ្ឈការ" (UNCDF/LGCC-WRP)<br>**គោលបំណង៖**<br>គាំទ្រដល់ការអនុវត្តមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងទឹកស្អាត កែលម្អបង្កើនសមត្ថភាពស្ថាប័ន និងការសម្របសម្រួលសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ទឹកស្អាតរបស់សហគមន៍មូលដ្ឋាន និងបង្កើនភាពធន់ និងសមត្ថភាពបន្សាំនៃជីវភាពរស់នៅតាមជនបទទៅនឹងផលប៉ះពាល់អាកាសធាតុ និងហានិភ័យលើធនធានទឹកនៅក្នុងតំបន់ងាយរងគ្រោះបំផុតចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ | | | | | កាលពីថ្ងៃទី១៩-២៨ ខែកុម្ភៈ ឆ្នាំ២០២៤ នៅប្រទេសកូរ៉េ<br>- បានទទួលដំណើរទស្សនកិច្ចរបស់ក្រុមការងារជំនាញទឹកស្អាតនៃប្រទេសកូរ៉េ (K-Water) ចំនួន២លើក ដើម្បីពិនិត្យ និងគាំទ្របច្ចេកទេសការផ្គត់ផ្គង់ទឹកស្អាតជូនអ្នកប្រើប្រាស់ក្នុងមូលដ្ឋាន<br>- បានគាំទ្រដល់ការរៀបចំគណៈកម្មការដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបានស័ក្តិ<br>- បានដំណើរការតភ្ជាប់បណ្តាញចែកចាយទឹកស្អាតជូនដល់ប្រជាពលរដ្ឋចំនួន៤៥៥ខ្នងផ្ទះដែលនៅជាប់បណ្តាញទុយោស្ថានីយទឹកស្អាតបានស័ក្តិ និងអតិថិជនដែលបានភ្ជាប់សេវាទឹកស្អាតប្រើប្រាស់ ៣៣៣ខ្នងផ្ទះ ស្មើនឹង ៧៥%<br>- ផ្តល់ការបណ្តុះបណ្តាលនូវគោលការណ៍ប្រតិបត្តិការ និងវិធីសាស្រ្តគ្រប់គ្រង និងថែទាំប្រព័ន្ធដំណើរការនានាដែលមាននៅក្នុងស្ថានីយ |
| ៥ | **គម្រោង៖**<br>ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA)<br>**គោលបំណង៖**<br>ដើម្បីបង្កើនការចូលរួម និងការទទួលយោបល់ត្រលប់របស់ប្រជាពលរដ្ឋការបំពេញការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការ | ២០២៣-២០២៥ | រាជរដ្ឋាភិបាលជប៉ុន តាមរយៈកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNDP) | .<br>៨៩៧.៧៥២ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | - អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា៖ កំពុងអនុវត្ត (កំពុងវាយតម្លៃជ្រើសរើសទីប្រឹក្សា និងកំពុងរៀបចំដេញថ្លៃ Savers ២គ្រឿង)<br>- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្សព្វផ្សាយព័ត៌មានក្រុងគោលដៅ៖ កំពុងអនុវត្ត (បានរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការសកម្មភាពក្រុងគោលដៅ និងកំពុងពិភាក្សាបញ្ចប់ជាមួយ UNDP)<br>- វាយតម្លៃកម្មវិធីជាតិដំណាក់កាលទី១៖ កំពុងអនុវត្ត (ការចុះប្រមូលព័ត៌មាន សម្រាប់វាយតម្លៃតាមខេត្តទាំង៦ នឹងចាប់ផ្តើមនៅសប្តាហ៍ទី២ ខែកក្កដា) |

| | | | | | | |
|---|---|---|---|---|---|---|
| | គាំទ្រការអនុវត្តគោលនយោបាយនៅថ្នាក់ជាតិ។ | | | | | - អង្កេតអភិបាលកិច្ច ២៥រាជធានី ខេត្តៈ កំពុងអនុវត្ត (កំពុងវាយតម្លៃជ្រើសរើសទីប្រឹក្សា)<br>- អង្កេតអភិបាលកិច្ចពាក់កណ្ដាលអាណត្តិកម្មវិធីជាតិដំណាក់កាលទី២ (១៣ រាជធានី ខេត្ត)ៈ មិនទាន់បានអនុវត្ត<br>- ទីប្រឹក្សាបច្ចេកទេសៈ កំពុងអនុវត្ត<br>- នៅក្នុងឆមាសទី១ បានចំណាយថវិកាចំនួន ៤៨.៦៧១,៨៧ ដុល្លារអាមេរិក |
| ៦ | **គម្រោងៈ**<br>អាហារូបត្ថម្ភនៅកម្ពុជា (CNP)<br>**គោលបំណងៈ**<br>ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងគុណភាពនៃសេវាសុខភាព និងអាហារូបត្ថម្ភជាអាទិភាពសម្រាប់មាតា និងកុមារសម្រាប់ក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជា។ | ២០១៩-២០២៦ | ធនាគារពិភពលោក (WB) និងអាល្លឺម៉ង់ | ១៧.៨០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | - បានវាយតម្លៃលទ្ធផលនៃការបំពេញការងារមូលនិធិគាំទ្រការផ្ដល់សេវាឃុំ សង្កាត់របស់រដ្ឋបាលឃុំ សង្កាត់ចំនួន ៣៦៥ និងរដ្ឋបាលក្រុង ស្រុកគោលដៅចំនួន៦០ នៃខេត្តគោលដៅចំនួន៩<br>- បានផ្ទេរមូលនិធិគាំទ្រការផ្ដល់សេវាឃុំ សង្កាត់សរុបចំនួន ១.៦២៣.៤៨២,៥១ដុល្លារអាមេរិក ក្នុងនោះចំនួន ១.៥២៤.១១៩,៤៥ដុល្លារអាមេរិកបានផ្ទេរទៅឱ្យរដ្ឋបាល ឃុំ សង្កាត់ចំនួន៣៦៥ និងចំនួន ៩៩,៣៦៣.០៦ដុល្លារអាមេរិកបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន ៦០<br>- បានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន ១៤វគ្គ ដែលមានសិក្ខាកាមចូលរួមមកពីរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់សរុបចំនួន ៤៩០រូប ក្នុងនោះមានស្ត្រីចំនួន ១៧០រូប។ (១) វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់ក្រុង ស្រុកស្ដីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្ដល់សេវាឃុំ សង្កាត់ចំនួន១វគ្គរយៈពេល៣ថ្ងៃដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៣០រូប ក្នុងនោះមានស្ត្រីចំនួន ១៥រូប (២) វគ្គបណ្ដុះបណ្ដាលស្ដីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្ដល់សេវាឃុំ សង្កាត់ចំនួន៦វគ្គរយៈពេល២ថ្ងៃក្នុងមួយវគ្គមានសិក្ខាកាមចូលរួមសរុបចំនួន២២០រូប ក្នុងនោះមានស្ត្រីចំនួន ៧៣រូប (៣) វគ្គបណ្ដុះបណ្ដាលស្ដីពីការហ្វឹកហ្វឺនសម្រាប់មូលនិធិគាំទ្រការផ្ដល់សេវាឃុំ សង្កាត់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ដល់អ្នកវាយតម្លៃនៃរដ្ឋបាលក្រុង ស្រុកគោលដៅចំនួន ០៣ វគ្គ រយៈពេល៣ថ្ងៃក្នុងមួយវគ្គៗមានសិក្ខាកាមចូលរួមសរុបចំនួន ៧៦រូប ក្នុងនោះមានស្ត្រីចំនួន ៤១រូប (៤) វគ្គបណ្តុះបណ្តាលអ្នកអនុវត្តសំខាន់ៗ ថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ចំនួន ៣វគ្គ រយៈពេល២ថ្ងៃ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១២២រូប ក្នុងនោះមានស្ត្រីចំនួន ២៤រូប និង (៥) វគ្គបណ្តុះបណ្តាលសេចក្តីណែនាំស្តីពីការវាយតម្លៃមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ និងអំពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការវាយតម្លៃចំនួន ១វគ្គ រយៈពេល៥ថ្ងៃ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤២រូប ក្នុងនោះមានស្ត្រីចំនួន ១៧រូប។<br>- បានរៀបចំពិធីប្រគល់ និងទទួលរថយន្តហ្វដ Ford pick-up ចំនួន៩គ្រឿងដល់រដ្ឋបាលខេត្តគោលដៅនៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជាទាំង៩ មានខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តកោះកុងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តគម្រោង។ |
| **សំណើគម្រោងថ្មី** | | | | | | |
| ១ | **គម្រោង៖**<br>រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុជំហានទី៣ (LGCC-III) | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNCDF | - ស្ថិតនៅក្នុងដំណាក់កាលរៀបចំសំណើគម្រោងពេញលេញ (Full Proposal) ដោយប្រើថវិការបស់ GCF PPF<br>- ក្រុមការងារបានពិភាក្សាជាមួយ UNCDF ដើម្បីពន្លឿនការរៀបចំសៀវភៅប្រតិបត្តិការ និងផែនការអនុវត្ត និងថវិកា និងផែនការលទ្ធកម្ម។ ជាលទ្ធផលនៃកិច្ចប្រជុំ ទីប្រឹក្សា eco នឹងបញ្ចប់ការរៀបចំសៀវភៅប្រតិបត្តិការ និងផែនការអនុវត្ត និងថវិកា និងផែនការលទ្ធកម្មត្រឹមដំណាច់ខែមិថុនា ឆ្នាំ ២០២៤។ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | **គម្រោង៖**<br>Readiness KHM-RS-011 ស្តីពីការអភិវឌ្ឍហិរញ្ញប្បទានអាកាសធាតុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា<br>**គោលបំណង៖**<br>ដើម្បីសិក្សានិងរៀបចំនូវក្របខ័ណ្ឌនិងយន្តការសម្រាប់ការវិនិយោគលើសកម្មភាពប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ដោយបន្សុីជាមួយសកម្មភាពបន្សាំជាតិ គោលនយោបាយប្រែប្រួលអាកាសធាតុរបស់ក្រសួងបរិស្ថាន និងមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ឆ្នាំ | GCF | ៤៤១.៤៦០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNCDF | - លេខាធិការដ្ឋាន គ.ជ.អ.ប. បានទទួលការអនុម័តពី GCF លើកម្មវិធី Readiness KHM-RS-011 នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៤<br>- បានបញ្ចប់លើការរៀបចំកិច្ចព្រមព្រៀងហិរញ្ញវត្ថុរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង UNOPS។ កិច្ចព្រមព្រៀងនេះក្រុមការងារគ្រោងស្នើសុំលទ្ធភាពពីឯកឧត្តមប្រធានក្នុងការចុះហត្ថលេខា។<br>- បានរៀបចំសិទ្ធិប្រទានពីអគ្គសេនាបតី ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធាន គ.ជ.អ.ប. ជូនឯកឧត្តម ចាន់ សុធា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.<br>- បានរៀបចំសេចក្តីព្រាងកិច្ចសន្យា (Sub Grant Agreement) ជាមួយអង្គការ UNCDF |
| ៣ | **គម្រោង៖**<br>សេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងរណបអាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត (CR-Wash) | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង GGGI | ស្ថិតនៅក្នុងដំណាក់កាលរៀបចំឯកសារទស្សនទានគម្រោង (Concept Note)៖<br>- បានឯកភាព និងអនុម័តលើការពន្យារពេលបញ្ចប់កិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង GGGI រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤<br>- បានបញ្ជូនលិខិតស្នើសុំកិច្ចប្រជុំជាមួយមូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា (KECF)។ លទ្ធផលស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជានឹងផ្តល់កាលបរិច្ឆេទនៅពេលជាក់លាក់ណាមួយលើកិច្ចប្រជុំ។ |
| ៤ | **គម្រោង៖**<br>ការធ្វើឱ្យប្រសើរឡើងនូវកសិកម្មអេកូឡូស៊ីដែលងាយរងគ្រោះដោយសារ | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNDP | ស្ថិតនៅក្នុងដំណាក់កាលរៀបចំឯកសារទស្សនទានគម្រោង (Concept Note)៖<br>- បានប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីកសិកម្ម និងនីតិកម្ម |

| | | | | | | |
|---|---|---|---|---|---|---|
| | អាកាសធាតុនៅតំបន់ខ្ពង់រាប (Agroecological transitions) | | | | | របស់ **GCF** លើការស្នើសុំសម្របសម្រួលលើលក្ខខណ្ឌពិសេសសម្រាប់កិច្ចសន្យារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង UNDP។ ជាលទ្ធផលនៃកិច្ចប្រជុំនេះមន្ត្រីនីតិកម្មរបស់ GCF បានផ្តល់អនុសាសន៍លើការរៀបចំពិសេសសម្រាប់កិច្ចសន្យារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងUNDP សម្រាប់តែគម្រោងមួយនេះទេ ដោយយោងគោលនយោបាយហិរញ្ញវត្ថុរបស់ UNDP តម្រូវឱ្យមានលក្ខខណ្ឌពិសេសនេះក្នុងការរាយការណ៍ជារបាយការណ៍ហិរញ្ញវត្ថុឱ្យស្របលើគោលការណ៍ Single Audit Principles<br>- បានស្នើសុំកិច្ចប្រជុំជាមួយធនាគារពិភពលោកនៅក្នុងខែមិថុនា ឆ្នាំ២០២៤។ ធនាគារពិភពលោកយល់ព្រមតាមការស្នើសុំជួប គឺនៅសប្តាហ៍ទី២នៃខែមិថុនា ឆ្នាំ២០២៤<br>- លោក Shakeel Deputy Resident of UNDP បានស្នើសុំជំនួបពិភាក្សាលើឯកសារទស្សនទានគម្រោង (Concept Note)។ លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលយកសំណើនេះនឹងពិចារណារកពេល ដើម្បីពិភាក្សាការងារនេះ<br>- បានរៀបចំសេចក្តីព្រាងសំណើគម្រោងសម្របសម្រួលក្នុងការរៀបចំគម្រោង (**PPF**)។ |
| ៥ | **គម្រោង៖**<br>ពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាល II (**EmPower II**) | ២ឆ្នាំ | UNEP | ១៦១.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | - បានរៀបចំសេចក្តីព្រាងកិច្ចសន្យាហិរញ្ញប្បទានរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង **UNEP**។ កិច្ចសន្យានេះគ្រោងនឹងអនុម័តនៅសប្តាហ៍ទី២ នៃខែមិថុនា ឆ្នាំ២០២៤<br>- គ្រោងនឹងចុះទស្សនកិច្ចលើការងារគម្រោងជាមួយតំណាង SIDA (Sweden), SDG, UNEP **និង** UN-Women នៅខេត្តតាកែវ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤។ |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | **គម្រោង៖**<br>ការពង្រឹងប្រព័ន្ធយន្តការបង្ការ និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅប្រទេសកម្ពុជា | ៥ឆ្នាំ | ADB | ៧លានដុល្លារ | ក្រសួងកិច្ចការនារី<br>ក្រសួងមហាផ្ទៃ<br>និងលេខាធិការដ្ឋាន<br>គ.ជ.អ.ប. | – រៀបចំសេចក្តីព្រាងអនុសារណៈយោគយល់រវាង ADB និងក្រសួងកិច្ចការនារី |

## ១៦. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

- បាននិងកំពុងអនុវត្តនូវគម្រោងអាហារូបត្ថម្ភនៅកម្ពុជា (CNP) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងគុណភាពនៃសេវាសុខភាព និងអាហារូបត្ថម្ភជាអាទិភាពសម្រាប់មាតា និងកុមារសម្រាប់ក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជា
- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទាន ស្តីពីការអនុវត្តសាកល្បងនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការបន្តការអនុវត្តការងារគណនេយ្យភាពសង្គមបន្ទាប់ពីគម្រោងគណនេយ្យភាពសង្គមគាំទ្រដោយដៃគូអភិវឌ្ឍន៍ត្រូវបានបញ្ចប់
- កំពុងរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងក្រុង ស្រុកគោលដៅចំនួន០៦ ដើម្បីធានាដល់ការប្រមូល/កៀរគរចំណូលសម្រាប់រ៉ាប់រងចំណាយលើការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជននៅថ្នាក់ក្រុង ស្រុក
- កំពុងរៀបចំយុទ្ធសាស្ត្រស្តីពីការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយក្នុងក្រុង ស្រុកគោលដៅ**ចំនួន០២** ដើម្បីធានាដល់ការប្រមូល/កៀរគរចំណូលសម្រាប់រ៉ាប់រងចំណាយលើការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រុង ស្រុក។

## ១៧. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

- បាននិងកំពុងដំណើរការរៀបចំវាយតម្លៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ (២០១០-២០២០) ធ្វើឡើងដោយក្រុមទីប្រឹក្សាឯករាជ្យ ក្រោមការគាំទ្រហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈគម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA) ដែលសម្រេចបានលទ្ធផល រួមមាន (១) បានបញ្ចប់ការរៀបចំរបាយការណ៍ចាប់ផ្តើមដំបូង (២) បានរៀបចំចងក្រងបញ្ជីសំណួរ និងផែនការសកម្មភាពសម្រាប់ការវាយតម្លៃ (៣) បាននិងកំពុងចុះប្រមូលព័ត៌មាន និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានានៃស្ថាប័នសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋទៅលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១
- បាននិងកំពុងដំណើរការរៀបចំការអង្កេតអភិបាលកិច្ច ដែលត្រូវអនុវត្តដោយក្រុមហ៊ុនឯករាជ្យក្រោមការគាំទ្រហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈគម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA) ដែលកំពុងដំណើរការវាយតម្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា សម្រាប់ធ្វើការអង្កេតអភិបាលកិច្ច និងត្រៀមរៀបចំផ្តល់កិច្ចសន្យាដែលចាប់ផ្តើមអនុវត្តនៅដើមត្រីមាសទី៣ឆ្នាំ២០២៤ គ្របដណ្តប់ទូទាំង២៥រាជធានី ខេត្ត។

**១៨. រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា**

- ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ក្រសួងឡើងវិញស្របតាមរចនាសម្ព័ន្ធ និងមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤)
- បានពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យស្របទៅតាមតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្តល់ដោយច្បាប់រៀបចំអង្គការ និងគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ។

**១៩. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ច រួមមានកិច្ចប្រជុំក្រុមប្រឹក្សាជាតិ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ និងកិច្ចប្រជុំថ្នាក់ដឹកនាំ ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចដំណើរការរបស់សមាគម
- រៀបចំឯកសារទស្សនទានស្តីពីការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាឱ្យសមាគមទាំងនេះកាន់តែមានសមត្ថភាពក្នុងការចូលរួមលើកកម្ពស់កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សមាគមបានរៀបចំទីស្នាក់ការថ្មីរបស់សមាគម ដោយរដ្ឋបាលរាជធានីបានប្រគល់ដីមួយកន្លែងមានទំហំប្រមាណ៤.០០០ម៉ែត្រការ៉េ ស្ថិតនៅសហគមន៍អណ្តូង៣ និងអណ្តូង៥ ភូមិអណ្តូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញសម្រាប់ធ្វើជាទីស្នាក់ការរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់រាជធានីភ្នំពេញ។ បច្ចុប្បន្ននេះ សមាគមកំពុងកៀរគរថវិកា ដើម្បីសាងសង់អគារទីស្នាក់ការថ្មីរបស់សមាគម
- សមាគមបានត្រៀមរៀបចំមហាសន្និបាតលើកទី៣របស់សមាគម ដោយផ្អែកតាមលក្ខន្តិកៈសមាគមត្រូវរៀបចំមហាសន្និបាតរៀងរាល់ប្រាំឆ្នាំម្តង ដើម្បីបោះឆ្នោតជ្រើសរើសអង្គអភិបាលកិច្ច ក៏ដូចជាអនុម័តឯកសារចាំបាច់ផ្សេងៗ
- រៀបចំដំណើរការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សានៅខេត្តគោលដៅ គឺខេត្តកំពត និងខេត្តសៀមរាបអំពីការត្រៀមបម្រុងការឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព ដោយមានការចូលរួមពីថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន សមាជិកក្រុមប្រឹក្សាខេត្តកំពត ខេត្តសៀមរាប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់មួយចំនួននៅខេត្តកំពត និងខេត្តសៀមរាប និងបានរៀបចំវគ្គបណ្តុះបណ្តាលជូនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ប្រមាណ២០វគ្គ។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណង

បង្កើនសមត្ថភាពសមាជិកក្រុមប្រឹក្សា ដើម្បីឈ្វេងយល់កាន់តែស៊ីជម្រៅលើការអនុវត្តតួនាទី ការគ្រប់គ្រង និងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព

- ចូលរួមនៅក្នុងកិច្ចប្រជុំផ្សេងៗដែលរៀបចំដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ក្រុមប្រឹក្សាជាសមាជិក
- សមាគមបានធ្វើការផ្សព្វផ្សាយលិខិតបទដ្ឋានមួយចំនួន រួមមាន (១) ច្បាប់ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិខេត្ត ក្រុង (២) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (៣) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (៤) ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (៥) ច្បាប់ស្តីពីសវនកម្ម និង (៦) សេចក្តីណែនាំស្តីពីការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈ និងលិខិតបទដ្ឋានផ្សេងទៀត
- សមាគមបានសហការជាមួយអង្គភាពពាក់ព័ន្ធនៅរដ្ឋបាលរាជធានី ខេត្ត ក្នុងការចុះផ្តល់ការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ជាសមាជិកចំនួន **៥១ឃុំ សង្កាត់** ក្នុងគោលបំណង ដើម្បីបង្កាត់បង្ហាញការចែករំលែកបទពិសោធការងារគ្រប់គ្រងគម្រោង ការដឹកនាំចាត់ចែង ការដោះស្រាយបញ្ហាផ្សេងៗដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យកាន់តែមានសមត្ថភាពប្រសើរឡើងក្នុងការអនុវត្តមុខងារ តួនាទីនៅមូលដ្ឋានដែលអាចឆ្លើយតបការផ្តល់សេវាជូនប្រជាពលរដ្ឋកាន់តែមានប្រសិទ្ធភាព។
- អនុវត្តគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រតិដ្ឋរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន (PMI-WILL) ដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលនៃប្រទេសកាណាដាតាមរយៈសហព័ន្ធទីក្រុងនៃប្រទេសកាណាដា កំពុងអនុវត្តចាប់ពីឆ្នាំ២០២១-២០២៦ នៅក្នុងក្រុង ស្រុកចំនួន៥ គឺក្រុងកែប ស្រុកទឹកឈូ ស្រុករលាប្អៀរ ស្រុកក្រឡាញ់ និងស្រុកមេសាង និងគាំទ្រគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមាររបស់សម្ព័ន្ធភាពជាតិ ក្នុងគោលបំណង ដើម្បី (១) ការកែលម្អសុខភាពមាតា និងទារក (២) ការចិញ្ចឹមកូនជាវិជ្ជមាននៅក្នុងសហគមន៍ងាយរងគ្រោះនៅស្រុកមេសាង ខេត្តព្រៃវែង (៣) ការលើកកម្ពស់អនាម័យ និងការប្រើប្រាស់ទឹកស្អាតសម្រាប់ប្រជាជន និង (៤) សេវាគ្រប់គ្រងសំណល់រឹងប្រកបដោយប្រសិទ្ធភាពនៅក្រុងកែប និងស្រុកទឹកឈូ។

**២០. ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

- បាននឹងកំពុងរៀបចំឯកសារទស្សនទាន និងផែនការសកម្មភាព ព្រមទាំងការកៀរគរការគាំទ្រសម្រាប់ការសិក្សាអំពីជម្រើសនៃការរៀបចំរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**២១. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធ និងកំណែទម្រង់**

- បានសហការជាមួយអង្គការសម្ព័ន្ធភាពដៃគូ ដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងការរៀបចំកិច្ចសន្ទនាថ្នាក់ជាតិស្តីពីការវិភាជថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការកំណត់នូវអនុសាសន៍សម្រាប់ការកែលម្អ

គោលនយោបាយ លិខិតបទដ្ឋាន និងគោលការណ៍នានាពាក់ព័ន្ធទៅនឹងការវិភាជថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីតំណាងស្ថាប័ននីតិបញ្ញត្តិ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តំណាងស្ថានទូតមួយចំនួន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

- បានគាំទ្រ និងសហការជាមួយអង្គការសង្គមស៊ីវិលចំនួន ១៩ ក្នុងការរៀបចំ និងអនុវត្តការងារគណនេយ្យភាពសង្គម ព្រមទាំងរៀបចំឱ្យមានវេទិកាពិគ្រោះយោបល់ទៅលើប្រសិទ្ធភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្តល់អនុសាសន៍សម្រាប់ការកែលម្អ និងការឈានទៅរៀបចំផែនការអនុវត្តជំហានបន្តបន្ទាប់ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

## ខ. សមាសភាគទី២ ÷ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី២នេះ រួមមានសកម្មភាពជាអាទិភាពចំនួន ១៩ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន ១៥ ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក

- បានផ្តល់ការគាំទ្រ និងពង្រឹងការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយសម្រេចបាននូវលទ្ធផល រួមមាន (១) ការរៀបចំដាក់ចេញនូវសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ (២) បានផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលមានសិក្ខាកាមចូលរួមចំនួន ៩៦៨រូប (ស្ត្រីចំនួន១៣១រូប) (៣) ក្រសួងអប់រំ យុវជន និងកីឡាបានផ្ទេរបុគ្គលិកគ្រូបង្រៀនសាលាបឋមសិក្សាសាធារណៈ សាលាមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ប្រមាណជិត ៦០.០០០នាក់ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (៤) បានរៀបចំបញ្ចប់សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការតែងតាំងនាយក នាយិកា នាយករង នាយិការងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ និងកំពុងដំណើរការពិនិត្យពិភាក្សា ដែលសម្របសម្រួលដោយក្រសួងមុខងារសាធារណៈ (៥) បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យានៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ (៦) បានរៀបចំប្រមូល និងចងក្រងទិន្នន័យដើមគ្រាក្នុងវិស័យអប់រំ យុវជន និងកីឡានៅតាមក្រុង ស្រុកចំនួន ៣១ នៃរាជធានី ខេត្តចំនួន ៦ ដូចជារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តស្វាយរៀង និងខេត្តមណ្ឌលគិរី (៧) បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ និងការផ្តល់គោលការណ៍ណែនាំបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមុខងារ

អប់រំដែលបានផ្ទេរ (៨) បានផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស អំពីការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៥ របស់ការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សា មត្តេយ្យសិក្សា និងមជ្ឈមណ្ឌលក្រៅប្រព័ន្ធ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា

- ក្រសួងសាធារណការ និងដឹកជញ្ជូនបានចុះត្រួតពិនិត្យវាយតម្លៃលើមុខងារដែលបានផ្ទេរពាក់ព័ន្ធនឹងការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក នៅខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប ខេត្តតាកែវ ខេត្តកណ្តាល និងខេត្តស្វាយរៀង មានសមាសភាពចូលរួមសរុប ៤០៨រូប ស្រី៨១រូប ព្រមទាំងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រង និងការផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកដល់មន្ត្រីអនុវត្តមុខងារនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ នៅខេត្តត្បូងឃ្មុំ ដោយមានអ្នកចូលរួមសរុបចំនួន២៧៣រូប ដែលជាថ្នាក់ដឹកនាំរដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ត្រីបច្ចេកទេសនៃអង្គភាពច្រកចេញចូលតែមួយខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ព្រមទាំងមន្ត្រីការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុកទាំង៨នេះផងដែរ
- ក្រសួងបរិស្ថានបានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីរៀបចំកម្រងសេវារដ្ឋបាលក្នុងវិស័យបរិស្ថាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ តាមរយៈសេចក្តីសម្រេចលេខ៨៤៥/សសរ ប.ស្ថ/អគព ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤។ ក្រុមការងារអន្តរក្រសួងនេះបានរៀបចំកិច្ចប្រជុំលើកទី១របស់ខ្លួន ដើម្បីពិនិត្យ និងពិភាក្សាអំពីបច្ចេកទេស និងវិធីសាស្ត្រគណនាតម្លៃសេវាសម្រាប់រៀបចំកម្រងសេវារដ្ឋបាលក្នុងវិស័យបរិស្ថាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បានគាំទ្រដល់ក្រុង ស្រុកក្នុងការអនុវត្តការងាររៀបចំផែនការក្រុង ស្រុក ការរៀបចំគម្រោងក្រុង ស្រុក ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារក្រុង ស្រុក និងការរៀបចំគោលនយោបាយគាំទ្រនានា
- បានប្រជុំផ្សព្វផ្សាយផ្តល់ការណែនាំ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

**២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់**

- បានផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការផ្ទេរធនធានពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលឃុំ សង្កាត់ សម្រាប់បំពេញមុខងាររបស់ខ្លួន រួមមាន (១) បានផ្ទេរធនធានថវិកាពីមូលនិធិឃុំ សង្កាត់ជូនរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសសរុបទាំងពីរត្រីមាសមានចំនួន **៤៤៧.៣៦០ លានរៀល** (២) ការផ្ទេរ

ធនធានបន្ថែមពីថវិការដ្ឋទៅឱ្យរដ្ឋបាលឃុំ សង្កាត់សរុបទាំងពីរត្រីមាសមាន**ចំនួន ១២៧.៨២២ លានរៀល**

- បាននិងកំពុងពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM) ឱ្យស្របទៅតាមស្ថានភាពនៃការវិវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបាន និងកំពុងរៀបចំសេចក្តីព្រាងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ
- បានផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព ការគាំទ្របច្ចេកទេស ធនធានហិរញ្ញវត្ថុ និងផ្តល់សម្ភារៈផ្សព្វផ្សាយ (I4C) ដល់រដ្ឋបាលឃុំ សង្កាត់ចំនួន១.៥៤៥ ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់សិទ្ធិអំណាច និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- រដ្ឋបាលរាជធានី ខេត្តបានផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២៦) និងការសិក្សាលទ្ធភាពគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៤
- បានប្រជុំផ្សព្វផ្សាយ ផ្តល់ការណែនាំ និងគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
- បានចុះតាមដានត្រួតពិនិត្យ គាំទ្រ និងសិក្សាស្រាវជ្រាវអំពីការអនុវត្តមុខងារ ការគ្រប់គ្រងថវិកា ការរៀបចំនិងការអនុវត្តគម្រោង និងកិច្ចដំណើរការលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ចំនួន៣លើក នៅក្នុងខេត្តកំពង់ចាម ខេត្តកណ្តាល និងរាជធានីភ្នំពេញ។

### ៣. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត

- បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត និងបានពិនិត្យពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានកំណត់អំពីផែនការសកម្មភាពសម្រាប់ការសិក្សាស្រាវជ្រាវអំពីជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត
- បានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធមុខងារ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត តាមសេចក្តីសម្រេចលេខ០១ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤
- បានប្រមូលចងក្រងនូវលិខិតបទដ្ឋានគតិយុត្ត និងឯកសារមេរៀនបទពិសោធអំពីការគ្រប់គ្រងរដ្ឋបាលខេត្តពីបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសថៃស្តីពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់តំបន់

- បានរៀបចំផែនការ និងដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធនៅប្រទេសឥណ្ឌូនេស៊ីដែលគ្រោងធ្វើឡើងនៅត្រីមាសទី១ ឆ្នាំ២០២៥ ដោយមានការគាំទ្រពីគម្រោង GIZ/ISD ក្រោមហិរញ្ញប្បទានពីប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស
- បានរៀបចំដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន ១៩រូប នៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ដែលបានគាំទ្រដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) និង GIZ។ ដំណើរទស្សនកិច្ចសិក្សានេះដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដើម្បីសិក្សាឈ្វេងយល់អំពីមេរៀន និងពិសោធន៍ល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចនៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ព្រមទាំងពង្រឹងនិងពង្រីកទំនាក់ទំនងរវាងកម្ពុជា និងស្វីសក្នុងកិច្ចសហប្រតិបត្តិការនាពេលអនាគត។

**៤. ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី ខេត្ត**

- បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានា សម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី និងបានពិនិត្យពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានកំណត់អំពីផែនការសកម្មភាពសម្រាប់ការសិក្សាស្រាវជ្រាវអំពីជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី
- បានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត តាមសេចក្តីសម្រេចលេខ០១ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤
- បានប្រមូលចងក្រងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារមេរៀនបទពិសោធអំពីការគ្រប់គ្រងរដ្ឋបាលទីក្រុងមេត្រូប៉ូលីតែនពីបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន សាធារណរដ្ឋកូរ៉េ និងប្រទេសថៃស្តីពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលមេត្រូប៉ូលីតែន។

**៥. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ**

- បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណង ដើម្បីពង្រឹងទំនាក់ទំនង គណនេយ្យភាព និងការទទួលខុសត្រូវរវាងក្រុមប្រឹក្សា និងគណៈអភិបាល ការពិភាក្សានិងការផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចចិត្តនានា ការដឹកនាំសម្របសម្រួល ព្រមទាំងការកំណត់នូវបញ្ហាប្រឈម និងអនុសាសន៍សម្រាប់លើកសំណើកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ដឹកនាំ អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រួមមាន ការគ្រប់គ្រងកម្រិត១ វិក្រឹត្យការមូលដ្ឋានជំនាន់ទី៨ ការអប់រំភាពជាអ្នកដឹកនាំ ការលើកកម្ពស់សមធម៌ និងបរិយាបន្នសង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៦. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ**

- បាននិងកំពុងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA/MIS) ដែលអនុវត្តដោយក្រុមហ៊ុនជំនាញ ក្រោមការគាំទ្រហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុនតាមរយៈគម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA)។ ប្រព័ន្ធគ្រប់គ្រងព័ត៌មាននេះ មានគោលបំណងផ្តល់ព័ត៌មាននានា និងទទួលមតិយោបល់ត្រលប់អំពីការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដែលនឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលក្រុងគោលដៅចំនួន៣គឺ ក្រុងបានលុងនៃខេត្តរតនគិរី ក្រុងសៀមរាបនៃខេត្តសៀមរាប និងក្រុងកំពង់ចាមនៃខេត្តកំពង់ចាម
- រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ បានរៀបចំវេទិកាសាធារណៈដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារ ការផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបំពេញតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងការពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**៧. ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

- បាននិងកំពុងរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**៨. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ**

- បាននិងកំពុងបន្តអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលឃុំ សង្កាត់**ចំនួន ១.៥៤៥ ឃុំ សង្កាត់ ស្មើនឹង ៩៣%** នៃចំនួនឃុំ សង្កាត់**សរុប ១.៦៥២** និងការអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ**ចំនួន ៣៧ ស្មើនឹង ១៨%** នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌសរុប**ចំនួន ២០៩** ដោយទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលអូស្ត្រាលី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ក្រោមការសម្របសម្រួលដោយធនាគារពិភពលោកតាមរយៈមូលនិធិបរធនបាលកិច្ច (Trust Fund)
- បានបោះពុម្ពប្រតិទិន និងបណ្ណព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ស្តីពីការងារគណនេយ្យភាពសង្គមចំនួន ១៣.៣៦២ និងបានចែកជូនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គោលដៅទាំងអស់ ព្រមទាំងបានពិនិត្យ និងកែសម្រួលសូចនាករផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងលើកទិសដៅនៃការអនុវត្តការងារគណនេយ្យភាពសង្គមលើសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ

ដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ធនាគារពិភពលោក និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ

- បានរៀបចំវគ្គបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រូបង្គោលថ្នាក់ខេត្ត អំពីការងារគណនេយ្យភាពសង្គមចំនួន ០២វគ្គ ចាប់ពីថ្ងៃទី១៣ ដល់ ១៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅខេត្តបាត់ដំបង និងខេត្តសៀមរាប ដែលមានសមាសភាពចូលរួមពីខេត្តបាត់ដំបង កំពង់ចាម កំពត ប៉ៃលិន ឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ និងក្រុង ស្រុកគោលដៅថ្មីចំនួន ១៤ រួមមានស្រុកស្រីសន្ធរ ក្រុងកំពង់ចាម ស្រុកអង្គរជ័យ ស្រុកជុំគិរី ក្រុងបូកគោ ស្រុកសាលាក្រៅ ក្រុងប៉ៃលិន ស្រុកចុងកាល់ ស្រុកអន្លង់វែង ស្រុកបន្ទាយអំពិល ស្រុកត្រពាំងប្រាសាទ ក្រុងសំរោង ស្រុកក្រូចឆ្មារ និងក្រុងសួង សរុបចំនួន ១២៧រូប ស្ត្រីចំនួន៣៣រូប និងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធគណនេយ្យ (Sage 50) និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ការងារគណនេយ្យភាពសង្គម ដោយមានការចូលរួមពីមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុគម្រោងនៃខេត្ត និងក្រុង ស្រុកគោលដៅថ្មី
- បានរៀបចំដំណើរទស្សនកិច្ចការងារគណនេយ្យភាពសង្គមរបស់គណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ ដែលដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដោយមានសមាសភាពចូលរួមចំនួន២៣រូប និងមានការចូលរួមពីស្ថានទូតអូស្ត្រាលី ស្ថានទូតអាល្លឺម៉ង់ ធនាគារពិភពលោក តំណាង GIZ/ISD និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) ទៅកាន់ខេត្តកំពតដែលការងារគណនេយ្យភាពសង្គមនេះ ជាផ្នែកដ៏សំខាន់មួយនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជានាដល់ការលើកកម្ពស់ការប្រាស្រ័យទាក់ទងគ្នារវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងកិច្ចដំណើរការអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន
- បានរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសស្តីពីការបន្តអនុវត្ត និងពង្រីកការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**៩. ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ**

- បានផ្តល់ការគាំទ្រ និងពង្រឹងកិច្ចដំណើរការនៃការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ តាមរយៈ (១) ការពិនិត្យកែសម្រួល និងធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង និងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋជាមួយកម្មវិធីទូរសព្ទដៃ (មតិយើង) (២) បាននិងកំពុងកែសម្រួលសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត (៣) បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងការប្រកាសជ័យលាភីការិយាល័យប្រជាពលរដ្ឋឆ្នើមប្រចាំឆ្នាំ២០២៣ (៤) បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលផុតអាណត្តិការងារ ទទួលមរណភាព និងលាលែងពីមុខតំណែង

- ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន ៨១១ **ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ច**ចំនួន ២២២ ករណី** (បញ្ចប់ការដោះស្រាយ **ចំនួន ១២៨ ករណី ស្មើនឹង ៥៧%** និងកំពុងដោះស្រាយចំនួន**៩៤ករណី**)។ បណ្តឹងក្រៅសមត្ថកិច្ច **ចំនួន ២១០ ករណី** និងព័ត៌មានផ្សេងៗចំនួន **៣៧៩ ករណី** (ការសរសើរចំនួន **៩២ ករណី** សំណើនិងសំណូមពរ**ចំនួន ១២៤ ករណី** និងការសាកសួរព័ត៌មាន**ចំនួន ១៦៣ ករណី**)




- **ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗ**ពីប្រជាពលរដ្ឋបានចំនួន**សរុប ១២.៩៣៨ ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ច**ចំនួន ២២៥ ករណី** (បញ្ចប់ការដោះស្រាយចំនួន **១១៨ ករណី ស្មើនឹង ៥២%** កំពុងដំណើរការចំនួន**១០៧ករណី**) **បណ្តឹងក្រៅ**សមត្ថកិច្ច**ចំនួន ១២២ ករណី** ព័ត៌មានផ្សេងៗសរុប**ចំនួន ១២.៥៩១ ករណី** (ការសរសើរចំនួន **៣៥៤ ករណី** សំណើ និងសំណូមពរ**ចំនួន ២.០៨៨ ករណី** និងការសាកសួរព័ត៌មានចំនួន **១០.១៤៩ ករណី**)។




**១០. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ**

- បានផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលមួយចំនួនក្នុងការចូលរួមគាំទ្រ និងអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការងារគណនេយ្យភាពសង្គមដែលបច្ចុប្បន្នរួមមានអង្គការសង្គមស៊ីវិលចំនួន១៩ បានបំពេញតួនាទីជាផ្នែក

តម្រូវការ ក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលក្នុងដាក់ពិន្ទុវាយតម្លៃការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវា

- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវេទិកាសាធារណៈ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ដើម្បីផ្សព្វផ្សាយ និងប្រមូលនូវមតិយោបល់ សំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលវេលា។

**១១. ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត**

- គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ រដ្ឋបាលថ្នាក់ក្រោមជាតិ**ចំនួន %** មានលទ្ធភាពប្រើប្រាស់សេវាអ៊ីនធឺណិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១២. ការរៀបចំនិងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលនៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បានធ្វើបច្ចុប្បន្នភាពទៅលើប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ប្រព័ន្ធគ្រប់គ្រងគម្រោងថ្នាក់ក្រោមជាតិ (PID) និងប្រព័ន្ធតាមដានការអនុវត្តផែនការថវិកាប្រចាំឆ្នាំ (NAD) របស់ គ.ជ.អ.ប. ព្រមទាំងបានធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងបណ្ណាល័យអេឡិចត្រូនិក (E-Library) របស់ គ.ជ.អ.ប.
- កំពុងដំណើរការអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស
- បាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញនៅថ្នាក់រាជធានី ខេត្តចំនួន ១២ លើប្រភេទសេវារដ្ឋបាលចំនួន ១១៧ ក្នុងវិស័យចំនួន៤ រួមមាន វិស័យទេសចរណ៍ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងដាក់ឱ្យអនុវត្តនូវប្រព័ន្ធទូទាត់តាមវិក្កយបត្រ (Payment Hub) នៅថ្នាក់រាជធានី ខេត្តទាំង២៥ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បាន និងកំពុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងរៀបចំប្រព័ន្ធគ្រប់គ្រងការសិក្សាអនឡាញនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សាលាជាតិរដ្ឋបាលមូលដ្ឋានបានផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលចំនួនពីរ (១) មជ្ឈមណ្ឌលអភិវឌ្ឍន៍មូលដ្ឋានដោយចីរភាព (២) មជ្ឈមណ្ឌលបណ្តុះបណ្តាលនវានុវត្តន៍ និងធ្វើឌីជីថលនីយកម្មប្រព័ន្ធគ្រប់គ្រងសាលា (MIS)
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីរបាយការណ៍សិក្សាគំរូស្តង់ដា និងការពង្រីកវិសាលភាពរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានការអញ្ជើញចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តចំនួន ០៤ ក្រុង ស្រុកចំនួន ០៨។

**១៣. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

- បាននិងកំពុងរៀបចំជ្រើសរើសទីប្រឹក្សាព័ត៌មានវិទ្យារយៈពេលខ្លី តាមរយៈគម្រោងគណនេយ្យភាព

សង្គម ដើម្បីធ្វើបច្ចុប្បន្នភាពមុខងារកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម លើប្រព័ន្ធប្រតិបត្តិការ IOS និង Android ដើម្បីឱ្យសាធារណជនកាន់តែងាយស្រួលប្រើប្រាស់ និងទទួលបានព័ត៌មានត្រលប់ពីប្រជាពលរដ្ឋទៅលើការផ្តល់សេវារបស់អង្គភាពផ្តល់សេវា

- រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដើម្បីលើកកម្ពស់ និងផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងការងារ ការផ្សព្វផ្សាយព័ត៌មាន ការផ្តល់យោបល់ត្រលប់ ការផ្តល់សេវារដ្ឋបាល និងការអនុវត្តភារកិច្ចរបស់ខ្លួនតាមរយៈប្រព័ន្ធ Facebook, Telegram, Website..ជាដើម។ ព័ត៌មានសំខាន់ៗដែលបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋរួមមានៈ ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។

**១៤.ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បាននិងកំពុងរៀបចំដំណើរការសិក្សាអំពីជម្រើសនានានៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវអនុវត្តដោយក្រុមការងារអន្តរក្រសួង រួមមាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប.
- កំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## គ. សមាសភាគទី៣ ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៣នេះ រួមមានសកម្មភាពជាអាទិភាពចំនួន ២០ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន ១៣ ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោមៈ

**១. ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីមុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមរៀបចំការបណ្តុះបណ្តាលដល់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។

**២. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំឱ្យមានលក្ខខណ្ឌការងារសម្រាប់មន្ត្រី បុគ្គលិកប្រចាំឆ្នាំនៅតាមសង្គមភាពសាមីនីមួយៗរបស់ខ្លួន។

**៣. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមានប្រចាំថ្ងៃនៅតាមអង្គភាពនីមួយៗ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមគ្រប់គ្រងបុគ្គលិកនានារបស់ខ្លួន ដែលបានផ្ទេរទៅឱ្យតាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបានល្អប្រសើរជាងមុន។

### ៤. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការចូលនិវត្តត្រូវបាននិងកំពុងសិក្សារៀបចំ ដោយក្រសួងមុខងារសាធារណៈ។

### ៥. ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក

- ក្រសួងមុខងារសាធារណៈ បានរៀបចំការពិនិត្យ និងពិភាក្សាលើស្ថានភាពនៃការអនុវត្តក្នុងវិស័យការងារ ការបណ្តុះបណ្តាល និងពាក់ព័ន្ធនានាទៅនឹងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបានសិក្សា និងរៀបចំសិក្ខាសាលា ឬបណ្តុះបណ្តាលការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ៦. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកចំនួន ១០៣.២៨២រូប ក្នុងនោះ៖
  - មន្ត្រីបុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន ២៥.៧៥៣រូប ស្ត្រី ១៣.២០០រូប (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន ៣.២៩៥រូប ស្ត្រីចំនួន ១.០៣១រូប និងគ្រូពេទ្យមានចំនួន ២២.៤៥៨រូប ស្ត្រីចំនួន ១២.១៦៩រូប)
  - មន្ត្រីបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន ៧៧.៥២៩រូប (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន ១៧.៥២៩រូប ស្ត្រី៦.៦៤១រូប និងគ្រូបង្រៀនប្រមាណជាង ៦០.០០០រូប)
- រដ្ឋបាលថ្នាក់ក្រោមជាតិពុំត្រូវបានអនុញ្ញាតឱ្យស្នើសុំក្របខ័ណ្ឌថ្មីសម្រាប់ឆ្នាំ២០២៤ទេ ប៉ុន្តែក្រសួងមុខងារសាធារណៈ តាមរយៈសាលាភូមិន្ទរដ្ឋបាលគ្រោងជ្រើសរើសមន្ត្រីជាន់ខ្ពស់ (ក្របខ័ណ្ឌ ក) ចំនួន ១រូប សម្រាប់រដ្ឋបាលរាជធានី ខេត្តនីមួយៗ និងជ្រើសរើសមន្ត្រីក្រមការ (ក្របខ័ណ្ឌ ខ) ចំនួន ១រូប សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

### ៧.ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨) ក្រោមការដឹកនាំសម្របសម្រួលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ និងមានការគាំទ្រដោយកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD) របស់កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង(GIZ)
- មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ និងប្រធាន/អនុប្រធានការិយាល័យ) មាន **ចំនួន ៥៨៣រូប ស្មើនឹង ២៧,៤៦%** និងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ) មាន**ចំនួន ១.៦៦៨រូប ស្មើនឹង ២៣,៣២%**។

### ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៤ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | ២៥ | ២ | ៨% |
| ២ | អភិបាលរង | ២៥០ | ៣១ | ១២,៤០% |
| ៣ | នាយករដ្ឋបាល | ២៥ | ១ | ៤% |
| ៤ | នាយករងរដ្ឋបាល | ១១៥ | ២១ | ១៨,២៦% |
| ៥ | នាយកទីចាត់ការ និងឬថ្នាក់ស្មើ | ២០៨ | ២៤ | ១១,៥៤% |
| ៦ | នាយករងទីចាត់ការ និងឬថ្នាក់ស្មើ | ៣៩៨ | ១១៣ | ២៨,៣៩% |
| ៧ | ប្រធានការិយាល័យ | ៣៨៨ | ១០៣ | ២៦,៥៥% |
| ៨ | អនុប្រធានការិយាល័យ | ៧១៤ | ២៨៨ | ៤០,៣៤% |
| **សរុប** | | **២.១២៣** | **៥៨៣** | **២៧,៤៦%** |

### ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៤ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | ២០៨ | ៧ | ៣,៣៧% |
| ២ | អភិបាលរង | ១២៤៨ | ២៤៨ | ១៩,៨៧% |
| ៣ | នាយករដ្ឋបាល | ១៧៩ | ១៨ | ១០,០៦% |
| ៤ | នាយករងរដ្ឋបាល | ៣០៨ | ៧៨ | ២៥,៣២% |
| ៥ | ប្រធានការិយាល័យ និងឬថ្នាក់ស្មើ | ២០៥៦ | ៤២០ | ២០,៤៣% |
| ៦ | អនុប្រធានការិយាល័យ និងឬថ្នាក់ស្មើ | ៣១៥៣ | ៨៩៧ | ២៨,៤៥% |
| **សរុប** | | **៧.១៥២** | **១.៦៦៨** | **២៣,៣២%** |

**៨. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តនានា និងឯកសារគោលនយោបាយមួយចំនួន រួមមាន (១) សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២) សេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (៣) ក្របខ័ណ្ឌស្តង់ដាសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៤) ក្របខ័ណ្ឌស្រាវជ្រាវរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និង (៥) សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត និងកំណត់តួនាទីរបស់នាយកគ្រប់គ្រងវគ្គបណ្តុះបណ្តាល
- វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**៩. ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានីខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព**

- អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១០. ការរៀបចំ និងការដាក់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព**

- រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន ស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់សរុបចំនួន **៦០វគ្គ** ដែលមានសិក្ខាកាមចូលរួមសរុប **ចំនួនប្រមាណ ៥.២៨០រូប** ដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចជា៖
  - ការងារគណនេយ្យភាពសង្គម (ដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់)
  - សន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់កុមារក្នុងវ័យលូតលាស់ (ដល់រដ្ឋបាលឃុំ សង្កាត់)
  - ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ (ដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)
  - ពិធីការនិងបដិសណ្ឋារកិច្ច (ដល់រដ្ឋបាលក្រុង ស្រុក ចំនួន ៦៧២)
  - ការពង្រឹងតួនាទីរបស់ គ.ក.ស.ក. (នៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)
  - តួនាទីរបស់ គ.ដ.វ.វ. (នៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)
  - របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន (ដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់)

- ការកសាងផែនការ និងការរៀបចំថវិកា (ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់)
- អន្តរាគមន៍អភិវឌ្ឍសមត្ថភាព (ដល់មន្ត្រីរដ្ឋបាលរាជធានី ខេត្ត)
- តួនាទី ភារកិច្ចស្មៀន (ដល់រដ្ឋបាលឃុំ សង្កាត់)
- ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ (ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់)
- ថវិកាឆ្លើយតបទៅនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ (ដល់រដ្ឋបាលឃុំ សង្កាត់)។

**១១. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន**

- បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានបានចូលរួមវគ្គបណ្តុះបណ្តាល**ចំនួន ០៦វគ្គ** នៅក្នុងប្រទេសចំនួន **០៤វគ្គ** និងក្រៅប្រទេសចំនួន **០២វគ្គ** ដែលមានសិក្ខាកាមសរុប**ចំនួន ១៦រូប ស្ត្រី ០៥រូប** លើប្រធានបទសំខាន់ៗ ដូចជាៈ
  - ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងលំហូឯកសារអេឡិចត្រូនិក
  - ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ជំនាន់ទី៦
  - វិក្រឹត្យការ ឆ្នាំ២០២៤
  - គោលការណ៍ បែបបទ និងនីតិវិធីក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - កម្មវិធីទស្សនកិច្ចសិក្សាស្តីពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍវិស័យកសិកម្មបច្ចេកវិទ្យាទំនើប និងច្រវាក់ទីផ្សារ
  - កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីភាពជាអ្នកដឹកនាំលើវិស័យសាធារណៈសម្រាប់មន្ត្រីជាន់ខ្ពស់ទី១
  - ធ្វើតេស្តសមត្ថភាពលើជំនាញបច្ចេកវិទ្យាឌីជីថលដែលរៀបចំឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងដំណើរការសាងសង់សាលាជាតិរដ្ឋបាលដ្ឋានដោយមានវឌ្ឍនភាព **២៨%** ដោយអគារសិក្សាកំពុងសាងសង់គ្រោងឆ្អឹងជាន់ទី២ និងរៀបចំខណ្ឌជាបន្ទប់ រីឯអគារអន្តេវាសិកដ្ឋានកំពុងបូកជញ្ជាំង។ អគារសាលាជាតិរដ្ឋបាលមូលដ្ឋានមានចំនួន ០២ខ្នង គឺអគារសិក្សាសម្រាប់បង្រៀនដែលមានទំហំ ១២.៨៥៨ម៉ែត្រការ៉េ កម្ពស់២ជាន់ និងអគារអន្តេវាសិកដ្ឋានទំហំ ៣.៧៣៤ម៉ែត្រការ៉េ កម្ពស់១ជាន់។ អគារសិក្សាមានបន្ទប់សិក្សាតូចៗចំនួន៩ បន្ទប់សិក្សាធំៗចំនួន៧ សហសាលសិក្សាចំនួន១ បន្ទប់កុំព្យូទ័រចំនួន២ បណ្ណាល័យចំនួន១ បន្ទប់ប្រជុំចំនួន២ បន្ទប់សម្រាប់គ្រូបង្រៀនចំនួន១ អាហារដ្ឋានចំនួន១ កន្លែងក្មេងលេង បន្ទប់ព្យាបាលបឋមចំនួន០១ បន្ទប់សម្ភារៈនិងបន្ទប់ផ្សេងៗទៀត។ ក្រៅពីនេះមានការិយាល័យសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារ។ អគារអន្តេវាសិកដ្ឋានមានបន្ទប់សម្រាប់សិក្ខាកាមស្នាក់នៅចំនួន៦៤បន្ទប់ និងបន្ទប់ផ្សេងៗទៀត។ ការសាងសង់អគារសិក្សា និងអន្តេវាសិកដ្ឋាននៃសាលាជាតិរដ្ឋបាលមូលដ្ឋានគ្រោងបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០២៥ ខាងមុខ ដែលប្រើប្រាស់ថវិកាសាងសង់

ប្រមាណ៦.១៥លានដុល្លារ ដែលទទួលបានថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ស្ថិតក្រោមក្របខ័ណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុដំហានទី២ (ADB Loan No. 3970-CAM)។

**១២. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន **១៤វគ្គ** ដែលមានសិក្ខាកាមសរុបចំនួន **៦២១រូប ស្ត្រីចំនួន ១៤០រូប** ដោយផ្តោតលើប្រធានបទ និងកម្មវិធីសំខាន់ៗ ដូចជាៈ
  - កម្មវិធីគ្រប់គ្រងកម្រិត១
  - កម្មវិធីវិក្រឹត្យការមូលដ្ឋានជំនាន់ទី៨
  - កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ
  - ការរៀបចំផែនការថវិកា
  - ការលើកកម្ពស់សមធម៌ និងបរិយាបន្នសង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - កិច្ចការរដ្ឋបាល និង
  - ការតាក់តែងអត្ថបទ។

**១៣. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងរៀបចំជាសេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងបានកំពុងរៀបចំកម្មវិធីសិក្សាថ្មីចំនួន០៤ រួមមាន (១) កម្មវិធីសិក្សារយៈពេលវែង (២) កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ (៣) កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (៤) កម្មវិធីសិក្សាសម្រាប់សាធារណជន

**១៤. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំសៀវភៅណែនាំមួយចំនួន រួមមាន (១) សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល (២) សៀវភៅណែនាំស្តីពីប្រតិបត្តិការសម្រាប់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន (៣) សៀវភៅគោលស្តីពីការគ្រប់គ្រងមុខងារសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត (៤) សៀវភៅគោលស្តីពីការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព (៥) សៀវភៅណែនាំស្តីពីនីតិវិធី និងរបៀបរបបការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (៦) សៀវភៅគោលស្តីពីពិធីការ (៧) សៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាល (៨) សៀវភៅណែនាំស្តីពីការរៀនបណ្តើរធ្វើការបណ្តើរ (៩) សៀវភៅគោលស្តីពីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅកម្ពុជា

(១០) សៀវភៅគោលស្ដីពីក្រមសីលធម៌មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ និង (១១) សៀវភៅណែនាំស្ដីពីការគ្រប់គ្រងបណ្ណាល័យ និងបណ្ណសារដ្ឋាន

- បាននិងកំពុងរៀបចំឯកសារបណ្តុះបណ្តាលតម្រង់ទិសសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលចាប់ឆ្នោតថ្មីក្នុងឆ្នាំ២០២៤។

## ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៤នេះ រួមមានសកម្មភាពជាអាទិភាពចំនួន**១៦** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន**១៣** ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការបញ្ជ្រាបរវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរណែនាំលេខ០០២ សហវ.ស.រ.អថ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្ដីពីប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានរៀបចំគម្រោងថវិកា និងអនុលោមភាពគម្រោងឆ្នាំ២០២៤ សរុបប្រមាណ**ចំនួន ២.៩៦០គម្រោង** ដែលគម្រោងទាំងនេះជាគម្រោងដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

### ២. ការរៀបចំឯកសារយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បាននិងកំពុងរៀបចំសៀវភៅណែនាំស្ដីពីវិធីសាស្ត្របញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយបរិយាបន្ន សមធម៌សង្គមក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់។

### ៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងផែនការ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យអនឡាញ ព្រមទាំងបានប្រមូល ផលិត និងចែករំលែកព័ត៌មានជាសាធារណៈអំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។

### ៤. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

- រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការតាមដានត្រួតពិនិត្យការអនុវត្តថវិកា និងការរៀបចំរបាយការណ៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញសារាចរណែនាំចំនួនពីររួមមាន (១) សារាចរណែនាំលេខ០០៥ សហវ.ស.រ. អហក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និង (២) សារាចរណែនាំលេខ០០៧ សហវ.ស.រ.អហក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ២០២៥-២០២៧ និង

នីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៥ ដែលក្នុងនោះ បានកំណត់នូវក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ២០២៥-២០២៧ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- រដ្ឋបាលរាជធានី ខេត្ត (ឆ្នាំ២០២៥ មាន**ចំនួន ២.៦១១.៦៧១ លានរៀល** ឆ្នាំ២០២៦ មាន**ចំនួន ២.៩១៥.៣៧៨ លានរៀល** ឆ្នាំ២០២៧ មាន**ចំនួន ៣.២៣១.៧៩៩ លានរៀល**)
- រដ្ឋបាលក្រុង ស្រុក (ឆ្នាំ២០២៥ មាន**ចំនួន ៤៦៤.៨២០ លានរៀល** ឆ្នាំ២០២៦ មានចំនួន **៥០២.២៤១ លានរៀល** ឆ្នាំ២០២៧ មាន**ចំនួន ៥៦០.៣៦០ លានរៀល**)
- រដ្ឋបាលឃុំ សង្កាត់ (ឆ្នាំ២០២៥ មាន**ចំនួន ១.៤០៦.៩៦០ លានរៀល** ឆ្នាំ២០២៦ មាន **ចំនួន ១.៤៨៩.៥១៧ លានរៀល** ឆ្នាំ២០២៧ មាន**ចំនួន ១.៦៦៥.៤៨៧ លានរៀល**)

- ផ្អែកតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានស្ថានភាព ដូចខាងក្រោម៖

*ឯកតា៖ លានរៀល*

| **បរិយាយ** | **គម្រោង** | **ជាក់ស្តែង** | **(%)** |
|---|---|---|---|
| **១. ថវិការដ្ឋបាលរាជធានី** | | | |
| – ចំណូល | ៣.៥៦៣.៤៧៤,៨ | ២.២០៤.៣៦៦.៣ | ៦១,៨៦% |
| – ចំណាយ | ៣.៥៦៣.៤៧៤,៨ | ១.២១០.៥៧២.៥ | ៣៤% |
| **២. ថវិការដ្ឋបាលក្រុង ស្រុក** | | | |
| – ចំណូល | ២.២៥៥.២៨៤,៥ | ១.៨៩៩.៤១៨,៣ | ៨៤,២២% |
| – ចំណាយ | ២.២៥៥.២៨៤,៥ | ៧១៤.៤១០.០ | ៣១,៦៨% |
| **៣. ថវិការដ្ឋបាលឃុំ សង្កាត់** | | | |
| – ចំណូល | ១.១៥០.៣៩៩ | ៥៧៦.៤៨០ | ៥០,១១% |
| – ចំណាយ | ១.១៥០.៣៩៩ | ៤៦២.៣១៨ | ៤០,១៩% |
| **៤. សរុបថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** | | | |
| – ចំណូល | ៦.៩៦៩.១៥៨,៣ | ៤.៦៨០.២៦៤,៦ | ៦៧,១៥% |
| – ចំណាយ | ៦.៩៦៩.១៥៨,៣ | ២.៣៨៧.៣០០,៥ | ៣៤,២៦% |

### ៥. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានផ្តល់គោលការណ៍ណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសារាចរណែនាំលេខ០០៧ សហវ.ស.រ.អហក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលរួមមាន៖
  - សម្រាប់ផែនការលទ្ធកម្មប្រចាំរបស់រដ្ឋបាលរាជធានី ខេត្តត្រូវពិនិត្យ និងសម្រេចក្នុងក្របខ័ណ្ឌនៃការចរចាថវិការដ្ឋបាលរាជធានី ខេត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- សម្រាប់ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ត្រូវដាក់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងអនុម័តក្នុងពេលដំណាលគ្នានឹងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកដែលត្រូវដាក់ជូនអភិបាលខេត្តសាមី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។

**៦. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រង ចំណូលសារពើពន្ធដែលមានស្រាប់**

- គិតមកដល់ខែមិថុនា ក្នុងឆ្នាំ២០២៤នេះ ចំណូលសារពើពន្ធរបស់រាជធានី ខេត្ត មានចំនួន **៧៨៤.០១២,៧ លានរៀល** ស្មើនឹង **១៩១.២ លានដុល្លារ** មានការកើនឡើងចំនួន **៦ លានដុល្លារ** ស្មើនឹង ១០៣,២០% ធៀបនឹង០៦ខែ ដើមឆ្នាំ២០២៣ មានចំនួន **៧៥៩.៤១៧ លានរៀល** ស្មើនឹង **១៨៥.២ លានដុល្លារ**។

**៧. ការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**

- តាមគោលការណ៍ រដ្ឋបាលខេត្តត្រូវបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងអត្រា ៤%។ ក្រៅពីនេះ រដ្ឋបាលរាជធានី ខេត្តត្រូវបែងចែកចំណូលសារពើពន្ធរបស់ខ្លួនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងអត្រា ៦%។ ការអនុវត្តជាក់ស្តែង ដោយសារស្ថានភាពចំណូលជាក់ស្តែងការបែងចែកចំណូលនេះ ត្រូវបានកាត់ព្យួរទាំងស្រុងការផ្ទេរចំណូលពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តជូនរដ្ឋបាលក្រុង ស្រុក និងការផ្ទេរចំណូលពីការបែងចែកចំណូលសារពើរពន្ធរបស់រដ្ឋបាលរាជធានី ខេត្តជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ឆ្នាំ២០២៤ តាមសារាចរណែនាំលេខ០០៥ សហវ.ស.រ.អហក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

**៨. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា**

- គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស បាននិងកំពុងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- បានដាក់អនុវត្តជាផ្លូវការប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយខេត្តគោលដៅទាំង២៥
- បានធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធ NRMIS និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត តាមប្រព័ន្ធអនឡាញ
- បាននិងកំពុងសម្របសម្រួលការងារជាមួយធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំនីតិវិធីសម្រាប់បង់កម្រៃសេវារដ្ឋបាលនៅតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាម QR CODE។

**៩. ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក**

- រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ ២០២៤-២០២៨ ក្នុងអត្រាថេរប្រចាំឆ្នាំ **១,៦%** ដែលអត្រានេះ មានការកើនឡើង **0,១%** ធៀបទៅនឹង អត្រាផ្ទេរនៅក្នុងឆ្នាំ២០២៣។ ថវិការបស់រដ្ឋបាល**ក្រុង ស្រុកសម្រាប់ឆ្នាំ២០២៤នេះ មាន**

**ចំនួន ២.២៨៨.០១៧ លានរៀល ដែលស្មើនឹង ៥៥៨ លានដុល្លារ** មានការកើនឡើងចំនួន **១.៦០៧.២១៤ លានរៀល ស្មើនឹង ៣៩២ លានដុល្លារ (ស្មើនឹង ៣៣៦%)** ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៣។ ថវិការបស់ក្រុង ស្រុក ឆ្នាំ២០២៤ ដែលកើនឡើងយ៉ាងខ្លាំងនេះ ដោយសារមានការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលក្រុង ស្រុកទូទាំងប្រទេសសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំក្នុងទំហំប្រមាណ **៤០៦ លានដុល្លារ** (ក្នុងនោះថវិកាបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានទំហំប្រមាណជាង ៣៣លានដុល្លារ)។

### ១០. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្នព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

- បានដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងអប់រំកុមារតូច អប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ. ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ចប់សេចក្តីព្រាងបឋមនូវសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បាននិងកំពុងរៀបចំក្រុមការងារអន្តរក្រសួងដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានការចូលរួមពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីសិក្សា និងកំណត់នូវមុខងារដែលមានតម្រូវការធនធានក្នុងវិស័យជំនាញទាំង២០ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងកំណត់នូវទំហំធនធានហិរញ្ញវត្ថុឱ្យច្បាស់លាស់ និងសមស្របសម្រាប់ផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ១១. ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលក្រុង ស្រុកសម្រាប់ផ្តល់ហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)
- គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក.) បានធ្វើការវាយតម្លៃទៅលើរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ចំនួន១០០ ដើម្បីទទួលបានហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ដើម្បីអនុវត្តគម្រោងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១២. ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាគតភាព និងកញ្ចប់ថវិកាពិសេស**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិភាគតភាព (មូលនិធិនេះមានប្រភពចំណូលពីការចែករំលែកចំណូលមិនមែនសារពើពន្ធលើការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងការចែករំលែកចំណូលពីទ្រព្យសម្បត្តិរដ្ឋ) ក្នុងគោលបំណង ដើម្បីបង្កើនធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីការអនុវត្តគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារនិងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានប្រជុំពិភាក្សាពិគ្រោះយោបល់សេចក្តីព្រាងសារាចរណែនាំនេះ ជាមួយក្រសួងមហាផ្ទៃ និងលេខាធិការ គ.ជ.អ.ប. នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤។

**១៣. ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការ**

- គ.ជ.អ.ប. បានដឹកនាំកិច្ចប្រជុំចង្អៀតកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ជាមួយតំណាងក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.អ.ប. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំណាងរដ្ឋបាលរាជធានី ខេត្តមួយចំនួន ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈមនៃការចុះបញ្ជីវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត និងវិធានការនានាក្នុងការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្តក្នុងការសម្រេចលើកិច្ចការពាក់ព័ន្ធនឹងការចុះបញ្ជីគម្រោងវិនិយោគ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់របស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសអន្តរក្រសួងកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ដែលមានមួយចំនួន ដើម្បីពន្យល់បកស្រាយអំពីខ្លឹមសារសំខាន់ៗនៃច្បាប់វិនិយោគថ្មី អនុក្រឹត្យលេខ១២០ និងផ្តល់ការណែនាំ ព្រមទាំងមានការឯកភាពគ្នាក្នុងការរៀបចំកិច្ចការសំខាន់ៗដែលច្បាប់ និងអនុក្រឹត្យទាំងនេះតម្រូវឱ្យក្រសួង ស្ថាប័នត្រូវធ្វើប្រតិភូមកម្មអំណាចទៅមន្ទីរអង្គភាពរបស់ខ្លួនការផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រនានា ដើម្បីជានាឱ្យរដ្ឋបាលរាជធានី ខេត្តអាចអនុវត្តនូវមុខងារចុះបញ្ជីគម្រោងវិនិយោគនានាដែលទុនសមមូល៥លានដុល្លារចុះស្របតាមច្បាប់ និងអនុក្រឹត្យកំណត់
- គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ ក្រសួង ស្ថាប័នចំនួន៤ បានដាក់ចេញនូវប្រកាសប្រតិភូកម្មដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួនដែលរួមមាន ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្ត និងក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីពិនិត្យ ផ្តល់យោបល់ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគនានាដែលទុនសមមូល

៥លានដុល្លារចុះ។ ក្រសួង ស្ថាប័នចំនួន១០ទៀត បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសប្រតិភូកម្ម។

**១៤. ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងសិក្សា និងរៀបចំដាក់ឱ្យអនុវត្តនូវនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំការសិក្សាអំពីលទ្ធភាពនៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត។

## ខ. សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមាសភាគទី៥នេះ រួមមានសកម្មភាពជាអាទិភាព**ចំនួន ១១** នៅក្នុងនោះសកម្មភាពអាទិភាពត្រូវបានអនុវត្ត**ចំនួន ១១** សកម្មភាពដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច**

- បាននិងកំពុងសិក្សាដើម្បីកំណត់ឱ្យច្បាស់លាស់នូវមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានផ្តល់ការគាំទ្រសមត្ថភាព និងការចែករំលែកបទពិសោធនៃគ្រប់គ្រងការផ្តល់សេវាសុខភិបាល និងបាន និងកំពុងរៀបចំឯកសារទស្សនទានស្តីពីសិក្ខាសាលាដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធយន្តការទំនាក់ទំនងគាំទ្រ តាមដានត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តការផ្ទេរមុខងារសុខាភិបាល ( SMEM )
- បានចុះត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តមុខងារដែលបានប្រគល់ និងធ្វើប្រតិភូកម្មក្នុងការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៅខេត្តសៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង កំពត កែប តាកែវ កណ្តាល និងខេត្តស្វាយរៀង
- បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីស្ថានភាពនៃការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិភាក្សាលើបញ្ហានានានៃការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្វែងរកដំណោះស្រាយ។ កិច្ចប្រជុំនេះ មានសមាសភាពអ្នកចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាល ប្រធាន និងមន្ត្រីនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងតំណាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងបានពិភាក្សាលើស្ថានភាពទូទៅនៃការអនុវត្តមុខងារទាំង៥៥នៃវិស័យចំនួន២០ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បាននិងកំពុងរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីអនុវត្តមុខងារការសាងសង់ ការជួសជុល ការថែទាំផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានា និងការងារគ្រប់គ្រងដីចំណីផ្លូវជាតិ ផ្លូវខេត្តដែលស្ថិតក្នុងទីប្រជុំជន
- បានរៀបចំឯកសារទស្សនទានស្តីពីការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល ដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងសិក្សាពីលទ្ធភាពក្នុងការផ្ទេរមុខងារសុខាភិបាលពីរដ្ឋបាលរាជ

ធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ និងលទ្ធភាពក្នុងការបង្កើតការិយាល័យសុខាភិបាលនៃរដ្ឋបាលក្រុង ស្រុក។

**២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស**

- បាននិងកំពុងបន្តប្រជុំពិគ្រោះយោបល់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង មូលនិធិឃុំ សង្កាត់ (PIM) ដើម្បីពិនិត្យ កែសម្រួលជំពូក៣ ស្តីពីកិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានត្រួតពិនិត្យ និងបញ្ជាក់លើរបាយការណ៍បច្ចេកទេសកិច្ចការសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចលើគម្រោងមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុក មានចំនួនសរុប៦៧៦គម្រោង ដែលរួមមានផ្លូវដី ផ្លូវបេតុង ស្ពានប្រឡាយ ដាក់បង្គោលភ្លើង សាងសង់របងសាលា១គម្រោង ចាក់សាប សង់ស្ពាន និងសង់ទំនប់ទឹក
- ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៤ មាន**ចំនួន ២.១០៦ គម្រោង** ដែលក្នុងនោះគម្រោងមិនទាន់សិក្សាចំនួន៣៩គម្រោង ស្មើនឹង ១,៨៥% គម្រោងកំពុងដំណើរការសិក្សាចំនួន ៤២៥ គម្រោង ស្មើនឹង ២,១៨% គម្រោងបានបញ្ចប់ការសិក្សាចំនួន ១.៦៤២ គម្រោង ស្មើនឹង ៧៧,៩៧%។ គម្រោងឃុំ សង្កាត់ ឆ្នាំ២០២៤ បានដេញថ្លៃរួចចំនួន ៨៩៨ គម្រោង ស្មើនឹង ៥៤,៦៩% នៃគម្រោងបានបញ្ចប់ការសិក្សា។ ការអនុវត្តកិច្ចសន្យាគម្រោងឃុំ សង្កាត់ ឆ្នាំ២០២៤ មានចំនួន៦០៩កិច្ចសន្យា ក្នុងនោះរួមមានកិច្ចសន្យាមិនទាន់អនុវត្តចំនួន២៦៦កិច្ចសន្យា ស្មើនឹង ៤៣,៦៨% អនុវត្តបានតិចជាង ៥០% ចំនួន ១៤៤កិច្ចសន្យា ស្មើនឹង ២៣,៦៥% អនុវត្តបានលើស៥០% ចំនួន១១៨កិច្ចសន្យា ស្មើនឹង ១៩,៣៨% បញ្ចប់ការសាងសង់ ១០០% ចំនួន៨១កិច្ចសន្យា ស្មើនឹង១៣,៣០%
- ការរៀបចំគម្រោងក្រុង ស្រុកឆ្នាំ២០២៤ មានចំនួន **៥៣៧គម្រោង** ដែលក្នុងនោះគម្រោងមិនទាន់សិក្សាចំនួន ១៣៦គម្រោង ស្មើនឹង ២៥.៣៣% គម្រោងកំពុងដំណើរការសិក្សាចំនួន ១៨៨គម្រោង ស្មើនឹង ៣៥.០១% គម្រោងបានបញ្ចប់ការសិក្សាចំនួន ២១៣គម្រោង ស្មើនឹង ៣៩.៦៦%។ គម្រោងក្រុង ស្រុក ឆ្នាំ២០២៤ បានដេញថ្លៃរួចចំនួន ៦១គម្រោង ស្មើនឹង ២៨.៦៤% នៃគម្រោងបានបញ្ចប់ការសិក្សា។ ការអនុវត្តកិច្ចសន្យាគម្រោងក្រុង ស្រុកឆ្នាំ២០២៤ មានចំនួន ៥៤កិច្ចសន្យា ក្នុងនោះរួមមានកិច្ចសន្យាមិនទាន់អនុវត្តចំនួន ៣៧កិច្ចសន្យា ស្មើនឹង ៦៨.៥២% អនុវត្តបានតិចជាង៥០% ចំនួន ០៨កិច្ចសន្យា ស្មើនឹង ១៤.៨១% អនុវត្តបានលើស ៥០% ចំនួន០៤កិច្ចសន្យា ស្មើនឹង ៧.៤១% បញ្ចប់ការសាងសង់១០០% ចំនួន ០៥កិច្ចសន្យា ស្មើនឹង ៩.២៦%
- ការរៀបចំគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៤ មាន**ចំនួន ២៨០គម្រោង** ដែលក្នុងនោះគម្រោងបានបញ្ចប់ការសិក្សាចំនួន ២៨០គម្រោង ស្មើនឹង ១០០% ការអនុវត្តកិច្ចសន្យាគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៤ មានចំនួន ១០៧កិច្ចសន្យា ក្នុងនោះរួមមានកិច្ចសន្យាអនុវត្តបានតិចជាង ៥០% ចំនួន៣៦កិច្ចសន្យា ស្មើនឹង៣៣.៦០% អនុវត្តបានលើស ៥០% ចំនួន ៤៧កិច្ចសន្យា ស្មើនឹង ៤៣.៩០% បញ្ចប់ការសាងសង់ ១០០% ចំនួន ២៤កិច្ចសន្យា ស្មើនឹង ២២.៥០%។ គម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានីខេត្ត ឆ្នាំ២០២៤ បានដេញថ្លៃរួច**ចំនួន**

**១៥៦គម្រោង** ស្មើនឹង ៥៥.៧០% នៃគម្រោងបានបញ្ចប់ការសិក្សា។ បានពិនិត្យ និងផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍន៍រាជធានី ខេត្ត សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៤ **ចំនួន ១៣១ គម្រោង** ដែលភាគច្រើនជាគម្រោងស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ អគាររដ្ឋបាល បណ្តាញអគ្គិសនី សួនច្បារសាធារណៈ និងសំណង់សិល្បការនានា។

**៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត**

- នៅក្នុងឆមាទី១ ឆ្នាំ២០២៤នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន **៣៦១.៧៩៥សេវា ស្មើនឹង ១១៥%** ធៀបនឹងចំនួនសេវាសរុបដែលបានផ្តល់ក្នុងឆមាសទី១ ឆ្នាំ២០២៣សេវា។ បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងវិស័យទាំង១៤ វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានផ្តល់សេវាច្រើនជាងគេគឺ**ចំនួន ១២៤.២០៨សេវា ស្មើនឹង ៣៤,៣៣%** បន្ទាប់មកគឺវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់សេវា**ចំនួន ៨៤.៣៩៤ សេវា ស្មើនឹង ២៣,៣៣%**។ ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺវិស័យពាណិជ្ជកម្មបានផ្តល់សេវា**ចំនួន ២សេវា ស្មើនឹង ០,០០១%**។




- នៅក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន **៥២.០២៩.១៩៦.១០៩ រៀល ស្មើនឹង ១៣.០០៧.២៩៩,០២ ដុល្លារ ស្មើនឹង ១០៩.៤៣%** ធៀបនឹងចំណូលសរុបឆមាសទី១ ឆ្នាំ២០២៣ **សរុបចំនួន ៤៧.៥៤៦.៥២៤.១៥២ រៀល ស្មើនឹង ១១.៨៨៦.៦៣១,៥៣ ដុល្លារអាមេរិក**។ បើប្រៀបធៀបចំណូលដែលទទួលបានក្នុងវិស័យទាំង១៤ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺ**ចំនួន ៣៩.៥៥៥.៧១៧.០៥៩ រៀល ស្មើនឹង ៧៦.០៣%** បន្ទាប់មកវិស័យសាធារណការ និងដឹកជញ្ជូន ទទួលបានចំណូល**ចំនួន ៤.០១៣.៨៩៨.៧០០ រៀល ស្មើនឹង ៧,៧១%**។ ចំពោះវិស័យដែលបានទទួលចំណូលតិចជាងគេ គឺវិស័យពាណិជ្ជកម្មបានទទួលចំណូល**ចំនួន ៤០០.០០០ រៀល ស្មើនឹង ០,០០១%**។




- បានរៀបចំផលិតវីដេអូឯកសារ និងផ្សព្វផ្សាយអប់រំពាក់ព័ន្ធនឹងដំណើរការរៀបចំកម្មវិធីសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានរៀបចំដាក់ឱ្យអនុវត្តនិងផ្តល់ការបណ្តុះបណ្តាលអំពីប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) និងការដាក់ឱ្យអនុវត្តសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅរដ្ឋបាលខេត្តចំនួន៨បន្ថែមទៀត
- បានប្រជុំពិភាក្សាជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីការធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធ NRMIS និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ចំនួន ២៣បន្ថែមទៀត តាមប្រព័ន្ធអនឡាញ
- បានរៀបចំវគ្គបណ្តុះបណ្តាល អំពីការទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅអង្គភាពច្រកចេញចូលតែមួយចំនួន៨គោលដៅ នៅខេត្តកំពត
- បានរៀបចំកិច្ចប្រជុំពិភាក្សា អំពីការបង្កើត គណៈកម្មាធិការរាជធានី ខេត្ត ដឹកនាំជំរុញការអនុវត្តយន្តការច្រកចេញចូលតែមួយថ្នាក់ឃុំ សង្កាត់។ ដោយបញ្ចូលការងារអត្តសញ្ញាណកម្មជាការងារអាទិភាព
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើសន្ទានកម្មទិន្នន័យរវាងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)

**៩. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

- នៅក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បានផ្តល់សេវារដ្ឋបាលសរុបចំនួន **១.៤៦៧.៥៥៦សេវា ស្មើនឹង ១១០.៦២%** ធៀបនឹងសេវាសរុបដែលផ្តល់ក្នុងឆមាសទី១ ឆ្នាំ២០២៣។ បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងវិស័យទាំង១៧ ការងារអត្រានុកូលដ្ឋានបានផ្តល់សេវាបានច្រើនជាងគេគឺ**ចំនួន ៧៨៤.៣២៦សេវា ស្មើនឹង ៣,៤៤%** បន្ទាប់មកការងារនីត្យានុកូលកម្មបានផ្តល់សេវាចំនួន **៦០៦.២០៩សេវា ស្មើនឹង ៤១,៣១%**។

ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេ គឺវិស័យបរិស្ថានបានផ្តល់សេវាចំនួន **១៨សេវា ស្មើនឹង ០,០០១%** និងវិស័យដែលមិនបានផ្តល់សេវា គឺវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។




- នៅក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន **៤.៣៤៦.២៩០.១១៤ រៀល ស្មើនឹង ១.០៨៦.៥៧២,៥២ ដុល្លារ ស្មើនឹង ៦៨%** ធៀបនឹងចំណូលសរុបក្នុងឆមាសទី១ ឆ្នាំ២០២៣។ បើប្រៀបធៀបចំណូលដែលទទួលបានក្នុងវិស័យទាំង១៧ វិស័យសុរិយោដីទទួលបានចំណូលខ្ពស់ជាងគេគឺ**ចំនួន ១.១០៥.០៣៥.០០០ រៀល ស្មើនឹង ២៥,៤២%** បន្ទាប់មកវិស័យសំណង់ទទួលបានចំណូល**ចំនួន ៩០៦.៤៨៩.៣០០ រៀល ស្មើនឹង ២០,៨៦%**។ ចំពោះវិស័យដែលបានទទួលចំណូលតិចជាងគេ គឺវិស័យពាណិជ្ជកម្មទទួលបានចំណូលចំនួន **២០០.០០០ រៀល ស្មើនឹង ០,០០៥%** និងវិស័យដែលមិនទទួលបានចំណូលគឺការងារអត្រានុកូលដ្ឋានវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យធម្មការ និងសាសនា និងវិស័យបរិស្ថាន។



- បានប្រជុំជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទទួលបន្ទុកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីពិនិត្យមើលលទ្ធភាពក្នុងការតភ្ជាប់បណ្តាញអ៊ីនធឺណិតល្បឿនលឿនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន២លើក
- បានរៀបចំកិច្ចប្រជុំជាមួយនឹងប្រៃសណីយ៍កម្ពុជា ដើម្បីឈ្វេងយល់អំពីបណ្តាសេវានានាដែលប្រៃសណីយ៍កម្ពុជាកំពុងផ្តល់សេវា
- បានរៀបចំកិច្ចប្រជុំជាមួយអ្នកយកព័ត៌មានរបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia) ហៅកាត់ថា អូឌីស៊ី ដើម្បីពិភាក្សា និងផ្តល់ជូននូវឯកសារទិន្នន័យ និងព័ត៌មានសំខាន់ៗមួយចំនួនសម្រាប់ការសិក្សា និងចងក្រងសាច់រឿងទិន្នន័យ (Data story) អំពីលទ្ធផលនៃការអនុវត្តយន្តការច្រកចេញចូលតែមួយ
- បានប្រជុំពិភាក្សាជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងតំណាងអង្គការ GIZ អំពីការរៀបចំកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ
- បានប្រជុំពិភាក្សាជាមួយតំណាងអង្គការ GIZ គម្រោង ISD អំពីការរៀបចំលក្ខខណ្ឌក្នុងការជ្រើសរើសអ្នកជំនាញរៀបចំផែនការទំនាក់ទំនងសម្រាប់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- បានរៀបចំកិច្ចប្រជុំពិភាក្សាអំពី ការរៀបចំចរន្តឯកសារនៃការផ្តល់សេវាតាមប្រព័ន្ធអនឡាញរបស់ការិយាល័យច្រកចេញចូលតែមួយ
- បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយធនាគារជាតិអំពីការភ្ជាប់ទិន្នន័យរវាងប្រព័ន្ធបាគង និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ។

**៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ**

- បាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញនៅថ្នាក់រាជធានី ខេត្តចំនួន១២ លើប្រភេទសេវារដ្ឋបាលចំនួន១១៧ ក្នុងវិស័យចំនួន៤ រួមមាន វិស័យទេសចរណ៍ វិស័យវប្បធម៌និងវិចិត្រសិល្បៈ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងដាក់ឱ្យអនុវត្តនូវប្រព័ន្ធទូទាត់តាមវិក្កយបត្រ (Payment Hub) នៅថ្នាក់រាជធានី ខេត្តទាំង២៥ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

**៦. ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

- បាន និងកំពុងបន្តសិក្សាលទ្ធភាពស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**៧. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**

- បានបញ្ចប់ការរៀបចំកម្មវិធីការងាររយៈពេល០៥ឆ្នាំស្តីពីការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី២ (Entity Work Program) ឆ្នាំ២០២៤-២០២៨ របស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងបានបញ្ជូនកម្មវិធីការងារនេះ ទៅក្រសួងបរិស្ថានទទួលបន្ទុកជាតិ និងលេខាធិការដ្ឋានមូលនិធិអាកាសធាតុ

បៃតង (GCF)។ ជាមួយគ្នានេះដែរ កម្មវិធីការងារងាររយៈពេល០៥ឆ្នាំនេះ ក៏បានដាក់ជូនថ្នាក់ដឹកនាំដើម្បីសុំការអនុម័តលើកម្មវិធីនេះ និងត្រៀមរៀបចំផ្សព្វផ្សាយ

- បានគាំទ្រ និងរៀបចំនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងវិនិយោគរួមរវាងរដ្ឋបាលស្រុករុក្ខគិរី និងអ្នកវិនិយោគឯកជន ស្តីពីការរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងលើការវិនិយោគរួម និងការប្រព្រឹត្តទៅរបស់គណៈកម្មការ និងការបែងចែងតួនាទីភារកិច្ចរបស់ស្ថានីយក្នុងក្របខ័ណ្ឌគម្រោង LGCC-WRP។ គណៈកម្មការដឹកនាំ និងគ្រប់គ្រងការវិនិយោគលើប្រតិបត្តិការស្ថានីយទឹកស្អាតបានស័ក្តិនេះមានតួនាទី និងភារកិច្ចយ៉ាងសំខាន់សម្រាប់ធានាអំពីនិរន្តភាពនៃកិច្ចការងារដឹកនាំ និងប្រតិបត្តិការរបស់ស្ថាននីយទាំងមូល។ ម្យ៉ាងវិញទៀត គណៈកម្មការនេះជាគំរូដំបូងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ក្នុងការព្យាយាមប្រឹងប្រែងយកមុខងារគ្រប់គ្រងទឹកស្អាតនេះទៅអនុវត្តក្នុងគោលបំណងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលកំពុងខ្វះខាតទឹកស្អាតប្រើប្រាស់ និងពង្រឹងការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋានរបស់ខ្លួន
- បានសិក្សា និងរៀបចំដារបាយការណ៍ស្តីពីបញ្ជីឃ្លាំមើលបរិស្ថាន និងសង្គម និងបានដាក់បញ្ចូលក្នុងការរៀបចំធ្វើបច្ចុប្បន្នភាពនៃសៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)
- បាននិងកំពុងរៀបចំសេចក្តីព្រាងបឋមស្តីពីការតាក់តែងសៀវភៅស្តីពីការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំឆ្លង និងពិគ្រោះយោបល់លើបទដ្ឋាន និងគោលនយោបាយនានាក្នុងការផ្តួចផ្តើមការរៀបចំបទដ្ឋានបច្ចេកទេសលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ។

**៤. ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

- បានបន្តពិភាក្សាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM) ដើម្បីពិនិត្យ កែសម្រួលបញ្ចប់ជំពូក២ស្តីពីការពិនិត្យគម្រោង និងបញ្ជាក់បច្ចេកទេសដោយមានអ្នកចូលរួមមកពីលេខាធិការដ្ឋាន គ.ជ.អ.ប. នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ ខេត្ត និងអង្គការតម្លាភាព
- បានពិគ្រោះយោបល់ជាមួយអង្គការ UNDP ដើម្បីរកលទ្ធភាពផ្តល់ការគាំទ្របច្ចេកទេសលើការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។ ជាលទ្ធផលនៃកិច្ចពិភាក្សានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានពិនិត្យ និងផ្តល់ធាតុចូលលើលក្ខខណ្ឌការងារ (TOR) របស់ទីប្រឹក្សាចំនួន៤នាក់ ដើម្បី UNDP ធ្វើលទ្ធកម្ម ជ្រើសរើសទីប្រឹក្សានៅក្នុងខែឧសភា ឆ្នាំ២០២៤។

**៥. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

- បាននិងកំពុងអនុវត្តគម្រោងនវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាត ដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP)

- បាននិងកំពុងរៀបចំឯកសារទស្សនទានគម្រោងស្តីពីសេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងរណប អាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត (CR-Wash)
- បាននិងកំពុងរៀបចំឯកសារទស្សនទានគម្រោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវកសិកម្មអេកូឡូស៊ី ដែលងាយរងគ្រោះដោយសារអាកាសធាតុនៅតំបន់ខ្ពង់រាប
- បានរៀបចំសេចក្តីព្រាងស្តីពីកិច្ចសន្យាហិរញ្ញប្បទានរបស់គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រី ដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ (EmPower) ដំណាក់កាលទី២ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ (UNEP)
- បានពិនិត្យ និងរៀបចំដាក់បញ្ចូលគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមទៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់។

## ៣. ស្ថានភាពហិរញ្ញវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ចំណាយសរុបសម្រាប់ ផ.ស.ថ. របស់ គ.ជ.អ.ប. មាន**ចំនួន ២.៤២៧.៧១៥ លានរៀល** សមមូល **៥៩២ លានដុល្លារ ស្មើនឹង ៣៤%** នៃផែនការថវិកាដែលបានគ្រោងទុកសរុបចំនួន **៧.០៨៨.២៥៥ លានរៀល** សមមូល**១.៧២៩ លានដុល្លារ**។ ការចំណាយនេះ រួមបញ្ចូលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយរបស់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានគាំទ្រដល់ ផ.ស.ថ.ឆ្នាំ២០២៤។ ខាងក្រោមនេះ បង្ហាញអំពីក្រាហ្វិកនានានៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍន៍តាមសេចក្តីសម្រេចរួមនិងកិច្ចព្រមព្រៀង និងចំណូលសរុប និងចំណាយសរុបជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះ៖

- ចំពោះការអនុវត្តសកម្មភាពនានានៃសេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្ត បានចំណាយថវិកាសរុប**ចំនួន ៤០.៤១៥ លានរៀល សមមូល ១០ លានដុល្លារ ស្មើនឹង ៣៤%** ធៀបនឹងថវិកាគ្រោងមាន**ចំនួន ១១៩.០៩៧ លានរៀល សមមូល ២៩,៧ លានដុល្លារ** ដូចរៀបរាប់សង្ខេបក្នុងតារាង និងក្រាហ្វិកដូចខាងក្រោម។

**តារាងទី៧ ៖ សង្ខេបការអនុវត្តថវិកាឆមាសទី១ ឆ្នាំ២០២៤ (គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកាគ្រោង | | ការចំណាយ | |
|---|---|---|---|---|---|
| | | (លានរៀល) | (ដុល្លារ) | (លានរៀល) | (ដុល្លារ) |
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550 | 2,137,500 | 3,950 | 987,489 |
| ២ | ក្រសួង ស្ថាប័ននានា | 2,517 | 629,252 | 498 | 124,504 |
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 12,496 | 3,123,993 | 2,441 | 610,364 |
| ៤ | គម្រោង កម្មវិធីដាច់ដោយឡែកនានា | 95,534 | 23,883,500 | 33,525 | 8,381,347 |
| | **សរុប** | **119,097** | **29,774,245** | **40,415** | **10,103,704** |

*** តួលេខចំណាយគិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤*




- រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានចំណាយសរុបចំនួន **២.៣៨៧.៣០១ លានរៀល សមមូល ៥៨១ លានដុល្លារ ស្មើនឹង ៣៤%** នៃចំណូលសរុបដែលមានចំនួន **៦.៩៦៩.១៥៨ លានរៀល សមមូល ១.៧០០ លានដុល្លារ** ក្នុងនោះ រដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗបានអនុវត្តចំណាយដូចខាងក្រោម៖
  - រាជធានី ខេត្ត បានចំណាយសរុបចំនួន **១.២១០.៥៧៣ លានរៀល** សមមូល **២៩៥ លានដុល្លារ ស្មើនឹង ៣៤%** នៃចំណូលសរុបដែលមានចំនួន **៣.៥៦៣.៤៧៥ លានរៀល សមមូល ៨៦៩ លានដុល្លារ**
  - ក្រុង ស្រុក បានចំណាយសរុបចំនួន **៧១៤.៤១០ លានរៀល សមមូល ១៧៤ លានដុល្លារ ស្មើនឹង ៣២%** នៃចំណូលសរុបដែលមានចំនួន **២.២៥៥.២៨៥ លានរៀល សមមូល ៥៥០ លានដុល្លារ**
  - ឃុំ សង្កាត់ បានចំណាយសរុបចំនួន **៤៦២.៣១៨ លានរៀល សមមូល ១១២ លានដុល្លារ ស្មើនឹង ៤០%** នៃចំណូលសរុបដែលមានចំនួន **១.១៥០.៣៩៩ លានរៀល សមមូល ២៨១ លានដុល្លារ**។

| ល.រ. | ធនធានហិរញ្ញវត្ថុ | ថវិកាគ្រោង | | ការចំណាយ | |
|---|---|---|---|---|---|
| | | (លានរៀល) | (លានដុល្លារ) | (លានរៀល) | (លានដុល្លារ) |
| ១ | រាជធានី ខេត្ត | 3,563,475 | 869 | 1,210,573 | 295 |
| ២ | ក្រុង ស្រុក | 2,255,285 | 550 | 714.410 | 174 |
| ៣ | ឃុំ សង្កាត់ | 1,150,399 | 281 | 462.318 | 112 |
| | **សរុប** | **6,969,158** | **1,700** | **2,387,301** | **581** |

*** តួលេខចំណាយគិតត្រឹមខែមិថុនា ឆ្នាំ២០២៤*




## ៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

ក្នុងការអនុវត្ត ផ.ស.ថ. ប្រចាំឆមាសទី១ ឆ្នាំ២០២៤នេះ មានបញ្ហាប្រឈមជាគន្លឹះមួយចំនួនរួមមាន៖

- ការគាំទ្រទាំងផ្នែកបច្ចេកទេសនិងសមត្ថភាព និងការតាមដាន ត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិពីក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួននៅពុំទាន់អនុវត្តបានពេញលេញ ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ ដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមានដែលចាំបាច់ត្រូវពង្រឹងការគាំទ្រ និងការតាមដានត្រួតពិនិត្យបន្ថែមទៀត
- បើទោះបីជាមានការសម្របសម្រួល និងការពិភាក្សាគ្នាក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ដើម្បីធានាដល់ភាពប្រទាក់ក្រឡាគ្នា ការគាំទ្រគ្នាទៅវិញទៅមក និងការធានាដល់ភាពសុខដុមនីយកម្មនៃកំណែទម្រង់នានា ក៏ប៉ុន្តែនៅមានបញ្ហាមួយចំនួនដែលពុំទាន់អនុវត្តឱ្យបានស្របគ្នា មានសង្គតិភាពជាមួយគ្នា និងគាំទ្រគ្នាទៅវិញទៅមកឱ្យបានពេញលេញនៅឡើយ ដែលបញ្ហានេះចាំបាច់ត្រូវមានការពិភាក្សាគ្នា និងសម្របសម្រួលបន្ថែមទៀត
- ការទទួលខុសត្រូវក្នុងការអនុវត្តមុខងារដែលបានផ្ទេរនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅជួបបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ត្រូវពិនិត្យ និងដោះស្រាយរួមមាន៖ (១) ការសិក្សា និងកំណត់ទំហំថវិកាសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារទាំង៥៥ ក្នុងវិស័យចំនួន១៩ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០២០ (២) កង្វះបុគ្គលិក និងសមត្ថភាពជំនាញនៅថ្នាក់ក្រុង ស្រុក (៣) បុគ្គលិកជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញតាមវិស័យនីមួយៗឱ្យបានច្បាស់លាស់ និងពេញលេញ (៤) ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំបច្ចេកទេសក្នុងវិស័យមួយចំនួន ដើម្បីជាមូលដ្ឋានសម្រាប់ប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ (៥) ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវមុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នា

មុខតំណែងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ប្រសិទ្ធភាព នៃការបំពេញមុខងារ និងការប្រើប្រាស់ធនធាននានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការគាំទ្រផ្នែកបច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ទៅរដ្ឋបាលឃុំ សង្កាត់នៅពុំទាន់អនុវត្តបានល្អប្រសើរស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន រួមមានដូចជា ការគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំសិក្សាលទ្ធភាពគម្រោង ការគាំទ្របច្ចេកទេស ការតាមដានត្រួតពិនិត្យកិច្ចលទ្ធកម្មឃុំ សង្កាត់ ការអនុវត្តគម្រោង និងការអភិវឌ្ឍសមត្ថភាព ជាដើម ដែលបញ្ហានេះចាំបាច់ ត្រូវពង្រឹងការទទួលខុសត្រូវរបស់អង្គភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ ដើម្បីផ្តល់ការដល់ឃុំ សង្កាត់
- យន្តការ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បើទោះបីជាត្រូវបានពង្រឹងនិងកែលម្អជាបណ្តើរៗក៏ដោយ ក៏ចាំបាច់ត្រូវពន្លឿនការរៀបចំយន្តការ និងនីតិវិធីទាំងនេះឱ្យកាន់តែមានភាពងាយស្រួល ឆាប់រហ័ស និងតម្លាភាពតាមរយៈការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល។

## ៥. សកម្មភាពជាអាទិភាពសម្រាប់ឆមាសទី២ ឆ្នាំ២០២៤

សកម្មភាពជាអាទិភាពតាមសមាសភាគនីមួយៗ ដែលត្រូវអនុវត្តសម្រាប់ឆមាសទី២ ឆ្នាំ២០២៤ មានដូចខាងក្រោម៖

### សមាសភាគទី១÷ ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់

១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

៦. ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

១០. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង (យុទ្ធសាស្ត្រដែលមានស្រាប់)

១១. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង

១២. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២

១៣. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

១៤. ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

១៥. ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬ អង្គការសង្គមស៊ីវិលនានាដោយបន្សីជាមួយកជទី២

១៦. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

១៧. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

១៨. រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា

១៩. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

២០. ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

២១. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

**សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ រដ្ឋបាលក្រុង ស្រុក

២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់

៣. ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន

៤. ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ

៥. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់

៦. ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី

៧. ការពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសៗគ្នា

៨. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

៩. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

១០. ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១១. ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ

១៣. ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ

១៤. ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ

១៥. ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

១៦. ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៧. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

១៨. ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ

២. ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាល ថ្នាក់ក្រោមជាតិ

៣. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ

៦. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រង ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

៧. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ

៨. ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក

៩. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១០. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១១. លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៣. ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព

១៤. ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

១៥. ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព

១៦. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៧. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

១៨. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា

១៩. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

**សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការរដ្ឋបាលថ្នាក់ក្រោមជាតិ**

១. ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

៤. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់

៦. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា

៧. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៨. ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

៩. ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា

១០. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

១១. ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាវៈភាព និងកញ្ចប់ថវិកាពិសេស

១៣. ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**

១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

៤. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

៦. ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន

៧. ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ

៨. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

៩. ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

១០. ការវិនិយោគសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

## ៦. សេចក្តីសន្និដ្ឋាន

ជារួម ក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការចូលរួមគាំទ្រ និងអនុវត្តយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ កម្មវិធីកំណែទម្រង់នេះ សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ ការពង្រឹងការគ្រប់គ្រង និងការចាត់ចែងអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងការពង្រឹងការផ្តល់សេវាសាធារណៈ ព្រមទាំងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ។

តាមរយៈកម្មវិធីកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងជាបណ្តើរទៅជាស្ថាប័នដែលមានភាពរឹងមាំ មានសមត្ថភាព មានសិទ្ធិអំណាច មានមុខងារ និងធនធាន និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងរួមចំណែកសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤នេះ មានមុខងារប្រមាណ ៦០ក្នុងវិស័យចំនួន២០ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារផ្តល់សេវារដ្ឋបាលប្រមាណជាង ៨០០ប្រភេទត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយ។ ឆ្នាំ២០២៤នេះ ការផ្ទេរថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងពី**ចំនួន ៥.១៦៣.៦០៥ លានរៀល ស្មើនឹង ១.២៥៩,៤១ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដល់ចំនួន ៦.៩៦៩.១៥៨ លានរៀល ស្មើនឹង ១.៧០០ លានដុល្លារ ក្នុងឆ្នាំ២០២៤**។ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារជាជម្រើសរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងធ្វើការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង **២.៩៦០គម្រោង** ក្នុងឆ្នាំ២០២៤ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ដែលជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

ទន្ទឹមនឹងវឌ្ឍនភាព និងសមិទ្ធផលខាងលើនេះ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ និងដោះស្រាយជាបន្តបន្ទាប់ក្នុងឆ្នាំ២០២៤នេះ និងបន្តនាឆ្នាំខាងមុខ ដើម្បីឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលរំពឹងទុកនានាស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០២១-២០៣០)។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

## ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពចំនួន៨៧ ធៀបនឹងចំណុចដៅដែលគ្រោងក្នុងឆមាសទី១ ឆ្នាំ២០២៤

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| 1 | **ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖**<br>**យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | | |
| 1.1 | **យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាបន្ន** | | | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | 1 | 1 | **បានបញ្ចប់** | - គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំលើកទី២២របស់ខ្លួន នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤ ដែលមានសមាសភាពចូលរួមចំនួន១៥០នាក់ ដោយបានពិនិត្យពិភាក្សា និងអនុម័តលើរបៀបវារៈសំខាន់ៗរួមមាន៖ (១) ការអនុម័តកំណត់ហេតុកិច្ចប្រជុំលើកទី២១ របស់ គ.ជ.អ.ប. (២) ការអនុម័តលើរបាយការណ៍នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣របស់ គ.ជ.អ.ប. (៣) ការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (៤) ពិនិត្យ និងផ្តល់ការឯកភាពលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. និង (៥) របៀបវារៈផ្សេងៗពាក់ព័ន្ធនឹងការជំរុញ និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលរាជធានី ខេត្តក្នុងការចុះបញ្ជីគម្រោងវិនិយោគក្រោម៥លានដុល្លារ ការបន្តពង្រឹងនិងពង្រីកវិសាលភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក និងការពន្លឿនការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។<br>- គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចង្អៀតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ការអនុវត្តការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូលក្រោម៥លានដុល្លារនៅថ្នាក់រាជធានី ខេត្ត ព្រមទាំងដាក់ចេញនូវវិធានការក្នុងការជំរុញការរៀបចំការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរអង្គភាពក្នុងការចុះបញ្ជីគម្រោងវិនិយោគ ដែលមានទុនសមមូល៥លានដុល្លារចុះ។ |
| | | 2. ចំនួនសុបលិខិតបទដ្ឋាន/ឯកសារដែលបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. | ឯកសារ | 4 | 2 | 2 | **បានបញ្ចប់** | - (១) ការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (២) ពិនិត្យ និងផ្តល់ការឯកភាពលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប.។ |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព | 3. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 6 | 3 | 1 | **កំពុងដំណើរការ** | - អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ដែលមានការចូលរួមពីសមាជិកអនុគណៈកម្មាធិការមុខងារ និងធនធាន  តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ  តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំនេះ ដឹកនាំដោយឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯក**ឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដែលមានគោលបំណងដើម្បី៖ (១) ប្រកាសសមាសភាពថ្មីនៃអនុគណៈកម្មាធិការមុខងារ និងធនធាន (២) ពិនិត្យ និងពិភាក្សាលើស្ថានភាពនៃការអនុវត្តមុខងារក្នុងវិស័យការងារ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយថ្នាក់រាជធានី ខេត្ត និង (៣) ពិនិត្យ និងពិភាក្សាលើបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 4. រចនាសម្ព័ន្ធនៃអង្គភាពចំណុះនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល | រចនាសម្ព័ន្ធ | អនុម័ត | 1 | សេចក្តីព្រាង | **កំពុងដំណើរការ** | - លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំការវិភាគមុខងារ រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងការរៀបចំការពិពណ៌នាមុខតំណែង ការកំណត់អំពីតម្រូវការធនធានមនុស្ស ព្រមទាំងតម្រូវការអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីបុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប.។ |
| | | 5. ចំនួនសរុបវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់បុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | វគ្គ | 4 | 2 | 3 | **បានបញ្ចប់** | - លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវ រួមមាន៖ (១) បានចាត់តាំងមន្ត្រីជាន់ខ្ពស់ចំនួន ០១រូប នៃលេខាធិការដ្ឋាន គ.ជ.អ.ប. ចូលរួមទស្សនកិច្ចសិក្សានៅប្រទេសថៃ ស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី១៤-១៧ ខែឧសភា ឆ្នាំ២០២៤ (២) បានបញ្ជូនមន្ត្រីជាថ្នាក់ដឹកនាំចំនួន០៣នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ជំនាន់៦ នៅសាលាភូមិន្ទរដ្ឋបាល ដែលមានរយៈពេល៣ខែ ចាប់ផ្តើមពីខែមីនា ដល់ខែមិថុនា ឆ្នាំ២០២៤ (៣) បានចាត់តាំងមន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាស្តីពីការពង្រឹងភាពជាដៃគូក្នុងតំបន់សម្រាប់ការប្រែប្រួលអាកាសធាតុនៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៤ នៅទីក្រុងបាងកក ប្រទេសថៃ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធ ជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍក្នុងតំបន់នានា និងមានការរៀបចំឡើងដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP)។ សិក្ខាសាលានេះ គឺជាវេទិកាមួយសម្រាប់ការផ្លាស់ប្តូរថ្នាក់តំបន់ ការចែករំលែកបទពិសោធការអនុវត្តល្អបំផុត និងផ្តល់នូវមធ្យោបាយឆ្ពោះទៅមុខ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការរៀនសូត្រជាក់ស្តែងពីបទពិសោធការងារនៅតាមបណ្តាប្រទេសនានានៅអាស៊ីខាងត្បូង និងតំបន់អាស៊ីអាគ្នេយ៍។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 6. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 48 | 24 | 24 | **បានបញ្ចប់** | – គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ.ឆ្នាំ២០២៤ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២១ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត។ |
| | | 7. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត | កិច្ចប្រជុំ | 50 | 25 | 25 | **បានបញ្ចប់** | – គ.ដ.វ.វ. នៃរដ្ឋបាលរាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត។ |
| | | 8. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក | កិច្ចប្រជុំ | 388 | 194 | 194 | **បានបញ្ចប់** | – គ.ដ.វ.វ. នៃរដ្ឋបាលក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត។ |
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 9. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 2 | 2 | **បានបញ្ចប់** | – លេខាធិការដ្ឋាននៃកំណែទម្រង់ទាំង០៥ ដែលរួមមានកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បានចុះធ្វើការសិក្សាឈ្វេងយល់អំពីការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងថវិកា និងក្របខ័ណ្ឌគណនេយ្យភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាព និងកំណត់បញ្ហាប្រឈម និងសំណើដំណោះស្រាយក្នុងទិដ្ឋភាពនៃកំណែ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ទម្រង់ទាំង៥នៅខេត្តប៉ៃលិន កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ និងខេត្តបាត់ដំបង កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤<br>- បានចូលរួមកិច្ចប្រជុំ និងវិបស្សនាប្រចាំឆ្នាំស្តីពីយន្តការអន្តរកំណែទម្រង់ស្នូលទាំង៥របស់រាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមនៃកែទម្រង់ទាំង៥នៃរាជរដ្ឋាភិបាល ដោយបានឯកភាពទៅលើការកែសម្រួលយន្តការពី "កែទម្រង់៣បូក១" និងបន្ថែមយន្តការកែទម្រង់ច្បាប់ ទៅជាយន្តការអន្តរកំណែទម្រង់គន្លឹះទាំង៥ ដើម្បីសុំការសម្រេចពីប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ និងការពិនិត្យសម្រេចពីប្រមុខរដ្ឋាភិបាល។ |
| | | 10. ផែនការសកម្មភាពរួមប្រចាំឆមាសដែលបានរៀបចំ | ផែនការ | 2 | 1 | 1 | **បានបញ្ចប់** | - លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួលរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់៣បូក១ និងរៀបចំសកម្មភាពអាទិភាពសម្រាប់រយៈពេល៦ខែដើមឆ្នាំ២០២៤ ដើម្បីត្រៀមកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ (យ.ស.ក.) ដែលដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប.<br>- បានសហការជាមួយកំណែទម្រង់៤ផ្សេងទៀតក្នុងការរៀបចំផែនការសកម្មភាពរួមនៃកំណែទម្រង់ទាំង៥សម្រាប់ឆមាសទី២ ឆ្នាំ២០២៤ និងសម្រាប់ឆ្នាំ២០២៥ ព្រមទាំងបានពិនិត្យកែសម្រួលអនុក្រឹត្យស្តីពីយន្តការសុខដុមនីយកម្មនៃកំណែទម្រង់គន្លឹះទាំង៥។ |
| 1.1.6 | ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាល | 11. ការសិក្សាអំពីការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាល | សិក្សា | 1 | | 1 | **បានបញ្ចប់** | - បាននិងកំពុងរៀបចំកិច្ចដំណើរការវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្នុងនោះកិច្ចការដែលសម្រេចបានរួមមាន (១) រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារទស្សនទានស្តីពីការរៀចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ (២) គ.ជ.អ.ប. បាន |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | ថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា | នៃរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | ដាក់ចេញសេចក្តីណែនាំស្តីពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងសេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលា សម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) បានផ្សព្វផ្សាយឯកសារទស្សនទាន និងសេចក្តីណែនាំស្តីពីការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានផ្តល់ការគាំទ្រទាំងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) រដ្ឋបាលឃុំ សង្កាត់ទាំង១.៦៥២ បានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ខ្លួន ដើម្បីកំណត់អំពីបញ្ហាប្រឈមជាគន្លឹះនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់ខ្លួនឯង និងបញ្ហាប្រឈមដែលត្រូវស្នើឱ្យរដ្ឋបាលថ្នាក់លើបន្តបន្ទាប់ធ្វើអន្តរាគមន៍ដោះស្រាយ<br>- បានរៀបចំនូវសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនង គណនេយ្យភាព និងការទទួលខុសត្រូវរវាងក្រុមប្រឹក្សា និងគណៈអភិបាល ការពិភាក្សានិងការផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនិងសេចក្តីសម្រេចចិត្តនានា ការដឹកនាំសម្របសម្រួល ព្រមទាំងការកំណត់នូវបញ្ហាប្រឈម និងអនុសាសន៍សម្រាប់លើកសំណើកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ប្រកបដោយភាពស្ថាបនា | 12. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | 1 | 1 | **បានបញ្ចប់** | - លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងពិនិត្យ និងកែសម្រួលទៅលើលក្ខខណ្ឌការងាររបស់ក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | នៅថ្នាក់ក្រោមជាតិ (TWG) ដើម្បីឱ្យមានលក្ខណៈសមស្របទៅតាមស្ថានភាព នៃការវិវត្តនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>- បានរៀបចំផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំក្រុមការងារបច្ចេកទេសវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ភាគីខាងរាជរដ្ឋាភិបាល) ដែលរួមមាន (១) **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃគ.ជ.អ.ប. ជាប្រធានក្រុមការងារ និង** (២) **ឯកឧត្តម ចាន់ សុជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាប្រធានលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេស**<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. បានជួបប្រជុំពិភាក្សាជាមួយតំណាងស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជាអំពីការបន្សីរវាងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការអភិវឌ្ឍន៍ភាពជាដៃគូឆ្នាំ២០២៤-២០២៨ រវាងរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា។ |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 13. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់រាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 300 | 150 | 150 | **បានបញ្ចប់** | - គ.ក.ស.ក រាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំជារៀងរាល់ខែបានទៀងទាត់ ដើម្បីពិនិត្យមើលសកម្មភាពនានាទាក់ទងអំពីហិង្សា ជនងាយរងគ្រោះជាស្ត្រី និងកុមារ ការផ្តល់យោបល់លើថែទាំមាតាមានផ្ទៃពោះ ការអប់រំកុមារ និងការរក្សាអនាម័យ  ដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហា  និងបានជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិដល់អភិបាល អភិបាលរងជាស្ត្រី នាយករដ្ឋបាល និងនាយករងរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ទាំង១៣ នៃខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប ៤៩នាក់ (ស្ត្រី២១នាក់) ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 14. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់ក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំ | កិច្ចប្រជុំ | 2,496 | 1,248 | 1,248 | **បានបញ្ចប់** | - គ.ក.ស.ក. ក្រុង ស្រុក ខណ្ឌ បានរៀបចំកិច្ចប្រជុំជារៀងរាល់ខែបានទៀងទាត់ ដើម្បីពិនិត្យមើលសកម្មភាពនានាទាក់ទងអំពីហិង្សា ជនងាយរងគ្រោះជាស្ត្រី និងកុមារ ការផ្តល់យោបល់លើថែទាំមាតាមានផ្ទៃពោះ ការអប់រំកុមារ និងការរក្សាអនាម័យ ដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហា និងបានជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិដល់អភិបាល អភិបាលរងជាស្ត្រី នាយករដ្ឋបាល និងនាយករងរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ទាំង១៣ នៃខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប ៤៩រូប (ស្ត្រី២១រូប) ។ |
| **1.2** | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | | | | | | | |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 15. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | 1 | 1 | 1 | **កំពុងដំណើរការ** | - បាននិងកំពុងបន្តសហការជាមួយនឹងអង្គការ GIZ ក្នុងការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយមានការគាំទ្រពីទីប្រឹក្សាឯករាជ្យដែលជ្រើសរើសឡើងដោយអង្គការ GIZ និងគ្រោងបញ្ចប់នៅដំណាច់ឆ្នាំ២០២៤នេះ<br>- បាននិងកំពុងកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយប្រមូលធាតុចូលពីរដ្ឋបាលរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តរតនគិរី ដើម្បីកែសម្រួលសៀវភៅយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដោយគ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៤។ |
| 1.2.2 | | 16. ចំនួនសរុបវេទិកា ឬកម្មវិធីផ្សព្វផ្សាយ | វេទិកា | 12 | 6 | 26 | **បានបញ្ចប់** | - បានរៀបចំវីដេអូឯកសារអំពីការងារគណនេយ្យភាពសង្គម និងបានផ្សព្វផ្សាយជូនថ្នាក់ដឹកនាំក្នុងដំណើរទស្សនកិច្ចស្តីពីការងារគណនេយ្យភាពសង្គមរបស់ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | អំពីចក្ខុវិស័យ គោលដៅ និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ | | | | | | គណៈប្រតិភូជាតិ និងអន្តរជាតិដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ នៅខេត្តកំពត និងបានសម្របសម្រួលជាមួយស្ថាប័នអ្នកសារព័ត៌មានចំនួន ៧ ស្ថាប័ន និងទូរទស្សន៍ BTV ដើម្បីបន្តផ្សព្វផ្សាយព័ត៌មានអំពីការងារគណនេយ្យភាពសង្គម<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. បានផ្សព្វផ្សាយព័ត៌មានសរុបចំនួន **២៥ព័ត៌មាន** សំខាន់ៗដូចជា ព័ត៌មានកិច្ចប្រជុំរបស់លេខាធិការដ្ឋាន ដំណើរទស្សនកិច្ចស្តីពីការងារគណនេយ្យភាពសង្គមរបស់គណៈប្រតិភូជាតិ អន្តរជាតិ សារលិខិតជូនពរ ឯកសារសេចក្តីសម្រេចនានា បេសកកម្មជាមួយដៃគូអភិវឌ្ឍន៍ និងវគ្គបណ្តុះបណ្តាលផ្សេងៗ ដាក់ក្នុងប្រព័ន្ធបណ្តាញសង្គម Facebook និង Telegram ក្នុងនោះមានសេចក្តីប្រកាសចំនួន០២ បានដាក់ចូលក្នុងគេហទំព័រ និងវីដេអូចំនួន០៣ បានដាក់ចូលក្នុងបណ្តាញ YouTube របស់លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- បាននិងកំពុងពិនិត្យកែសម្រួលលើផែនការសកម្មភាព និងថវិកា និងពិនិត្យបញ្ចប់លើលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសក្រុមហ៊ុនជំនាញអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តសាកល្បង និងបានរៀបចំគោលការណ៍អនុវត្តទៅតាមនីតិវិធីលទ្ធកម្ម ដើម្បីដំណើរការជ្រើសរើសទីប្រឹក្សា<br>- បានរៀបចំបទដ្ឋានបច្ចេកទេស និងធ្វើលទ្ធកម្មទិញម៉ាស៊ីនមេ (Server) ចំនួន០២គ្រឿងសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 17. ចំនួនសរុបឯកសារព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 5 | 2 | 2 | **បានបញ្ចប់** | - លេខាធិការដ្ឋាន គ.ជ.អ.ប. បានបញ្ចូលឯកសារនានាពាក់ព័ន្ធនឹងកំណែទម្រង់ស្ថាលរបស់រាជរដ្ឋាភិបាល និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិករបស់ គ.ជ.អ.ប. បានចំនួន **១២.៣៥០ ឯកសារ** និងត្រៀមបញ្ចូលនូវឯកសារប្រមាណ **១៣.៥៧៧ ឯកសារបន្ថែម** ទៀតទៅក្នុងបណ្ណាល័យអេឡិចត្រូនិកនេះ |
| **1.3** | **កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | | |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 18. ផ.ស.ថ. ឆ្នាំ២០២៤ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ. | 1 | 1 | 1 | **បានបញ្ចប់** | - ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៤ របស់ គ.ជ.អ.ប. និងរបាយការណ៍នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ របស់ គ.ជ.អ.ប. បានអនុម័តនាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ និងបានបោះពុម្ព ផ.ស.ថ. ឆ្នាំ២០២៤ ចំនួន ១០០ក្បាល និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ ចំនួន ១០០ក្បាល ដើម្បីបែងចែក និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 19. ភាគរយសរុបសកម្មភាពអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២៤ ដែលសម្រេចបាន | ភាគរយ | 80% | 40% | 72.4% | **បានបញ្ចប់** | - ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង៨៧ និងសូចនាករចំនួន ១៣៩ នៃ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. មានសកម្មភាពជាអាទិភាព**ចំនួន ៧០ ស្មើនឹង ៨០% (បានបញ្ចប់ចំនួន ២៤ និងកំពុងអនុវត្ត ៤៦) និង សូចនាករចំនួន ១១៤ ស្មើនឹង ៨២%** ត្រូវបានអនុវត្ត ។ |
| | | 20. សេចក្តីព្រាង ផ.ស.ថ. ឆ្នាំ២០២៥ ត្រូវបានរៀបចំ | ផ.ស.ថ. | 1 | | 1 | **កំពុងដំណើរការ** | - គ.ជ.អ.ប. បានបញ្ជូនសេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥ ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងក្របខ័ណ្ឌពេលវេលា ត្រូវបានរៀបចំ និងបានបញ្ជូន |

| ក្រដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីត្រៀមដាក់បញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ដើម្បីធានាដល់ការចូលរួមអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ |
| | | 21. ចំនួនសរុបនៃសេចក្តីសម្រេចរួម ដែលបានរៀបចំ និងអនុម័ត | សេចក្តីសម្រេចរួម | 46 | 46 | 46 | **ប្បានបញ្ចប់** | - បានសម្របសម្រួល ពិនិត្យ និងអនុម័តសេចក្តីសម្រេចរួមឆ្នាំ២០២៤ រវាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និង គ.ជ.អ.ប. សរុបក្រសួង ស្ថាប័នចំនួន២០ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥។ |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 22. ចំនួនក្រសួងស្ថាប័នបានបញ្ចូលសកម្មភាពនៃផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 21 | 21 | 21 | **កំពុងដំណើរការ** | - ក្រសួង ស្ថាប័ន បាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥ ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងក្របខ័ណ្ឌពេលវេលា ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ (២០២៥-២០២៧) និងគម្រោងថវិកាឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ដើម្បីធានាដល់ការចូលរួមអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ |
| | | 23. ចំនួនរដ្ឋបាលរាជធានី ខេត្តបានបញ្ចូលសកម្មភាពនៃ ផអ៥ទី១ ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 25 | 25 | 25 | **កំពុងដំណើរការ** | - រដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥ ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងក្របខ័ណ្ឌពេលវេលា ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ (២០២៥-២០២៧) និងគម្រោងថវិកាឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ដើម្បីធានាដល់ការចូលរួមអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ |
| 1.3.6 | ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និង | 24. ការអង្កេតអភិបាលកិច្ច | ការអង្កេត | 1 | | 1 | **កំពុងដំណើរការ** | - បាន និងកំពុងដំណើរការរៀបចំការធ្វើអង្កេតអភិបាលកិច្ច ដែលត្រូវអនុវត្តដោយក្រុមហ៊ុនឯករាជ្យ ក្រោមការគាំទ្រហិរញ្ញប្បទានឥតសំណងរបស់ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | ការវាយតម្លៃលើការអនុវត្តកជទី២ | | | | | | | រាជរដ្ឋាភិបាលជប៉ុនតាមរយៈគម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA) ដែលកំពុងដំណើរការវាយតម្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សាសម្រាប់ធ្វើការអង្កេតអភិបាលកិច្ច និងត្រៀមរៀបចំផ្តល់កិច្ចសន្យាដែលនឹងចាប់ផ្តើមអនុវត្តនៅដើមត្រីមាសទី៣ឆ្នាំ២០២៤ គ្របដណ្តប់ទូទាំង ២៥រាជធានី ខេត្ត។ |
| | | 25. ការវាយតម្លៃលើការអនុវត្តកជទី១ | ការវាយតម្លៃ | 1 | | 1 | **កំពុងដំណើរការ** | - បាននិងកំពុងដំណើរការរៀបចំវាយតម្លៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ (២០១០-២០២០) ដែលធ្វើឡើងដោយក្រុមទីប្រឹក្សាឯករាជ្យ ក្រោមការគាំទ្រហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈគម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA) ដែលសម្រេចបានលទ្ធផល រួមមាន (១) បានបញ្ចប់ការរៀបចំរបាយការណ៍ចាប់ផ្តើមដំបូង (២) បានរៀបចំចងក្រងបញ្ជីសំណួរ និងផែនការសកម្មភាពសម្រាប់ការវាយតម្លៃ (៣) បាននិងកំពុងចុះប្រមូលព័ត៌មាន និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានានៃស្ថាប័នសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ទៅលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១។ |
| | | 26. របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. | របាយការណ៍ | 1 | 1 | 1 | **កំពុងដំណើរការ** | - លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំរបាយការណ៍ប្រចាំឆមាសទី១នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប.។ |
| | | 27. សវនកម្មយេនឌ័រ | ការអង្កេត | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| **1.5** | **ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់** | | | | | | | |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 28. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 2 | 3 | **បានបញ្ចប់** | - សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ច រួមមានកិច្ចប្រជុំក្រុមប្រឹក្សាជាតិ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ និងកិច្ចប្រជុំថ្នាក់ដឹកនាំ ក្នុងគោលបំណង ដើម្បីពង្រឹងកិច្ចដំណើរការរបស់សមាគម។ |
| | | 29. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន ដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 2 | 2 | **បានបញ្ចប់** | - សមាគមជាតិក្រុមប្រឹក្សាមូលដ្ឋាន បានរៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ច រួមមានកិច្ចប្រជុំក្រុមប្រឹក្សាជាតិ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ និងកិច្ចប្រជុំថ្នាក់ដឹកនាំ ក្នុងគោលបំណង ដើម្បីពង្រឹងកិច្ចដំណើរការរបស់សមាគម។ |
| | | 30. ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ផែនការ | 1 | | 1 | **កំពុងដំណើរការ** | - រៀបចំឯកសារទស្សនទានស្តីពីការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យសមាគមទាំងនេះកាន់តែមានសមត្ថភាពក្នុងការចូលរួមលើកកម្ពស់កិច្ចដំណើរកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ |
| | | 31. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត | វគ្គ | 4 | 2 | 1 | **កំពុងដំណើរការ** | - បានរៀបចំដំណើរការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សានៅខេត្តគោលដៅ គឺខេត្តកំពត និងខេត្តសៀមរាបអំពី "ការត្រៀមបម្រុងការឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួមពីថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន សមាជិកក្រុមប្រឹក្សាខេត្តកំពត និងខេត្តសៀមរាប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់មួយចំនួននៅខេត្តកំពត និងខេត្តសៀមរាប។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 32. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | វគ្គ | 4 | 2 | 1 | **កំពុងដំណើរការ** | - បានរៀបចំវគ្គបណ្តុះបណ្តាលជូនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ប្រមាណ ២០វគ្គ។ វគ្គបណ្តុះបណ្តាលមានគោលបំណងបង្កើនសមត្ថភាពសមាជិកក្រុមប្រឹក្សា ដើម្បីឈ្វេងយល់កាន់តែស៊ីជម្រៅលើការអនុវត្តតួនាទី ការគ្រប់គ្រង និងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។ |
| 1.5.2 | ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 33. ការសិក្សាអំពីជម្រើសនានាត្រូវបានអនុវត្ត | ការសិក្សា | 1 | | 1 | **កំពុងដំណើរការ** | - បាននឹងកំពុងរៀបចំឯកសារទស្សនទាន និងផែនការសកម្មភាព ព្រមទាំងការកៀរគរការគាំទ្រសម្រាប់ការសិក្សាអំពីជម្រើសនៃការរៀបចំរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 1.5.4 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | 34. ការសិក្សា និងរៀបចំយុទ្ធសាស្ត្រនៃការចូលរួមរបស់អង្គការសង្គមស៊ីវិល | ការសិក្សា | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| | | 35. ចំនួនកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលលើការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់ | កិច្ចប្រជុំ | 2 | 1 | 2 | **បានបញ្ចប់** | - បានគាំទ្រ និងសហការជាមួយអង្គការសង្គមស៊ីវិលចំនួន១៩ ក្នុងការរៀបចំ និងអនុវត្តការងារគណនេយ្យភាពសង្គម ព្រមទាំងរៀបចំឱ្យមានវេទិកាពិគ្រោះយោបល់ទៅលើប្រសិទ្ធភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្តល់អនុសាសន៍សម្រាប់ការកែលម្អ និងការឈានទៅរៀបចំផែនការអនុវត្តជំហានបន្តបន្ទាប់ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល<br>- បានសហការជាមួយអង្គការសម្ព័ន្ធភាពដៃគូ ដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងការរៀបចំកិច្ចសន្ទនាថ្នាក់ជាតិស្តីពីការវិភាជថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហា |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ប្រឈម និងការកំណត់នូវអនុសាសន៍សម្រាប់ការកែលម្អគោលនយោបាយ លិខិតបទដ្ឋាន និងគោលការណ៍នានាពាក់ព័ន្ធទៅនឹងការវិភាជថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីតំណាងស្ថាប័ននីតិបញ្ញត្តិ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តំណាងស្ថានទូតមួយចំនួន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ |
| 2 | **រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖**<br>**រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ** | | | | | | | |
| **2.1** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ** | | | | | | | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង ស្រុក | 36. ភាគរយសរុបនៃក្រុង ស្រុក ខណ្ឌដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | ភាគរយ | 20% | 10% | 20% | **បានបញ្ចប់** | - បានផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលមានសិក្ខាកាមចូលរួមចំនួន ៩៦៨រូប (ស្ត្រីចំនួន ១៣១រូប)<br>- បានផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសអំពីការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៥ របស់ការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សា មត្តេយ្យសិក្សា និងមជ្ឈមណ្ឌលក្រៅប្រព័ន្ធ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសាធារណការ និងដឹកជញ្ជូនបានចុះត្រួតពិនិត្យវាយតម្លៃលើមុខងារដែលបានផ្ទេរពាក់ព័ន្ធនឹងការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក នៅខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប ខេត្តតាកែវ ខេត្តកណ្តាល និង |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ខេត្តស្វាយរៀង ដែលមានសមាសភាពចូលរួមសរុប ៤០៨រូប ស្រី ៨១រូប ព្រមទាំងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រង និងការផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកដល់មន្ត្រីអនុវត្តមុខងារនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ នៅខេត្តត្បូងឃ្មុំ ដោយមានអ្នកចូលរួមសរុបចំនួន ២៧៣រូប ដែលជាថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ត្រីបច្ចេកទេសនៃអង្គភាពច្រកចេញចូលតែមួយខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ព្រមទាំងមន្ត្រីការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុកទាំង៨នេះផងដែរ។ |
| | | 37. មុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសត្រូវបានកំណត់ | លិខិតបទដ្ឋាន | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំអំឡុងឆមាសទី២។ |
| | | 38. ភាគរយសរុបនៃមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដែលមានសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | ភាគរយ | 70% | 60% | 57% | **កំពុងដំណើរការ** | - ការរៀបចំដាក់ចេញនូវសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ<br>- បានរៀបចំបញ្ចប់សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការតែងតាំងនាយក នាយិកា នាយករងនាយិការងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ និងកំពុងដំណើរការពិនិត្យពិភាក្សា ដែលសម្របសម្រួលដោយក្រសួងមុខងារសាធារណៈ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | - បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យានៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ។ |
| | | 39. ទិន្នន័យដើមគ្រាសម្រាប់មុខងារអប់រំត្រូវបានរៀបចំ | របាយការណ៍ | 1 | 1 | 1 | **កំពុងដំណើរការ** | - បានរៀបចំប្រមូល និងចងក្រងទិន្នន័យដើមគ្រាក្នុងវិស័យអប់រំ យុវជន និងកីឡានៅតាមក្រុង ស្រុកចំនួន៣១ នៃរាជធានី ខេត្តចំនួន៦ ដូចជារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តស្វាយរៀង និងខេត្តមណ្ឌលគិរី និងបានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ និងការផ្តល់គោលការណ៍ណែនាំបន្ថែមដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមុខងារអប់រំដែលបានផ្ទេរ។ |
| | | 40. ការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល | របាយការណ៍ | 1 | 1 | 1 | **កំពុងដំណើរការ** | - បានសហការជាមួយក្រសួងសុខាភិបាលក្នុងការរៀបចំក្រុមការងារអន្តរក្រសួងសម្រាប់ការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល ដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត<br>- បានរៀបចំឯកសារទស្សនទានស្តីពីការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល ដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ។ |
| | | 41. ការសិក្សាអំពីលទ្ធភាពបង្កើតការិយាល័យសុខាភិបាលនៅថ្នាក់ក្រុង ស្រុក | របាយការណ៍ | 1 | | 1 | **កំពុងដំណើរការ** | - បានសិក្សាពីលទ្ធភាពក្នុងការផ្ទេរមុខងារសុខាភិបាលពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ និងលទ្ធភាពក្នុងការបង្កើតការិយាល័យសុខាភិបាលនៃរដ្ឋបាលក្រុង ស្រុក។ |
| 2.1.2 | | 42. ភាគរយឃុំ សង្កាត់ដែលទទួលបានការ | ភាគរយ | 5% | 2.5% | 2% | **កំពុងដំណើរការ** | - បានផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព គាំទ្របច្ចេកទេស ធនធានហិរញ្ញវត្ថុ និងផ្តល់សម្ភារៈផ្សព្វផ្សាយ (I4C) ដល់រដ្ឋបាលឃុំ សង្កាត់ចំនួន១.៥៤៥ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | គាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារ | | | | | | ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់សិទ្ធិអំណាច និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន<br>- បានចុះត្រួតពិនិត្យ តាមដានគាំទ្រ និងសិក្សាស្រាវជ្រាវអំពីការអនុវត្តមុខងារ ការគ្រប់គ្រងថវិកា ការរៀបចំនិងការអនុវត្តគម្រោង និងកិច្ចដំណើរការលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ចំនួន០៣លើក នៅក្នុងខេត្តកំពង់ចាម ខេត្តកណ្តាល និងរាជធានីភ្នំពេញ។ |
| | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 43. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយរាជធានី ខេត្តក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | **បានបញ្ចប់** | - រដ្ឋបាលរាជធានី ខេត្តបានផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤ - ២០២៦) និងការសិក្សាលទ្ធភាពគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៤។ |
| | | 44. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយក្រុង ស្រុកក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | **បានបញ្ចប់** | - នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បានគាំទ្រដល់ក្រុង ស្រុកក្នុងការអនុវត្តការងាររៀបចំផែនការក្រុង ស្រុក ការរៀបចំគម្រោងក្រុង ស្រុក ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារក្រុង ស្រុក និងការរៀបចំគោលនយោបាយគាំទ្រនានា<br>- រដ្ឋបាលក្រុង ស្រុក បានផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤ - ២០២៦) និងការសិក្សាលទ្ធភាពគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៤។ |
| 2.1.3 | ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន | 45. ការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជា | របាយការណ៍ | 1 | 1 | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំឆមាសទី២។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | សង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | | | | | | |
| | | 46. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំឆមាសទី២។ |
| 2.1.4 | ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ | 47. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំឆមាសទី២។ |
| **2.2** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | | | | | | | |
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត | 48. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរបស់រដ្ឋបាលខេត្ត | របាយការណ៍ | 1 | | 1 | **កំពុងដំណើរការ** | - បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធមុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត និងបានពិនិត្យពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានកំណត់អំពីផែនការសកម្មភាពសម្រាប់ការសិក្សាស្រាវជ្រាវអំពីជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | - បានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត តាមសេចក្ដីសម្រេចលេខ០១ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០២៤<br>- បានប្រមូលចងក្រងនូវលិខិតបទដ្ឋានគតិយុត្ត និងឯកសារមេរៀនបទពិសោធអំពីការគ្រប់គ្រងរដ្ឋបាលខេត្តពីបណ្ដាប្រទេសមួយចំនួនដូចជា ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសថៃស្ដីពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់តំបន់<br>- បានរៀបចំផែនការ និងដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធនៅប្រទេសឥណ្ឌូនេស៊ី ដែលគ្រោងធ្វើឡើងនៅត្រីមាសទី១ ឆ្នាំ ២០២៥ ដោយមានការគាំទ្រពីគម្រោង GIZ/ISD ក្រោមហិរញ្ញប្បទានពីប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស<br>- បានរៀបចំដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន១៩ រូប នៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ដែលបានគាំទ្រដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) និង GIZ។ ដំណើរទស្សនកិច្ចសិក្សានេះដឹកនាំដោយ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីសិក្សាឈ្វេងយល់អំពីមេរៀន និងពិសោធន៍ល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចនៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ព្រមទាំងពង្រឹង និង |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ពង្រីកទំនាក់ទំនងរវាងកម្ពុជា និងស្វីសក្នុងកិច្ចសហប្រតិបត្តិការនាពេលអនាគត។ |
| 2.3.1 | ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី | 49. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរដ្ឋបាលរាជធានី | របាយការណ៍ | 1 | | 1 | **កំពុងដំណើរការ** | - បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី និងបានពិនិត្យពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានកំណត់អំពីផែនការសកម្មភាពសម្រាប់ការសិក្សាស្រាវជ្រាវអំពីជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី<br>- បានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត តាមសេចក្តីសម្រេចលេខ០១ ស.ស.រ./គ.ជ.អ.ប ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០២៤<br>- បានប្រមូលចងក្រងឯកសារគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារមេរៀនបទពិសោធអំពីការគ្រប់គ្រងរដ្ឋបាលទីក្រុងមេត្រូប៉ូលីតែនពីបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន សាធារណរដ្ឋកូរ៉េ និងប្រទេសថៃស្តីពីការរៀបចំរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលមេត្រូប៉ូលីតែន។ |
| **2.4** | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 2.4.4 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | 50. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត | វេទិកា | 100 | 50 | 50 | **បានបញ្ចប់** | - រដ្ឋបាលរាជធានី ខេត្ត បានរៀបចំវេទិកាសាធារណៈ ដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារ ការផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបំពេញ តួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 51. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលក្រុង ស្រុក | វេទិកា | 776 | 388 | 388 | **បានបញ្ចប់** | - រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ បានរៀបចំវេទិកាសាធារណៈ ដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារ ការផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបំពេញតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| **2.5** | **សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | | |
| 2.5.3 | ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 52. ការសិក្សាអំពីលទ្ធភាព និងការរៀបចំកញ្ចប់ថវិកាគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | 1 | 1 | 1 | **កំពុងដំណើរការ** | - បាន និងកំពុងរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **2.6** | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 2.6.1 | ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | 53. ការសិក្សាអំពីជម្រើសនានាក្នុងការបង្កើតយន្តការផ្តល់ព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិជូនប្រជាពលរដ្ឋ | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 54. ភាគរយសរុបនៃឃុំ សង្កាត់ដែលអនុវត្តការងារគណនេយ្យភាពសង្គម | ភាគរយ | 93% | 93% | 93% | **បានបញ្ចប់** | - បាននិងកំពុងបន្តអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលឃុំ សង្កាត់ **ចំនួន ១.៥៤៥** ឃុំ សង្កាត់**ស្មើនឹង ៩៣%** នៃចំនួនឃុំ សង្កាត់**សរុប១.៦៥២** ដោយទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលអូស្ត្រាលី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ក្រោមការសម្របសម្រួលដោយធនាគារពិភពលោកតាមរយៈមូលនិធិបរធនបាលកិច្ច (Trust Fund)។ |
| | | 55. ការសិក្សា និងរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ត្រូវបានរៀបចំ | របាយការណ៍ | 1 | | 1 | **មិនទាន់អនុវត្ត** | - ផែនការអនុវត្តគណនេយ្យសង្គមដំណាក់កាលបន្ទាប់គ្រោងនឹងរៀបចំនៅឆ្នាំ២០២៥។ ការអនុវត្តការងារគណនេយ្យភាពសង្គមនាពេលបច្ចុប្បន្ននេះបាននិងកំពុងអនុវត្តផែនការអនុវត្តការងារគណនេយ្យភាព ដំណាក់កាលទី២ (២០១៩-២០២៣) និងត្រូវបានពន្យារហូតដល់ឆ្នាំ២០២៥ ដែលមានរយៈពេល០២ឆ្នាំ (២០២៥)។ |
| | | 56. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌលើសេវាតាមការិយាល័យច្រកចេញចូលតែមួយ | ភាគរយ | 17% | 17% | 18% | **បានបញ្ចប់** | - បាននិងកំពុងបន្តអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៣៧ ស្មើនឹង១៨% នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌសរុបចំនួន២០៩ ដោយទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលអូស្ត្រាលី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ក្រោមការសម្របសម្រួលដោយធនាគារពិភពលោកតាមរយៈមូលនិធិបរធនបាលកិច្ច (Trust Fund)<br>- បានរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសស្តីពីការបន្តអនុវត្ត និងពង្រីកការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ |
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 57. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជា | វគ្គ | 1 | 1 | 1 | **បានបញ្ចប់** | - បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងការប្រកាសជ័យលាភីការិយាល័យប្រជាពលរដ្ឋឆ្នើមប្រចាំឆ្នាំ២០២៣។ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ពលរដ្ឋរាជធានី ខេត្តត្រូវបានរៀបចំ | | | | | | |
| | | 58. ភាគរយបណ្ដឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | បណ្ដឹង | 80% | 80% | 57% | **កំពុងដំណើរការ** | - ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្ដឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន៨១១ករណី ក្នុងនោះបណ្ដឹងក្នុងសមត្ថកិច្ចចំនួន២២២ករណី **(បញ្ចប់ការដោះស្រាយចំនួន១២៨ករណី ស្មើ៥៧%** និងកំពុងដោះស្រាយចំនួន៩៤ករណី)។ បណ្ដឹងក្រៅសមត្ថកិច្ចចំនួន ២១០ករណី និងព័ត៌មានផ្សេងៗចំនួន៣៧៩ករណី (ការសរសើរចំនួន ៩២ករណី សំណើ និងសំណូមពរចំនួន ១២៤ករណី និងការសាកសួរព័ត៌មានចំនួន ១៦៣ករណី)។ |
| | | 59. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | វគ្គ | 1 | 1 | | **មិនទាន់អនុវត្ត** | - គ្រោងនឹងអនុវត្តនៅអំឡុងឆមាសទី២។ |
| | | 60. ភាគរយបណ្ដឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ | បណ្ដឹង | 80% | 80% | 52% | **កំពុងដំណើរការ** | - ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ បានទទួលបណ្ដឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានចំនួនសរុប ១២.៩៣៨ករណី ក្នុងនោះបណ្ដឹងក្នុងសមត្ថកិច្ចចំនួន ២២៥ករណី (បញ្ចប់ការដោះស្រាយចំនួន១១៨ករណី **ស្មើនឹង៥២%** កំពុងដំណើរការចំនួន ១០៧ករណី) បណ្ដឹងក្រៅសមត្ថកិច្ចចំនួន ១២២ករណី ព័ត៌មានផ្សេងៗសរុបចំនួន ១២.៥៩១ករណី (ការសរសើរចំនួន ៣៥៤ករណី សំណើ និងសំណូមពរចំនួន ២.០៨៨ករណី និងការសាកសួរព័ត៌មានចំនួន ១០.១៤៩ករណី)។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | 61. ភាគរយរដ្ឋបាលរាជធានី ខេត្ត ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 50% | 50% | 50% | **បានបញ្ចប់** | - បានផ្ដល់ការគាំទ្រ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលមួយចំនួនក្នុងការចូលរួមគាំទ្រ និងអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្តតាមរយៈការងារគណនេយ្យភាពសង្គម ដែលបច្ចុប្បន្នរួមមានអង្គការសង្គមស៊ីវិល**ចំនួន១៩** បានបំពេញតួនាទីជាផ្នែកតម្រូវការ ក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលដាក់ពិន្ទុវាយតម្លៃការបំពេញការងារ និងការផ្ដល់សេវាសាធារណៈរបស់អង្គភាពផ្ដល់សេវា<br>- រដ្ឋបាលរាជធានី ខេត្ត បានរៀបចំវេទិកាសាធារណៈ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ដើម្បីផ្សព្វផ្សាយ និងប្រមូលនូវមតិយោបល់ សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលវេលា។ |
| | | 62. ភាគរយរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 20% | 20% | 20% | **បានបញ្ចប់** | - បានផ្ដល់ការគាំទ្រ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលមួយចំនួនក្នុងការចូលរួមគាំទ្រ និងអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការងារគណនេយ្យភាពសង្គម ដែលបច្ចុប្បន្នរួមមានអង្គការសង្គមស៊ីវិល**ចំនួន១៩** បានបំពេញតួនាទីជាផ្នែកតម្រូវការ ក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលដាក់ពិន្ទុវាយតម្លៃការបំពេញការងារ និងការផ្ដល់សេវាសាធារណៈរបស់អង្គភាពផ្ដល់សេវា<br>- រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានរៀបចំវេទិកាសាធារណៈ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ដើម្បីផ្សព្វផ្សាយ និងប្រមូលនូវមតិយោបល់ សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលវេលា។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | ទិន្នន័យធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | ទិន្នន័យនៃការអនុវត្តសំខាន់ៗ |
| **2.7** | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | | | | | | | |
| 2.7.1 | ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិត | 63. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបានតំណភ្ជាប់សេវាអ៊ីនធឺណិត | ភាគរយ | 60% | 50% | | **កំពុងដំណើរការ** | - គិតមកដល់ឆ្នាំ២០២៤នេះ រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន......% មានលទ្ធភាពប្រើប្រាស់សេវាអ៊ីនធឺណិតក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ |
| | | 64. ប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល (ISAF M&E Database, NAD, PID…) | ប្រព័ន្ធ | 5 | 2 | 2 | **បានបញ្ចប់** | - បានធ្វើបច្ចុប្បន្នភាពទៅលើប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ប្រព័ន្ធគ្រប់គ្រងគម្រោងថ្នាក់ក្រោមជាតិ (PID) និងប្រព័ន្ធតាមដានការអនុវត្តផែនការថវិកាប្រចាំឆ្នាំ (NAD) របស់ គ.ជ.អ.ប. ព្រមទាំងបានធ្វើបច្ចុប្បន្នភាពបច្ចេកវិទ្យាប្រព័ន្ធគ្រប់គ្រងបណ្ណាល័យអេឡិចត្រូនិករបស់ គ.ជ.អ.ប.។ |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 65. ការសិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA-MIS) | របាយការណ៍ | 1 | | 1 | **កំពុងដំណើរការ** | - បាននិងកំពុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់ គ.ជ.អ.ប. និងរៀបចំប្រព័ន្ធគ្រប់គ្រងការសិក្សាអនឡាញនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| | | 66. ការសិក្សាអំពីប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ | របាយការណ៍ | 1 | | 1 | **បានបញ្ចប់** | - កំពុងដំណើរការអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស។ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ទ្រព្យសម្បត្តិត្រូវបានអនុវត្ត | | | | | | |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 67. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់គេហទំព័របណ្តាញសង្គម និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ដើម្បីផ្សព្វផ្សាយ និងទទួលព័ត៌មានពាក់ព័ន្ធនានា | ភាគរយ | 50% | 50% | 50% | **បានបញ្ចប់** | - រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាក្នុងការទំនាក់ទំនង ផ្សព្វផ្សាយ និងអនុវត្តភារកិច្ចរបស់ខ្លួនមានដូចជាប្រព័ន្ធ Facebook, Telegram, Website។ ព័ត៌មានសំខាន់ៗដែលបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋរួមមាន ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ |
| | | 68. ភាគរយរាជធានីខេត្ត បានរៀបចំនិងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ភាគរយ | 70% | 70% | 40% | **កំពុងដំណើរការ** | - បាននិងកំពុងរៀបចំជ្រើសរើសទីប្រឹក្សាព័ត៌មានវិទ្យារយៈពេលខ្លី តាមរយៈគម្រោងគណនេយ្យភាពសង្គម ដើម្បីធ្វើបច្ចុប្បន្នភាពមុខងារកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គមលើប្រព័ន្ធប្រតិបត្តិការ IOS និង Android ដើម្បីឱ្យសាធារណជនកាន់តែងាយស្រួលប្រើប្រាស់ និងទទួលបានព័ត៌មានត្រលប់ពីប្រជាពលរដ្ឋទៅលើការផ្តល់សេវារបស់អង្គភាពផ្តល់សេវា<br>- រដ្ឋបាលរាជធានី ខេត្តបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាក្នុងការទំនាក់ទំនង ផ្សព្វផ្សាយ និងអនុវត្តភារកិច្ចរបស់ខ្លួនមានដូចជា ប្រព័ន្ធ Facebook, Telegram, Website។ ព័ត៌មានសំខាន់ៗដែលបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋរួមមាន ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| 2.8 | **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 2.8.1 | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 69. ការសិក្សាអំពីលទ្ធភាពនៃការបង្កើតអង្គភាពត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | 1 | 1 | 1 | **កំពុងដំណើរការ** | - បាននិងកំពុងរៀបចំដំណើរការសិក្សាអំពីជម្រើសនានានៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវអនុវត្តដោយក្រុមការងារអន្តរក្រសួង រួមមាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។ |
| | | 70. បែបបទ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវបានរៀបចំ | សេចក្តីណែនាំ | 1 | | 1 | **កំពុងដំណើរការ** | - កំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| 3 | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ** | | | | | | | |
| **3.1** | **អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 71. ការសិក្សា និងរៀបចំលិខិតបទដ្ឋាននានាស្តីពីអង្គមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | ទិន្នន័យភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | ទិន្នន័យភាពនៃការអនុវត្តសំខាន់ៗ |
| | | 72. ការសិក្សាអំពីការរៀបចំក្របខ័ណ្ឌឋានន្តរស័ក្តិ ថ្នាក់ឱ្យសមស្របនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| **3.2** | **ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.2.1 | ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 73. សេចក្តីណែនាំស្តីពីការពិពណ៌នាអំពីមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈសម្រាប់អង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | សេចក្តីណែនាំ | អនុម័ត | | សេចក្តីព្រាង | **កំពុងដំណើរការ** | - បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីមុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមរៀបចំការបណ្តុះបណ្តាលដល់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។ |
| 3.2.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 74. គោលការណ៍ណែនាំស្តីពីការរៀបចំលក្ខខណ្ឌការងាររបស់ | គោលការណ៍ | 1 | | 1 | **បានបញ្ចប់** | - រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំឱ្យមានលក្ខខណ្ឌការងារសម្រាប់មន្ត្រីបុគ្គលិកប្រចាំឆ្នាំនៅតាមសង្គមភាពសាមីនីមួយៗរបស់ខ្លួន។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | | | | | | |
| 3.2.4 | ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 75. លិខិតបទដ្ឋានស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | អនុម័ត | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| 3.2.5 | ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ | 76. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត | ប្រព័ន្ធ | អនុម័ត | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| **3.3** | **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.3.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 77. ការសិក្សា និងការរៀបចំឯកសារទស្សនទានអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ | ឯកសារទស្សនទាន | 1 | 1 | 1 | **កំពុងដំណើរការ** | - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ការចូលនិវត្តត្រូវបាននិងកំពុងសិក្សារៀបចំ ដោយក្រសួងមុខងារសាធារណៈ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ក្រោមជាតិត្រូវបានអនុវត្ត | | | | | | |
| **3.4** | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | | | | | | | |
| 3.4.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំស្ដីពីការវាយតម្លៃតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ | 78. សេចក្ដីណែនាំស្ដីពីការវាយតម្លៃតម្រូវការធនធានមនុស្សត្រូវបានរៀបចំ | សេចក្ដីណែនាំ | សេចក្ដីព្រាង | | | **មិនទាន់អនុវត្ត** | - គ្រោងរៀបចំនៅអំឡុងឆមាសទី២។ |
| 3.4.2 | ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | 79. ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | វគ្គ | អនុវត្ត | | 1 | **កំពុងដំណើរការ** | - ការពិនិត្យ និងពិភាក្សាលើស្ថានភាពនៃការអនុវត្តក្នុងវិស័យការងារ ការបណ្ដុះបណ្ដាល និងពាក់ព័ន្ធ នានាទៅនឹងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>- សិក្សានិងរៀបចំសិក្ខាសាលា ឬបណ្ដុះបណ្ដាលការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| 3.4.3 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 80. ភាគរយរដ្ឋបាលថ្នាក់រាជធានី ខេត្តបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | 100% | | 100% | **បានបញ្ចប់** | - មន្ត្រីបុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន ២៥.៧៥៣រូប ស្ត្រី១៣.២០០រូប (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន ៣.២៩៥រូប ស្ត្រី១.០៣១រូប និងគ្រូពេទ្យមានចំនួន២២.៤៥៨រូប ស្ត្រី១២.១៦៩រូប)<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពុំត្រូវបានអនុញ្ញាតឱ្យស្នើសុំក្របខ័ណ្ឌថ្មីសម្រាប់ឆ្នាំ២០២៤ទេ ប៉ុន្តែក្រសួងមុខងារសាធារណៈ តាមរយៈសាលាភូមិន្ទរដ្ឋបាល គ្រោងនឹងជ្រើសរើសមន្ត្រីជាន់ខ្ពស់ (ក្របខ័ណ្ឌ ក) ចំនួន១រូបសម្រាប់រដ្ឋបាលរាជធានី ខេត្តនីមួយៗ និងជ្រើសរើសមន្ត្រីក្រមការ (ក្របខ័ណ្ឌ ខ) ចំនួន១រូបសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។ (ផែកព័ត៌មាន)។ |
| | | 81. ភាគរយរដ្ឋបាលថ្នាក់ក្រុង ស្រុកបាន | ភាគរយ | 100% | | 100% | **បានបញ្ចប់** | - មន្ត្រីបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន ៧៧.៥២៩នាក់ (មន្ត្រីបុគ្គលិករដ្ឋ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | រៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | | | | | | - បាលចំនួន ១៧.៥២៩នាក់ ស្ត្រី៦.៦៤១នាក់ និងគ្រូបង្រៀនប្រមាណជាង ៦០.០០០នាក់)<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពុំត្រូវបានអនុញ្ញាតឱ្យស្នើសុំក្របខ័ណ្ឌថ្មីសម្រាប់ឆ្នាំ ២០២៤ទេ ប៉ុន្តែក្រសួងមុខងារសាធារណៈ តាមរយៈសាលាភូមិន្ទរដ្ឋបាល គ្រោងនឹងជ្រើសរើសមន្ត្រីជាន់ខ្ពស់ (ក្របខ័ណ្ឌ ក) ចំនួន១រូបសម្រាប់រដ្ឋបាលរាជធានី ខេត្តនីមួយៗ និងជ្រើសរើសមន្ត្រីក្រមការ (ក្របខ័ណ្ឌ ខ) ចំនួន១រូបសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។ (ផែកព័ត៌មាន)។ |
| 3.5.1 | ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 82. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| **3.5** | **គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.5.4 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 83. ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ | ផែនការ | អនុម័ត | 1 | សេចក្តីព្រាង | **កំពុងដំណើរការ** | - បានពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨) ក្រោមការដឹកនាំសម្របសម្រួលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ និងមានការគាំទ្រដោយកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈជូន |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ក្រោមជាតិត្រូវបានអនុម័ត ផ្សព្វផ្សាយ និងអនុវត្ត | | | | | | ប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD) របស់កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់(GIZ)។ |
| | | 84. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ភាគរយ | 27.51 % | | 27,46 % | **បានបញ្ចប់** | - មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ការ និងប្រធាន/អនុប្រធានការិយាល័យ) **មានចំនួន ៥៨៣នាក់ ស្មើនឹង ២៧,៤៦ %។** |
| | | 85. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 23.58 % | | 23,32 % | **បានបញ្ចប់** | - រដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន **១.៦៦៨នាក់ ស្មើនឹង ២៣,៣២%។** |
| **3.6** | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | | | | | | | |
| 3.6.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 86. សេចក្តីណែនាំស្តីពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានពិនិត្យ និងកែសម្រួល | សេចក្តីណែនាំ | 1 | | 1 | **បានបញ្ចប់** | - សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយមួយចំនួន រួមមាន (១) សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២) សេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (៣) ក្របខ័ណ្ឌស្តង់ដាសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៤) ក្របខ័ណ្ឌស្រាវជ្រាវរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (៥) សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត និងកំណត់តួនាទីរបស់នាយកគ្រប់គ្រងវគ្គបណ្តុះបណ្តាល |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | - វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។ |
| 3.6.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 87. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | វគ្គ | 1 | | 1 | **បានបញ្ចប់** | - អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| 3.6.3 | ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 88. របាយការណ៍វាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |
| 3.6.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 89. ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 100% | | 70% | **កំពុងដំណើរការ** | - រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួនស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 90. ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 90% | | 50% | **កំពុងដំណើរការ** | – រដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួនស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 91. ភាគរយនៃសកម្មភាពអភិវឌ្ឍសមត្ថភាពដែលបានគ្រោងក្នុងផែនការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | ភាគរយ | 80% | 40% | 40% | **កំពុងដំណើរការ** | – រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់សរុបចំនួន ៦០វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ ៥.២៨០រូប ដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចជា៖<br>• ការងារគណនេយ្យភាពសង្គម (ដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់)<br>• សន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់កុមារក្នុងវ័យលូតលាស់ (ដល់រដ្ឋបាលឃុំ សង្កាត់)<br>• ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ (ដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)<br>• ពិធីការ និងបដិសណ្ឋារកិច្ច (ដល់រដ្ឋបាលក្រុង ស្រុក ចំនួន៦៧២)<br>• ការពង្រឹងតួនាទីរបស់ គ.ក.ស.ក. (នៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)<br>• តួនាទីរបស់ គ.ដ.វ.វ. (នៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ)<br>• របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន (ដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់)<br>• ការកសាងផែនការ និងថវិកា (ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់) |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | • អន្តរាគមន៍អភិវឌ្ឍសមត្ថភាព (ដល់មន្ត្រីរដ្ឋបាលរាជធានី ខេត្ត)<br>• តួនាទី ភារកិច្ចស្មៀន (ដល់រដ្ឋបាលឃុំ សង្កាត់)<br>• ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ (ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់)<br>• ថវិកាឆ្លើយតបទៅនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ (ដល់រដ្ឋបាលឃុំ សង្កាត់)។ |
| **3.7** | **ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.7.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 92. ភាគរយអគារនៃសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានសាងសង់ | ភាគរយ | 60% | 30% | 28% | **កំពុងដំណើរការ** | – សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងដំណើរការសាងសង់សាលាជាតិរដ្ឋបាលដ្ឋានដោយមានវឌ្ឍនភាព **២៨%** ដោយអគារសិក្សាកំពុងសាងសង់គ្រោងឆ្អឹងជាន់ទី២ និងរៀបចំខណ្ឌជាបន្ទប់ រីឯអគារអន្តេវាសិកដ្ឋានកំពុងបូកជញ្ជាំង។ អគារសាលាជាតិរដ្ឋបាលមូលដ្ឋានមានចំនួន០២ខ្នង គឺអគារសិក្សាសម្រាប់បង្រៀនដែលមានទំហំ ១២.៨៥៨ម៉ែត្រការ៉េ កម្ពស់២ជាន់ និងអគារអន្តេវាសិកដ្ឋានទំហំ ៣.៧៣៤ម៉ែត្រការ៉េ កម្ពស់១ជាន់។ អគារសិក្សាមានបន្ទប់សិក្សាតូចៗចំនួន០៩ បន្ទប់សិក្សាធំៗចំនួន០៧ សហសាលសិក្សាចំនួន០១ បន្ទប់កុំព្យូទ័រចំនួន០២ បណ្ណាល័យចំនួន០១ បន្ទប់ប្រជុំចំនួន២ បន្ទប់សម្រាប់គ្រូបង្រៀនចំនួន០១ អាហារដ្ឋានចំនួន០១ កន្លែងក្មេងលេង បន្ទប់ព្យាបាលបឋមចំនួន០១ បន្ទប់សម្ភារៈនិងបន្ទប់ផ្សេងៗទៀត។ ក្រៅពីនេះមានការិយាល័យសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារ។ អគារអន្តេវាសិកដ្ឋានមានបន្ទប់សម្រាប់សិក្ខាកាមស្នាក់នៅចំនួន៦៤បន្ទប់ និងបន្ទប់ផ្សេងៗទៀត។ ការសាងសង់អគារសិក្សា និងអន្តេវាសិកដ្ឋាននៃសាលាជាតិរដ្ឋបាលមូលដ្ឋានគ្រោងបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០២៥ខាងមុខ ដែលប្រើប្រាស់ថវិកាសាងសង់ប្រមាណ៦.១៥លានដុល្លារ ដែលទទួលបានថវិកាកម្ម |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ពីធនាគារអភិវឌ្ឍន៍អាស៊ី ស្ថិតក្រោមក្របខ័ណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុជំហានទី២ ( ADB Loan No. 3970-CAM )។ |
| | | 93. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់គ្រូបណ្តុះបណ្តាល និងបុគ្គលិករបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | វគ្គ | 4 | 2 | 6 | **បានបញ្ចប់** | - បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានបានចូលរួមវគ្គបណ្តុះបណ្តាលចំនួន៦វគ្គ នៅក្នុងប្រទេសចំនួន៤វគ្គ និងក្រៅប្រទេសចំនួន២វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ១៦នាក់ ស្ត្រី ៥នាក់ លើប្រធានបទសំខាន់ៗ ដូចជា៖<br>• ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងលំហូរឯកសារអេឡិចត្រូនិក<br>• ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ជំនាន់ទី៦<br>• វិក្រឹត្យការ ឆ្នាំ២០២៤<br>• គោលការណ៍ បែបបទ និងនីតិវិធីក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>• កម្មវិធីទស្សនកិច្ចសិក្សាស្តីពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍវិស័យកសិកម្មបច្ចេកវិទ្យាទំនើប និងច្រវាក់ទីផ្សារ<br>• កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីភាពជាអ្នកដឹកនាំលើវិស័យសាធារណៈសម្រាប់មន្ត្រីជាន់ខ្ពស់ទី១<br>• ធ្វើតេស្តសមត្ថភាពលើជំនាញបច្ចេកវិទ្យាឌីជីថលដែលរៀបចំឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ |
| 3.7.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 94. ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានរៀបចំ | វគ្គ | 35 | 15 | 14 | **កំពុងដំណើរការ** | - សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន ១៤វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦២១នាក់ ស្ត្រីចំនួន ១៤០នាក់ ដោយផ្តោតលើប្រធានបទ និងកម្មវិធីសំខាន់ៗ ដូចជា៖<br>• កម្មវិធីគ្រប់គ្រងកម្រិត១<br>• កម្មវិធីវិក្រឹត្យការមូលដ្ឋានជំនាន់ទី៨<br>• កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | • ការរៀបចំផែនការថវិកា<br>• ការលើកកម្ពស់សមធម៌ និងបរិយាបន្នសង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• កិច្ចការរដ្ឋបាល និង<br>• ការតាក់តែងអត្ថបទ។ |
| **3.8** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.8.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 95. លិខិតបទដ្ឋានស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | | 6 | **បានបញ្ចប់** | - សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំពិនិត្យកែសម្រួលនិងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា (១) រៀបចំជាសេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (២) សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា សិក្សាថ្មីចំនួន ០៤ រួមមាន (១) កម្មវិធីសិក្សារយៈពេលវែង (២) កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ (៣) កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (៤) កម្មវិធីសិក្សាសម្រាប់សាធារណជន។ |
| 3.8.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា | 96. ចំនួនសៀវភៅគោលត្រូវបានរៀបចំ | ក្បាល | 4 | | 11 | **បានបញ្ចប់** | - សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំសៀវភៅណែនាំមួយចំនួន រួមមាន (១) សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល សៀវភៅណែនាំស្តីពីប្រតិបត្តិការសម្រាប់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន (៣) សៀវភៅគោលស្តីពីការគ្រប់គ្រងមុខងារសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត (៤) សៀវភៅគោលស្តីពីការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព (៥) សៀវភៅណែនាំស្តីពីនីតិវិធី និងរបៀបរបបការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន(៦) សៀវភៅគោលស្តីពីពិធីការ (៧) សៀវភៅណែនាំ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | សម្រាប់អ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាល (៨) សៀវភៅណែនាំស្តីពីការរៀនបណ្តើរធ្វើការបណ្តើរ (៩) សៀវភៅគោលស្តីពីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅកម្ពុជា (១០) សៀវភៅគោលស្តីពីក្រមសីលធម៌មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ (១១) សៀវភៅណែនាំស្តីពីការគ្រប់គ្រងបណ្ណាល័យ និងបណ្ណសារដ្ឋាន។ |
| 4 | **ទិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។** | | | | | | | |
| **4.1** | **កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សីុគ្នា ដោយផ្អែកលើចរិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** | | | | | | | |
| 4.1.1 | ការបន្សីុគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 97. ភាគរយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រទៅលើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន | ភាគរយ | 100% | 100% | 100% | **បានបញ្ចប់** | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរណែនាំលេខ០០២ សហវ.ស.រ.អថ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤។ ស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥<br>– រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានរៀបចំគម្រោងថវិកា និងអនុលោមភាពគម្រោងឆ្នាំ២០២៤ សរុបប្រមាណ**ចំនួន ២.៩៦០ គម្រោង** ដែលគម្រោងទាំងនេះជាគម្រោងដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 98. ប្រព័ន្ធទិន្នន័យស្តីពីព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SPD) ត្រូវបានពិនិត្យ និងកែសម្រួល | ទិន្នន័យ | 1 | 1 | 1 | **បានបញ្ចប់** | – បានធ្វើបច្ចុប្បន្នភាពបញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ PID និងSPD ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុបៃតងដំណាក់កាលទី៣ (CCCA3) និងបានកំពុងធ្វើតេស្តសាកល្បងនៅរដ្ឋបាលខេត្តចំនួន០៣រួមមាន ៖ ខេត្តកំពត ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | ទិន្នន័យធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | ទិន្នន័យនៃការអនុវត្តសំខាន់ៗ |
| | | 99. ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ឆ្នាំ២០២៣ ត្រូវបានប្រមូល ផលិត និងចែករំលែក | ទិន្នន័យ | 1 | 1 | 1 | **បានបញ្ចប់** | - ក្រសួងផែនការ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យអនឡាញ ព្រមទាំងបានប្រមូល ផលិត និងចែករំលែកព័ត៌មានជាសាធារណៈអំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។ |
| | | 100. ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីមន្ទីរផែនការអំពីដំណើរការ និងវិធីសាស្ត្រកសាងផែនការនៅថ្នាក់ក្រោមជាតិ និងវិធីសាស្ត្រកែច្នៃ វិភាគ និងផលិតឯកសារព័ត៌មាន និងទិន្នន័យនានា | វគ្គ | 3 | 1 | | **មិនទាន់អនុវត្ត** | - គ្រោងនឹងអនុវត្តនៅអំឡុងឆមាសទី២។ |
| **4.2** | **ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 101. ចំនួនរដ្ឋបាលរាជធានី ខេត្ត ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ | រាជធានី ខេត្ត | 25 | 25 | 25 | **បានបញ្ចប់** | - រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការរៀបចំរបាយការណ៍។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | | | | | |
| | | 102. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត | លិខិតបទដ្ឋាន | 1 | | 1 | **កំពុងដំណើរការ** | - បានផ្ដល់គោលការណ៍ណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសារាចរណែនាំលេខ០០៧ សហវ.ស.រ.អហក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖ ផែនការលទ្ធកម្មប្រចាំរបស់រដ្ឋបាលរាជធានី ខេត្តត្រូវពិនិត្យ និងសម្រេចក្នុងក្របខ័ណ្ឌនៃការចរចារថវិការដ្ឋបាលរាជធានី ខេត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |
| | | 103. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ថវិការបស់ថ្នាក់ក្រុង ស្រុកដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរតនាគារខេត្ត | លិខិតបទដ្ឋាន | 1 | | 1 | **កំពុងដំណើរការ** | - បានផ្ដល់គោលការណ៍ណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសារាចរណែនាំលេខ០០៧ សហវ.ស.រ.អហក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ផែនការលទ្ធកម្មប្រចាំរបស់រដ្ឋបាលក្រុង ស្រុកត្រូវពិនិត្យ និងសម្រេចក្នុងក្របខ័ណ្ឌនៃការចរចារថវិការដ្ឋបាលរាជធានី ខេត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 104. ក្រុមខ័ណ្ឌរួមស្តីពីការរៀបចំរបាយការណ៍ និងការត្រួតពិនិត្យតាមដានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |
| | | 105. ក្រុមខ័ណ្ឌរួមមួយស្តីពីការវាយតម្លៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |
| **4.3** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់ | 106. លិខិតបទដ្ឋានស្តីពីការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែល | លិខិតបទដ្ឋាន | 1 | 1 | 1 | **បានបញ្ចប់** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញលិខិត០១៣ សហវ សរ.អថ សារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៤។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | មានស្រាប់របស់រាជធានី ខេត្តត្រូវបានរៀបចំ និងអនុវត្ត | | | | | | |
| | | 107. ចំណូលសារពើពន្ធរបស់រាជធានីខេត្តមានការកើនឡើងធៀបនឹងឆ្នាំ២០២៣ | ចំណូល | កើនឡើង | | កើនឡើង | **បានបញ្ចប់** | – គិតមកដល់ខែមិថុនា ក្នុងឆ្នាំ២០២៤នេះ ចំណូលសារពើពន្ធរបស់រាជធានីខេត្ត មានចំនួន **២.២១៤.៧២១លានរៀល (សមមូល ៥៤០ លានដុល្លារ)** មានការកើនឡើងចំនួន**១០លានដុល្លារ ស្មើនឹង០.៩៨%** ធៀបនឹង០៦ខែដើមឆ្នាំ២០២៣។ |
| 4.3.2 | ការបែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់ | 108. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក | ភាគរយ | 4% | 4% | 4% | **បានបញ្ចប់** | – តាមគោលការណ៍ រដ្ឋបាលខេត្តត្រូវចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុង**អត្រា ៤%**។ ការអនុវត្តជាក់ស្តែងដោយសារស្ថានភាពចំណូលជាក់ស្តែងការចែករំលែកចំណូលនេះ ត្រូវបានកាត់ព្យួរទាំងស្រុងការផ្ទេរចំណូលពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តជូនរដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៤ តាមសារាចរណែនាំលេខ០០៥សហវ.ស.រ.អហក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។ |
| | | 109. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅ | ភាគរយ | 6% | 6% | 6% | **បានបញ្ចប់** | – តាមគោលការណ៍ រដ្ឋបាលខេត្តត្រូវចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុង**អត្រា ៦%** ។ ការអនុវត្តជាក់ស្តែងដោយសារស្ថានភាពចំណូលជាក់ស្តែងការចែករំលែកចំណូលនេះ ត្រូវបានកាត់ព្យួរទាំងស្រុងការផ្ទេរចំណូលពីការបែងចែកចំណូលសារពើរពន្ធរបស់រដ្ឋបាលរាជធានី ខេត្តជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ឆ្នាំ២០២៤ តាមសារាចរណែនាំលេខ០០៥សហវ.ស.រ.អហក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ ស្តីពី |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ឱ្យរដ្ឋបាលឃុំ សង្កាត់ | | | | | | ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។ |
| **4.4** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 110. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ប្រព័ន្ធ | អនុវត្ត | | អនុវត្ត | **បានបញ្ចប់** | - គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសបាននិងកំពុងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS)។ |
| | | 111. ភាគរយនៃការទូទាត់តាមប្រព័ន្ធឌីជីថលសម្រាប់អង្គភាព/ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ភាគរយ | សេវា ចំនួន ១០% បាន អនុវត្ត | | 10% | **បានបញ្ចប់** | - បានធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធ NRMIS និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត តាមប្រព័ន្ធអនឡាញ<br>- បានដាក់អនុវត្តជាផ្លូវការប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយខេត្តគោលដៅទាំង២៥។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | 112. ការសិក្សាអំពីជម្រើសនានានៃការប្រើប្រាស់ចំណូលដែលទទួលបានកម្រៃពីអ្នកប្រើប្រាស់សេវាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | 1 | | 1 | **កំពុងដំណើរការ** | - បាននិងកំពុងសម្របសម្រួលការងារជាមួយធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំនីតិវិធីសម្រាប់បង់កម្រៃសេវារដ្ឋបាលនៅតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌតាម QR CODE។ |
| **4.5** | **ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមវិធានការច្បាស់លាស់** | | | | | | | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 113. ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរ | ការផ្ទេរ | អនុវត្ត | | 1 | **កំពុងដំណើរការ** | - គ្រោងនឹងរៀបចំនៅអំឡុងឆមាសទី២។ |
| | | 114. សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ | សេចក្តីណែនាំ | 1 | 1 | 1 | **បានបញ្ចប់** | - រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តតាំងពីខែមករា ឆ្នាំ២០២១ |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ក្រោមជាតិត្រូវបានរៀបចំ | | | | | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទូទាំងប្រទេសតាំងពីខែមីនា ឆ្នាំ២០២៣។ |
| | | 115. ការបែងចែកចំណូលពីទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ការបែងចែក | អនុវត្ត | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |
| | | 116. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលរាជធានី ខេត្តត្រូវបានពង្រឹងការអនុវត្ត | ប្រព័ន្ធ | អនុវត្ត | | អនុវត្ត | **បានបញ្ចប់** | - រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តតាំងពីខែមករា ឆ្នាំ២០២១។ |
| | | 117. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុកត្រូវបាន | ប្រព័ន្ធ | អនុវត្ត | | អនុវត្ត | **បានបញ្ចប់** | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទូទាំងប្រទេសតាំងពីខែមីនា ឆ្នាំ២០២៣។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | រៀបចំ និងដាក់ឱ្យអនុវត្ត | | | | | | |
| **4.6** | **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ** | | | | | | | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក | 118. អត្រាផ្ទេរធនធានពីថវិកាជាតិទៅឱ្យមូលនិធិក្រុង ស្រុក | អត្រា | 1.6 | 1.6 | 1.6 | **បានបញ្ចប់** | - រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ២០២៤-២០២៨ ក្នុងអត្រាថេរប្រចាំឆ្នាំ **១,៦%** ដែលអត្រានេះ មានការកើនឡើង **0,១%** ធៀបទៅនឹងអត្រាផ្ទេរនៅក្នុងឆ្នាំ ២០២៣។ ថវិការបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៤នេះ មានចំនួន ២.២៨៨.០១៧លានរៀល ស្មើនឹង៥៥៨លានដុល្លារ មានការកើនឡើងចំនួន១.៦០៧.២១៤លានរៀល សមមូលនឹង ៣៩២លានដុល្លារ ស្មើនឹង ៣៣៦% ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៣។ ថវិការបស់ក្រុង ស្រុក ឆ្នាំ២០២៤ ដែលកើនឡើងយ៉ាងខ្លាំងនេះ ដោយសារមានការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលក្រុង ស្រុកទូទាំងប្រទេសសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំក្នុងទំហំប្រមាណ ៤០៦លានដុល្លារ ក្នុងនោះថវិកាបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានទំហំប្រមាណជាង ៣៣លានដុល្លារ។ |
| | | 119. ការសិក្សាអំពីប្រភេទចំណូលមិនមែនសារពើពន្ធដាក់លាក់មួយ | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ចំនួនដែលត្រូវបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក | | | | | | |
| 4.6.2 | ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 120. ការសិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | រៀបចំ | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅក្នុងអំឡុងឆមាសទី២។ |
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា | 121. លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងសេវាសង្គម អនាម័យ និងបរិស្ថាន | លិខិតបទដ្ឋាន | 1 | | 1 | **បានបញ្ចប់** | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ២០២៤-២០២៨ ដោយមានកំណត់អំពីទំហំធនធាននៃសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| **4.7** | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | 122. ការសិក្សាលើការរៀបចំការដាក់បញ្ចូលធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារទៅក្នុងគម្រោងថវិកាឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | រៀបចំ | | រៀបចំ | **បានបញ្ចប់** | - បានដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងអប់រំកុមារតូច អប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ. ប្រក.អថចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា។ |
| **4.8** | **ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិធំទូលាយមួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត** | | | | | | | |
| 4.8.1 | ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | 123. ការសិក្សា និងវាយតម្លៃលើការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំក្នុងអំឡុងឆមាសទី២។ |
| | | 124. គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្ម | គោលការណ៍ | 1 | | 1 | **បានបញ្ចប់** | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលក្រុង ស្រុក |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ប្រចាំឆ្នាំរបស់រដ្ឋបាលក្រុងស្រុកត្រូវពិនិត្យ និងកែសម្រួល | | | | | | សម្រាប់ផ្តល់ហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)។ |
| 4.8.3 | ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស | 125. លិខិតបទដ្ឋានសម្រាប់បង្កើតយន្តការមូលនិធិភាតរភាពត្រូវបានរៀបចំ | លិខិតបទដ្ឋាន | 1 | 1 | 1 | **កំពុងដំណើរការ** | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃមូលនិធិភាតរភាព (មូលនិធិនេះមានប្រភពចំណូលពីការចែករំលែកចំណូលមិនមែនសារពើពន្ធលើការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងការចែករំលែកចំណូលពីទ្រព្យសម្បត្តិរដ្ឋ) ក្នុងគោលបំណង ដើម្បីបង្កើនធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់។ |
| **4.9** | **ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព** | | | | | | | |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | 126. សិក្សា និងរៀបចំក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | របាយការណ៍ | 1 | | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំក្នុងអំឡុងឆមាសទី២។ |
| | | 127. នីតិវិធីសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ | សេចក្តីណែនាំ | 1 | 1 | 1 | **កំពុងដំណើរការ** | - គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចង្អៀតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូលក្រោម៥លានដុល្លារនៅថ្នាក់រាជធានី ខេត្ត ព្រមទាំងដាក់ចេញនូវវិធានការក្នុងការជំរុញការរៀបចំការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរអង្គភាពក្នុងការចុះបញ្ជីគម្រោងវិនិយោគ ដែលមានទុនសមមូល៥លានដុល្លារចុះ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | បានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | | | |
| 5 | **ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។** | | | | | | | | |
| **5.1** | **ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព** | | | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 128. មេរៀនបទពិសោធស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចត្រូវបានរៀបចំ | ករណីសិក្សា | 1 | | 1 | **កំពុងដំណើរការ** | - បានប្រមូលចងក្រងលិខិតបទដ្ឋានគតិយុត្ត និងឯកសារមេរៀនបទពិសោធអំពីការគ្រប់គ្រងរដ្ឋបាលខេត្តពីបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសថៃស្តីពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់តំបន់<br>- បានរៀបចំផែនការ និងដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធនៅប្រទេសឥណ្ឌូនេស៊ី ដែលគ្រោងធ្វើឡើងនៅត្រីមាសទី១ ឆ្នាំ២០២៥ ដោយមានការគាំទ្រពីគម្រោងGIZ/ISD ក្រោមហិរញ្ញប្បទានពីប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស<br>- បានរៀបចំដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន១៩រូប នៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ដែលបានគាំទ្រដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) និង GIZ។ ដំណើរទស្សនកិច្ចសិក្សានេះដឹកនាំដោយ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីសិក្សាឈ្វេងយល់អំពីមេរៀន និងពិសោធន៍ល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចនៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់ ព្រមទាំងពង្រឹង និងពង្រីកទំនាក់ទំនងរវាងកម្ពុជា និងស្វីសក្នុងកិច្ចសហប្រតិបត្តិការនាពេលអនាគត។ |
| | | 129. ចំនួនភាគរយសរុបនៃមុខងារជាកាតព្វកិច្ចដែលមានសេចក្ដីណែនាំបច្ចេកទេសស្ដីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ | ភាគរយ | 90% | 80% | 57% | **កំពុងដំណើរការ** | - សេចក្ដីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន ០៨ រួមមាន ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនិវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជននិងកីឡា។ |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 130. នីតិវិធីអនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ការសិក្សា | បានកែសម្រួល | 1 | | **មិនទាន់អនុវត្ត** | - គ្រោងនឹងរៀបចំនៅឆមាសទី២។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ត្រូវបានពិនិត្យ និងកែសម្រួល | | | | | | |
| | | 131. នីតិវិធីអនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | បានកែសម្រួល | 1 | 1 | **កំពុងដំណើរការ** | - បាននិងកំពុងបន្តប្រជុំពិគ្រោះយោបល់ជាមួយនាយកដ្ឋានកិច្ចការរដ្ឋបាលស្រុក និងឃុំ សង្កាត់  នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ ខេត្ត និងអង្គការតម្លាភាព ស្ដីពីការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM) ដើម្បីពិនិត្យ និងកែសម្រួល។ |
| **5.2** | **យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាថាការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួលឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | | | | | |
| 5.2.1 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | 132. បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | 1 | | 1 | **បានបញ្ចប់** | - សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីគោលការណ៍ និងនីតិវិធីការផ្តល់សេវាតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| | | 133. សេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជី | សេចក្តីណែនាំ | 1 | 1 | 1 | **កំពុងដំណើរការ** | - លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសអន្តរក្រសួងកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ដែលមានការចូលរួមពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងតំណាងរដ្ឋបាលរាជធានី ខេត្តមួយចំនួន |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | គម្រោងវិនិយោគនៅថ្នាក់រាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | | | ដើម្បីពន្យល់បកស្រាយអំពីខ្លឹមសារសំខាន់ៗនៃច្បាប់វិនិយោគថ្មី អនុក្រឹត្យលេខ១២០ និងផ្តល់ការណែនាំ ព្រមទាំងមានការឯកភាពគ្នាក្នុងការរៀបចំកិច្ចការសំខាន់ៗដែលច្បាប់ និងអនុក្រឹត្យទាំងនេះតម្រូវឱ្យក្រសួង ស្ថាប័នត្រូវធ្វើប្រតិភូកម្មអំណាចទៅមន្ទីរអង្គភាពរបស់ខ្លួន ការផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រនានា ដើម្បីជានាឱ្យរដ្ឋបាលរាជធានី ខេត្តអាចអនុវត្តនូវមុខងារចុះបញ្ជីគម្រោងវិនិយោគនានាដែលទុនសមមូល៥លានដុល្លារចុះស្របតាមច្បាប់ និងអនុក្រឹត្យកំណត់<br>- គិតមកដល់ខែមិថុនា ឆ្នាំ២០២៤នេះ ក្រសួង ស្ថាប័នចំនួន៤ បានដាក់ចេញនូវប្រកាសប្រតិភូកម្មដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួនដែលរួមមាន ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីពិនិត្យផ្តល់យោបល់ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគនានាដែលទុនសមមូល៥លានដុល្លារចុះ។ ក្រសួង ស្ថាប័នចំនួន ១០ទៀត បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសប្រតិភូកម្ម។ |
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | 134. ការផ្តល់សេវាក្នុងវិស័យមួយចំនួនបានផ្តល់តាមប្រព័ន្ធអនឡាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង | ការផ្តល់សេវា | 5 | | 117 | **បានបញ្ចប់** | - បាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញនៅថ្នាក់រាជធានី ខេត្តចំនួន១២ លើប្រភេទសេវារដ្ឋបាលចំនួន១១៧ ក្នុងវិស័យចំនួន៤ រួមមាន វិស័យទេសចរណ៍ វិស័យវប្បធម៌និងវិចិត្រសិល្បៈ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងដាក់ឱ្យអនុវត្តនូវប្រព័ន្ធទូទាត់តាមវិក្កយបត្រ (Payment Hub) នៅថ្នាក់រាជធានី ខេត្តទាំង២៥ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។<br>- ដំណើរការរៀបចំកម្មវិធីសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត |

| ក្រុង | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | | | | | | | - អនុវត្តប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) និងការដាក់ឱ្យអនុវត្តសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅរដ្ឋបាលខេត្ត<br>- ការធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធ NRMIS និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តតាមប្រព័ន្ធអនឡាញ<br>- ផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅអង្គភាពច្រកចេញចូលតែមួយ។ |
| **5.4** | **ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 135. សេចក្តីណែនាំស្តីពីការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | សេចក្តីណែនាំ | 1 | | 1 | **កំពុងដំណើរការ** | - បាននិងកំពុងបន្តសិក្សាលទ្ធភាពស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 136. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការ | សៀវភៅណែនាំ | អនុម័ត | 1 | 1 | **កំពុងដំណើរការ** | - បាននិងកំពុងរៀបចំសេចក្តីព្រាងបឋមស្តីពីការតាក់តែងសៀវភៅស្តីពីការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំឆ្លង និងពិគ្រោះយោបល់លើបទដ្ឋាន និងគោលនយោបាយនានាក្នុងការផ្តួចផ្តើមការរៀបចំបទដ្ឋានបច្ចេកទេសលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | | | | | | - បានបញ្ចប់ការរៀបចំកម្មវិធីការងាររយៈពេល៥ឆ្នាំស្តីពីការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី២ (Entity Work Program) ឆ្នាំ២០២៤-២០២៨ របស់ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបានបញ្ជូនកម្មវិធីការងារនេះ ទៅក្រសួងបរិស្ថាន ទទួលបន្ទុកជាតិ និងលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង (GCF)។ ជាមួយគ្នានេះដែរ កម្មវិធីការងាររយៈពេល០៥ឆ្នាំនេះ ក៏បានដាក់ជូនថ្នាក់ដឹកនាំ ដើម្បីសុំការអនុម័តលើកម្មវិធីនេះ និងត្រៀមរៀបចំផ្សព្វផ្សាយ ។ |
| 5.4.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 137. ការសិក្សា និងរៀបចំទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុត្រូវ | របាយការណ៍ | អនុវត្ត | 1 | 1 | **កំពុងចំណើរការ** | - បានពិគ្រោះយោបល់ជាមួយ UNDP ដើម្បីរកលទ្ធភាពផ្តល់ការគាំទ្របច្ចេកទេស លើការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។ ជាលទ្ធផលនៃកិច្ចពិភាក្សានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានពិនិត្យ និងផ្តល់ធាតុចូលលើលក្ខខណ្ឌការងារ (TOR) របស់ទីប្រឹក្សាចំនួន០៤នាក់ ដើម្បី UNDP ធ្វើលទ្ធកម្មជ្រើសរើសទីប្រឹក្សានៅក្នុងខែឧសភា ឆ្នាំ២០២៤។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | បានរៀបចំ និងអនុវត្ត | | | | | | |
| 5.4.4 | ការវិនិយោគសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 138. លិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាបន្នសមធម៌សង្គម និងសេវាសង្គម ត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | 1 | | | **កំពុងដំណើរការ** | - បាននបញ្ចប់ការរៀបចំកម្មវិធីការងាររយៈពេល០៥ឆ្នាំស្តីពីការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី២ (Entity Work Program) ឆ្នាំ២០២៤-២០២៨ របស់លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបានបញ្ជូនកម្មវិធីការងារនេះទៅក្រសួងបរិស្ថានទទួលបន្ទុកជាតិ និងលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង (GCF)។ ជាមួយគ្នានេះដែរ កម្មវិធីការងាររយៈពេល០៥ឆ្នាំនេះ ក៏បានដាក់ជូនថ្នាក់ដឹកនាំដើម្បីសុំការអនុម័តលើកម្មវិធីនេះ និងត្រៀមរៀបចំផ្សព្វផ្សាយ<br>- បានបន្តពិភាក្សាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM) ដើម្បីពិនិត្យ កែសម្រួលបញ្ចប់ជំពូក២ស្តីពីការពិនិត្យគម្រោង និងបញ្ជាក់បច្ចេកទេសដោយមានអ្នកចូលរួមមកពីលេខាធិការដ្ឋាន គ.ជ.អ.ប. នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ ខេត្ត និងអង្គការតម្លាភាព។ |
| | | 139. ចំនួនភាគរយនៃគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្ត | ភាគរយ | 20% | 10% | 10% | **កំពុងដំណើរការ** | - រដ្ឋបាលឃុំ គោលដៅបានទទួលការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា<br>- គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅ ឆ្នាំ ២០២៤ | | វឌ្ឍនភាពធៀបនឹងចំណុចដៅ ប្រចាំឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី១ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពនៃការអនុវត្តសំខាន់ៗ |
| | | ដោយផ្តោតលើការបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានៅក្នុងសហគមន៍មូលដ្ឋាន | | | | | | - គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA)<br>- គម្រោងគាំទ្រលេខាធិការដ្ឋានគ.ជ.អ.ប. ក្នុងការបំពេញលក្ខខណ្ឌស្ថាប័នអនុវត្តគម្រោងនៃ GCF<br>- គម្រោងនវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP)<br>- បាននិងកំពុងរៀបចំឯកសារទស្សនទានគម្រោងស្តីពីសេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងរណបអាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត (CR-Wash)<br>- បាននិងកំពុងរៀបចំឯកសារទស្សនទានគម្រោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវកសិកម្មអេកូឡូស៊ីដែលងាយរងគ្រោះដោយសារអាកាសធាតុនៅតំបន់ខ្ពង់រាប<br>- បានរៀបចំសេចក្តីព្រាងស្តីពីកិច្ចសន្យាហិរញ្ញប្បទានរបស់គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រី ដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ (EmPower) រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធី បរិស្ថាននៃអង្គការសហប្រជាជាតិ (UNEP)<br>- បានរៀបចំកិច្ចព្រមព្រៀងហិរញ្ញវត្ថុរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង (UNOPS)<br>- បាននិងកំពុងរៀបចំឯកសារទស្សនទានគម្រោងស្តីពីការពង្រឹងភាពធន់នឹងអាកាសធាតុក្នុងទីក្រុងភ្នំពេញ ដោយផ្តោតលើការជានាសហគមន៍ទីក្រុងប្រកបដោយសុវត្ថិភាព សុខភាពល្អ និងនិរន្តរភាពសម្រាប់ទាំងអស់គ្នា "Strengthening Urban Climate Resilience in Phnom Penh: Ensuring a Safer, Healthier, and Sustainable Urban Community for All"។ |

## ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆមាសទី១ ឆ្នាំ២០២៤របស់ក្រសួង ស្ថាប័ន

(គិតជាលានរៀល)

| ល.រ. | ក្រសួង ស្ថាប័ន | ថវិកាឆ្នាំ ២០២៤ | ថវិកា ចំណាយ ឆមាសទី១ឆ្នាំ ២០២៤ | សមតុល្យ |
|---|---|---|---|---|
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550 | 3,950 | 4,600 |
| ២ | ក្រសួងមហាផ្ទៃ | 297 | 64 | 233 |
| ៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 248 | 0 | 248 |
| ៤ | ក្រសួងមុខងារសាធារណៈ | 60 | 0 | 60 |
| ៥ | ក្រសួងផែនការ | 99 | 0 | 99 |
| ៦ | ក្រសួងកិច្ចការនារី | 275 | 151 | 124 |
| ៧ | ក្រសួងសាធារណការ និងដឹកជញ្ជូន | 80 | 48 | 32 |
| ៨ | ក្រសួងបរិស្ថាន | 44 | 9 | 36 |
| ៩ | ក្រសួងទេសចរណ៍ | 60 | 17 | 43 |
| ១០ | ក្រសួងពាណិជ្ជកម្ម | 75 | 27 | 48 |
| ១១ | ក្រសួងធនធានទឹក និងឧតុនិយម | 35 | 2 | 33 |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 42 | 0 | 42 |
| ១៣ | ក្រសួងរ៉ែ និងថាមពល | 68 | 31 | 36 |
| ១៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ | 78 | 0 | 78 |
| ១៥ | ក្រសួងសុខាភិបាល | 50 | 0 | 50 |
| ១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 122 | 64 | 58 |
| ១៧ | ក្រសួងអប់រំ យុវជន និងកីឡា | 200 | 23 | 177 |
| ១៨ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 60 | 16 | 44 |
| ១៩ | ក្រសួងអភិវឌ្ឍន៍ជនបទ | 178 | 13 | 166 |
| ២០ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 75 | 1 | 74 |
| ២១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 51 | 24 | 27 |
| ២២ | ក្រសួងព័ត៌មាន | 100 | 10 | 90 |
| ២៣ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 220 | 0 | 220 |
|  | **សរុប** | **11,067** | **4,448** | **6,619** |

## ទិន្នន័យភាពនៃការអនុវត្តថវិកាប្រចាំឆមាសទី១ ឆ្នាំ២០២៤របស់រាជធានី ខេត្ត

(គិតជាលានរៀល)

| ល.រ. | រាជធានី ខេត្ត | ថវិកាឆ្នាំ២០២៤ | ថវិកាចំណាយ ឆមាសទី១ឆ្នាំ២០២៤ | សមតុល្យ |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | 322 | 58.39 | 263 |
| ២ | បាត់ដំបង | 824 | - | 824 |
| ៣ | កំពង់ចាម | 771 | 163.79 | 607 |
| ៤ | កំពង់ឆ្នាំង | 224 | 37.40 | 187 |
| ៥ | កំពង់ស្ពឺ | 291 | 139.00 | 152 |
| ៦ | កំពង់ធំ | 771 | 50.14 | 720 |
| ៧ | កំពត | 797 | 257.77 | 539 |
| ៨ | កណ្តាល | 1,591 | - | 1,591 |
| ៩ | កោះកុង | 621 | 251.50 | 369 |
| ១០ | ក្រចេះ | 412 | 109.77 | 303 |
| ១១ | មណ្ឌលគិរី | 252 | 48.23 | 203 |
| ១២ | ភ្នំពេញ | 2,238 | 581.22 | 1,657 |
| ១៣ | ព្រះវិហារ | 183 | 30.25 | 153 |
| ១៤ | ព្រៃវែង | 298 | - | 298 |
| ១៥ | ពោធិ៍សាត់ | 224 | 53.47 | 170 |
| ១៦ | រតនគិរី | 177 | 87.58 | 90 |
| ១៧ | សៀមរាប | 331 | - | 331 |
| ១៨ | ព្រះសីហនុ | 410 | 93.42 | 317 |
| ១៩ | ស្ទឹងត្រែង | 243 | 14.29 | 229 |
| ២០ | ស្វាយរៀង | 351 | 152 | 199 |
| ២១ | តាកែវ | 306 | 203.50 | 103 |
| ២២ | ឧត្តរមានជ័យ | 188 | 40.01 | 148 |
| ២៣ | កែប | 37 | 5.10 | 32 |
| ២៤ | ប៉ៃលិន | 265 | 8.64 | 256 |
| ២៥ | ត្បូងឃ្មុំ | 369 | 56.00 | 313 |
| **សរុប** | | **12,496** | **2,441** | **10,055** |

## វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆមាសទី១ ឆ្នាំ២០២៤របស់ដៃគូអភិវឌ្ឍ

(គិតជាលានរៀល)

| ល.រ. | គម្រោង | ប្រភពមូលនិធិ | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|---|---|
| ១ | ការលើកកម្ពស់អាហារូបត្ថម្ភ (CNP) | WB | 26,982 | 5,506 | 21,476 |
| ២ | ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) | ADB, RGC | 18,236 | 5,729 | 12,507 |
| ៣ | ការគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | ADB | 17,000 | 13,000 | 4,000 |
| ៤ | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STAD) | UNDP | 2,915 | 195 | 2,720 |
| ៥ | ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF) | WB | 10,050 | 1,260 | 8,790 |
| ៦ | លើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (ISAF-CSOs) | WB | 16,542 | 7,550 | 8,992 |
| ៧ | នវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP) | UNCDF | 394 | 57 | 337 |
| ៨ | ការលើកកម្ពស់វិស័យសេវាសង្គម | UNICEF | 300 | 230 | 70 |
| ៩ | លើកកម្ពស់កិច្ចគាំពារកុមារ | UNICEF | - | - | - |
| ១០ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD) | GIZ | - | - | - |
| ១១ | ការរៀបចំយន្តការ និងសៀវភៅណែនាំស្តីពីមូលនិធិវិនិយោគប្រែប្រួលអាកាសធាតុរដ្ឋបាលថ្នាក់ក្រោមជាតិ (SCIF) | UNDP | 1,800 | - | 1,800 |
| ១២ | សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ASAC | 1,315 | - | 1,315 |
| **សរុប** | | | **95,534** | **33,525** | **62,009** |

## ឧបសម្ព័ន្ធទី៣ ÷ ស្ថានភាពនៃការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាពទី១ ៖ ការគ្រប់គ្រង និងការសម្របសម្រួលកម្មវិធីកំណែទម្រង់** | | | | | | |
| ១ | ធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ដែលបានសន្យាគាំទ្រដោយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត មិនបានវិភាជគ្រប់គ្រាន់ និងផ្តល់គ្រប់ចំនួន និងទាន់ពេលវេលា | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដានការអនុវត្តគ្រោងថវិកាឆ្នាំ ២០២៤ របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត<br>➢ ពង្រឹងការតាមដានការអនុវត្តសេចក្តីសម្រេចរួម<br>➢ ពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយ MEF ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | – ក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ បានអនុវត្តសេចក្តីសម្រេចរួមទាន់ពេលវេលា ស្របតាមទៅតាមផែនការដែលបានគ្រោងទុក។ |
| ២ | ភាពអសកម្មភាពនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់រឹមដ្ឋការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាំឱ្យដំណើរការ និងប្រសិទ្ធភាពនៃការងារកំណែទម្រង់មានការថយចុះ រួមបញ្ចូលទាំងការអនុវត្ត ផ.ស.ថ. សេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងនានា | ទាប | មធ្យម | ➢ ពង្រឹងការតាមដាន និងការអនុវត្តការងារកំណែទម្រង់ដោយ គ.ជ.អ.ប. តាមរយៈកិច្ចប្រជុំ គ.ជ.អ.ប.<br>➢ ពង្រឹងការរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ជាមួយស្ថាប័នអនុវត្តនានា | – គ.ជ.អ.ប.<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាក្នុងចំនួនសមស្រប (៥.៨លានដុល្លារ) សម្រាប់គាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ និងបានចំណាយសម្រាប់ការអនុវត្តកិច្ចការនេះចំនួនប្រមាណ២៩% ដូចមានបរិយាយនៅផ្នែកស្ថានភាពហិរញ្ញវត្ថុខាងលើ។ |
| **សមាសភាពទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងត្រួតពិនិត្យ | មធ្យម | មធ្យម | ➢ រៀបចំវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹងបន្ថែមទៅក្នុងការអនុវត្តតួនាទី និងអាណត្តិការងារ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាល ថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | លើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួន | | | របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>➢ ការរៀបចំឱ្យមានគម្រោងចំណាយច្បាស់លាស់របស់ក្រុមប្រឹក្សានៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | តួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២ | មន្ត្រីរដ្ឋបាលខេត្តមិនផ្លាស់ប្តូរទម្លាប់ក្នុងការគ្រប់គ្រង និងអន្តរាគមន៍លើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋានឱ្យទៅជាការជួយគាំទ្រ ផ្ដែកបច្ចេកទេស និងការប្រឹក្សាយោបល់ | មធ្យម | ខ្ពស់ | ➢ ផ្តល់គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលខេត្តអំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន<br>➢ ជំរុញ និងពង្រឹងការតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ពីក្រសួងមហាផ្ទៃ ក្នុងករណីដែលមានអាកប្បកិរិយា និងសកម្មភាពមិនសមស្របរបស់មន្ត្រីនៃរដ្ឋបាលខេត្ត | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពការលើកកម្ពស់សមធម៌ និងបរិយាបន្នសង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការបង្កើនចំនួនស្ត្រី | មធ្យម | ខ្ពស់ | ➢ ពង្រឹងការផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ<br>➢ ពង្រឹងការត្រួតពិនិត្យ និងការគាំទ្រ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួងកិច្ចការនារី<br>– ក្រសួងមហាផ្ទៃ | – ផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួល ដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ។ |
| **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | | | |
| ១ | សិទ្ធិអំណាចក្នុងការជ្រើសរើស និងរៀបចំបុគ្គលិកមិនអាចអនុវត្តបានតាមគោលការណ៍បទប្បញ្ញត្តិដែលបានកំណត់ | មធ្យម | មធ្យម | ➢ ការរៀបចំសេចក្តីណែនាំបន្ថែមរបស់ថ្នាក់ជាតិដើម្បីពង្រឹងការអនុវត្តគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់រួចហើយ | – ក្រសួងមុខងារសាធារណៈ<br>– ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំផែនការ និងជ្រើសរើសបុគ្គលិករបស់ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ការពង្រឹងការតាមដាន ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក | | ខ្លួន ស្របតាមបែបបទ និងនីតិវិធីដែលមានស្រាប់។ |
| ២ | ការវាយតម្លៃបុគ្គលិកមិនត្រូវបានអនុវត្តទៀងទាត់ និងត្រឹមត្រូវ | មធ្យម | មធ្យម | ➢ ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យការអនុវត្តផែនការវាយតម្លៃបុគ្គលិកទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីថ្នាក់ជាតិ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងមុខងារសាធារណៈ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – បុគ្គលិកថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃរៀងរាល់២ឆ្នាំម្តងសម្រាប់ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ។ |
| ៣ | ខ្វះការចូលរួមរបស់មន្ទីរ អង្គភាពជំនាញនាំឱ្យការអភិវឌ្ឍសមត្ថភាព ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្ត មុខងារដែលបានផ្ទេរមិនសូវមានប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពង្រឹងកិច្ចសហការ និងផ្តល់ការគាំទ្រដល់មន្ទីរ អង្គភាពជំនាញក្នុងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌ<br>➢ ពង្រឹងការរៀបចំ និងការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ តាមរយៈ វិធីសាស្ត្រផ្សេងៗ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលរាជធានី ខេត្ត | – មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាសម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រីការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ៤ | ពុំមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអន្តរកាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដានក្រសួងមហាផ្ទៃ ក្នុងការរៀបចំ និងការវិភាជថវិកាសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការផ្តល់ថវិកាគាំទ្រផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀគរធនធានសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – ឆ្នាំ២០២៤នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន១៤វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦២១នាក់ ស្ត្រីចំនួន១៤០នាក់។ |

| ល.រ. |ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| ៥ | សមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅមានកម្រិតក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដាន ការគាំទ្រទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>➢ ការអភិវឌ្ឍសមត្ថភាពបន្ថែមទៅលើស្តង់ដានៃការអនុវត្តមុខងារដែលបានផ្ទេរក្រុង ស្រុក ខណ្ឌ | – គ.ជ.អ.ប.<br>– គ.ជ.វ.វ. ក្រសួង ស្ថាប័នអនុវត្ត | – ឆ្នាំ២០២៤នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងបានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពបន្ថែមស្តង់ដានៃការអនុវត្តមុខងារដែលបានផ្ទេរដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| **សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធកសាងផែនការ និងថវិកាថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | រដ្ឋបាលក្រុង ស្រុកមានធនធានថវិកាផ្នែកអភិវឌ្ឍន៍តិចតួចដែលមិនអាចអនុវត្តមុខងារ ផ្តល់សេវា ក៏ដូចជាការឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងចំណាយផ្នែកអភិវឌ្ឍន៍របស់ក្រុង ស្រុក<br>➢ សិក្សា និងរៀបចំលិខិតបទដ្ឋាននានាអំពីការបង្កើនចំណូលដល់រដ្ឋបាលក្រុង ស្រុក | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – មូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ត្រូវបានវិភាជចំនួន ១,៦% នៃចំណូលចរន្តថវិកាជាតិមានការកើនឡើងចំនួន ០,១% ធៀបនឹងឆ្នាំ២០២៣។ |
| ២ | ការផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពន្យារពេល | មធ្យម | ខ្ពស់ | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃកំពុងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា។ |
| **សមាសភាគទី៥ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | | |
| ១ | ភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក | ទាប | ខ្ពស់ | ➢ ជំរុញ និងពង្រឹងការរៀបចំឯកសារចាំបាច់នានានៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនានា<br>➢ លេខាធិការដ្ឋាន គ.ជ.អ.ប. តាមដាន សហការ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការរៀបចំឯកសារពាក់ព័ន្ធនានា | – ក្រសួង ស្ថាប័ន<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន៨ រួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | និងនិវានុវត្តន៍ ក្រសួងរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងអប់រំ យុវជន និងកីឡា។ |
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនពុំមានបុគ្គលិក និងសមត្ថភាពសមស្របនាំឱ្យការអនុវត្តមុខងារដែលបានផ្ទេរពុំមានប្រសិទ្ធភាព | ទាប | មធ្យម | ➢ សម្របសម្រួល និងពង្រឹងកិច្ចសហការរវាងកម្មវិធីកំណែទម្រង់ទាំងបីក្នុងការសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើង<br>➢ ពង្រឹងការតាមដាន ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌនៅនឹងកន្លែង<br>➢ សិក្សា និងពិនិត្យមើលជម្រើសនានាក្នុងការផ្ទេរបុគ្គលិកពីមន្ទីរ អង្គភាពជំនាញទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - បានរៀបចំកិច្ចប្រជុំកំណែទម្រង់ទាំង៣ចំនួន០៣លើកសម្រាប់ដោះស្រាយបញ្ហា ប្រឈមនានា<br>- ឆ្នាំ២០២៤នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន ១៤វគ្គ ដែលមានសិក្ខាកាមសរុប៦២១នាក់ ស្ត្រីចំនួន១៤០នាក់។ |
| ៣ | មុខងារជាជម្រើសពាក់ព័ន្ធនឹងសេវាសង្គមមិនអាចអនុវត្តស្របទៅតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ទាប | មធ្យម | ➢ គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការជ្រើសរើស ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសដែលពាក់ព័ន្ធនឹងសេវាសង្គម<br>➢ ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់អាទិភាពដល់ការចំណាយលើការផ្តល់សេវាសង្គមសម្រាប់ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ | - ក្រសួងមហាផ្ទៃ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលធិនិក្រុង ស្រុក និងមូលធិនិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន។ |
| ៤ | រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់តិចតួចអំពីអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះទាំងនៅក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកានានា | មធ្យម | មធ្យម | ➢ រៀបចំផែនការសកម្មភាពនិង ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ<br>➢ ពង្រឹងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួងមហាផ្ទៃ | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលធិនិក្រុង ស្រុក និងមូលធិនិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និង |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ពង្រឹងការវាយតម្លៃ និងតាមដានដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំ និងអនុវត្តកម្មវិធីផ្តល់ពានរង្វាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារបានល្អ | | អនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការងារសមភាពយេនឌ័របរិយាបន្ន និងសង្គម។ |
| ៥ | ក្រុង ស្រុក ខណ្ឌមួយចំនួនមិនសូវយកចិត្តទុកដាក់ និងផ្តួចផ្តើមគំនិតក្នុងការអនុវត្តលិខិតបទដ្ឋាននានាដែលមាន និងមុខងារនានាដែលបានផ្ទេរនាំឱ្យការគាំទ្ររបស់រាជធានី ខេត្ត មិនមានប្រសិទ្ធភាព | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ<br>➢ ធ្វើការណែនាំដល់ក្រុង ស្រុក ខណ្ឌដែលអសកម្ម | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - រដ្ឋបាលរាជធានី ខេត្តបានចុះតាមដាននិងគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជាប្រចាំក្នុងការរៀបចំ និងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ |
| ៦ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការចំណាយបន្ថែមលើការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា | មធ្យម | ខ្ពស់ | ➢ កៀរគរធនធានបន្ថែមពីមូលនិធិអាកាសធាតុបៃតង និងពីប្រភពផ្សេងទៀត ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ | - លេខាធិការដ្ឋាន គ.ជ.អ.ប. | - រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលបានថវិកាមួយចំនួន ដើម្បីអនុវត្តគម្រោងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| ៧ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | ➢ បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | - លេខាធិការដ្ឋាន គ.ជ.អ.ប. | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលធិនិក្រុង ស្រុក និងមូលធិនិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការពង្រឹងភាពធន់ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។ |